**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការប្រឡងប្រណាំងទីក្រុងស្អាត នៃរដ្ឋបាលខណ្ឌដូនពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ថុន ស្រីពៅ**

**ក. សាត ស៊ីថន**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៥

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការប្រឡងប្រណាំងទីក្រុងស្អាត នៃខណ្ឌដូនពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ក. ផុន ស្រីពេជ្រ** | **បណ្ឌិត អ៊ុន សកក្កដា** |
| **ក. សាត ស៊ីវន** | |


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | | ឆ្នាំចូលរៀន | ២០១៨ |
| ជំនាន់ទី ១៥ | | ឆ្នាំសរសេរសារណា | ២០២២ |

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំ **ថុន ស្រីពេជ្រ** និង **សាត ស៊ីវន** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាន់ទី១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨-២០២២។

**សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖**

| | | | |
|---|---|---|---|
| លោកឪពុក | **ខួន ថេត** | លោកឪពុក | **សាត ទ្រនាល** |
| អ្នកម្តាយ | **ខាត់ សុភី** | អ្នកម្តាយ | **តយ ម៉ាច** |

មាតាបិតាដែលជាអ្នកមានគុណដ៏ថ្លៃថ្លា ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ហើយផ្តល់នូវការអប់រំយ៉ាងច្រើនប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងទូន្មានប្រៀនប្រដៅកូនឱ្យក្លាយជា កូនល្អ សិស្សល្អ មិត្តល្អ និងជាបុគ្គលល្អក្នុងសង្គម។ មិនតែប៉ុណ្ណោះ លោកទាំងពីរបានផ្គត់ផ្គង់សម្ភារ និងឱកាសដល់នាងខ្ញុំទាំងពីរបានសិក្សារៀនសូត្រ ដើម្បីក្រេបជញ្ជក់យកចំណេះដឹង ចំណេះធ្វើ ដើម្បីក្លាយខ្លួនជាបុគ្គលដែលមានតម្លៃសម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិទាំងមូល។

សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចន្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងលោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរសរង ដែលបានអនុញ្ញាត និងផ្តល់លទ្ធភាពឱ្យនាងខ្ញុំទាំងពីរ ទទួលបាននូវឱកាសក្នុងការចូលសិក្សា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោក លោកស្រី ដែលជាសាស្ត្រាចារ្យ ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ណែនាំ និងផ្តល់នូវចំណេះដឹងដល់នាងខ្ញុំទាំងពីរអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ព្រមទាំងផ្តល់នូវដំបូន្មានអប់រំប្រដៅ និងទស្សនទានល្អៗជាច្រើនសម្រាប់ការសិក្សា និងការអភិវឌ្ឍខ្លួនក្លាយទៅជាបុគ្គលដែលមានសមត្ថភាពមួយរូបក្នុងសង្គម។

ជាពិសេស នាងខ្ញុំទាំងពីរ សូមគោរពអរគុណចំពោះ **លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ បានផ្តល់ជាយោបល់ល្អៗ និងជួយកែសម្រួលនូវសារណាមួយនេះតាំងពីចាប់ផ្តើម រហូតដល់បញ្ចប់នូវសៀវភៅមួយក្បាលនេះ បានជោគជ័យ។ ជាពិសេសរៀមច្បងជំនាន់មុនដែលបានបន្សល់ទុកនូវស្នាដៃល្អៗ ដែលជាឯកសារសម្រាប់ និស្សិតជំនាន់ក្រោយយកមកធ្វើជាគំរូ និងសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។

ជាចុងក្រោយនាងខ្ញុំទាំងពីរ សូមធ្វើការដឹងគុណដល់មាតាបិតា ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកទាំងអស់ដែលកំពុងបំពេញ ការងារនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ជួបប្រទះតែសេចក្តីសុខ ព្រមទាំងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បើក្រឡេកមើលទៅស្ថានភាពទីក្រុងនៅលើពិភពលោកក្នុងពេលបច្ចុប្បន្ន បានបង្ហាញឱ្យឃើញថា កំពុងតែមានការប្រែប្រួលទីក្រុងយ៉ាងខ្លាំង ដោយប្រទេសនីមួយៗកំពុងព្យាយាមអភិវឌ្ឍន៍ខ្លួនទៅជាទីក្រុងទំនើប មានសក្តានុពល និងមានភាពរីកចម្រើនកាន់តែខ្លាំង។ ជាក់ស្តែង ប្រទេសកម្ពុជាដែលជាសមាជិកអាស៊ានក៏ បានរួមបញ្ចូលទិសដៅនៃការបង្កើតនូវទីក្រុងស្អាតមួយ ដើម្បីប្រកួតប្រជែងជាមួយបណ្តាប្រទេសនៅអាស៊ានទាំងមូលផងដែរ។ អ្វីដែលកាន់តែចាប់អារម្មណ៍នោះ គ្រប់បណ្តាក្រុង-ខណ្ឌ នៅក្នុងប្រទេសកម្ពុជាទាំងមូល កំពុងតែអួតពីស្នាដៃ និងការអភិវឌ្ឍក្រុង-ខណ្ឌរបស់ខ្លួនយ៉ាងមុតមាំ ដើម្បីឱ្យតំបន់របស់ខ្លួនទទួលបាននូវពានរង្វាន់ទីក្រុងស្អាតក្នុងប្រទេស និងអាចឈានទៅប្រកួតជាមួយបណ្តាប្រទេសនៅក្នុងអាស៊ានបន្ត។ ដូចជាខណ្ឌដូនពេញកំពុងទទួលបានប្រជាប្រិយភាពនៅក្នុងរាជធានីភ្នំពេញ ដោយខណ្ឌដូនពេញ បានរៀបចំហេដ្ឋារចនាសម្ព័ន្ធបរិស្ថាន បរិយាកាស និងមានការបំពុលអាកាសធាតុតិចបំផុតដែលជាតម្រូវការនៃទីក្រុងស្អាត។ យ៉ាងណាមិញមន្ត្រីក្រុមការងារ និងភ្នាក់ងារទាំងអស់បានខិតខំប្រឹងប្រែងដើម្បីតំបន់របស់ខ្លួនណាស់ ប៉ុន្តែក៏តម្រូវឱ្យប្រជាពលរដ្ឋគ្រប់រូបសហការគ្នា និងជួយជំរុញអភិវឌ្ឍន៍ខណ្ឌឱ្យទទួលបានភាពស៊ីវិល័យផងដែរ។

ដោយនាងខ្ញុំទាំងពីរជឿជាក់ថា អាចប្រែក្លាយប្រទេសកម្ពុជាមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព ហើយតាមរយៈការប្រកួតប្រជែងទាំងក្រុង និងខណ្ឌទាំងអស់ក្នុងប្រទេស ទីណាមានការប្រកួតប្រជែង ទីនោះមានការអភិវឌ្ឍ ពីព្រោះគ្រប់ក្រុង-ខណ្ឌ គឺចង់ឱ្យតំបន់ខ្លួនក្លាយជាតំបន់លិចធ្លោជាងគេ ដូចនេះប្រទេសនឹងអាចដោះស្រាយនូវបញ្ហាប្រែប្រួលអាកាសធាតុ ស្របពេល ដែលយើងកំពុងខិតខំបន្តអភិវឌ្ឍន៍សេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ ពង្រឹងការអភិវឌ្ឍ និងបរិយាប័ន្នសង្គម និងប្រែក្លាយទៅជាទីក្រុងស្អាតផងដែរ ទើបក្រុមនាងខ្ញុំទាំងពីរធ្វើការស្រាវជ្រាវក្រោមប្រធានបទមួយស្តីពី **ការប្រឡងប្រណាំងទីក្រុងស្អាតនៃរដ្ឋបាលខណ្ឌដូនពេញ** ដើម្បីបង្ហាញពីវឌ្ឍនភាពក្នុងការប្រឡងប្រណាំងទីក្រុងស្អាតនៃខណ្ឌមួយនេះ ទៅកាន់បណ្តាក្រុង និងខណ្ឌផ្សេងៗទៀតយកជាគំរូ។

នាងខ្ញុំទាំងពីរបានត្រួតពិនិត្យ និងកែសម្រួលជាច្រើនដង ប៉ុន្តែនាងខ្ញុំទាំងពីរប្រាកដជានៅមានចំណុចខ្វះខាតកើតមានឡើង ទាំងអត្ថន័យខ្លឹមសារ ពាក្យពេជន៍ឃ្លាឃ្លោង ទាំងអក្ខរាវិរុទ្ធ និងបច្ចេកទេសនៃការចងក្រងនៅមានកម្រិតផងនោះ ដូច្នេះហើយនាងខ្ញុំទាំងពីរ សូមធ្វើការអភ័យទោស កំហុសដែលបានកើតឡើងដោយអចេតនា ហើយនាងខ្ញុំទាំងពីរមានសេចក្តីសោមនស្សរីករាយ ទទួលការរិះគន់ក្នុងន័យស្ថាបនា ដើម្បីកែលម្អបន្ថែមឆ្ពោះទៅរកសុក្រឹតភាពនៃសារណានេះ ដើម្បីទុកជាឯកសារដល់និស្សិតជំនាន់ក្រោយៗទៀត។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ការប្រឡងប្រណាំងទីក្រុងស្អាត**

**១.១. ទិដ្ឋភាពទូទៅ** ........ ៦

១.១.១. ប្រវត្តិនៃការរៀបចំទីក្រុងស្អាត ........ ៧

១.១.២. និយមន័យ ........ ៨

១.១.៣. បរិបថនៃមូលហេតុនាំឱ្យមានការរៀបចំទីក្រុងស្អាត ........ ៨

**១.២. ការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត** ........ ៩

១.២.១. សមាសភាព ........ ៩

១.២.២. តួនាទីភារកិច្ចរបស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ........ ១០

១.២.៣. រចនាសម្ព័ន្ធ និងការគ្រប់គ្រង ........ ១១

១.២.៤. អាណត្តិនៃការប្រឡងប្រណាំងទីក្រុងស្អាត ........ ១៤

**១.៣. លក្ខខ័ណ្ឌនៃការចូលរួមប្រឡងប្រណាំងទីក្រុងស្អាត** ........ ១៥

១.៣.១. នីតិវិធីនៃការប្រឡងប្រណាំង ........ ១៥

១.៣.២. កាលបរិច្ឆេទ និងទទួលពាក្យ ........ ១៦

១.៣.៣. សូចនាករ និងលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃ ........ ១៦

១.៣.៤. សុពលភាព និងកម្រិតពានរង្វាន់ និងស្លាកសញ្ញាសម្រាប់ទីក្រុងជ័យលាភី ........ ២៤

១.៣.៥. ការផ្លាស់ប្តូ ឬដកហូតឡាបិលទីក្រុងស្អាត ........ ២៤

**ជំពូកទី២**

**យុទ្ធសាស្ត្រនៃខណ្ឌដូនពេញក្នុងការប្រឡងប្រណាំងទីក្រុងស្អាត**

**២.១. វិស័យសំខាន់ៗសម្រាប់ការអភិវឌ្ឍនិរន្តរភាពនៅក្នុងខណ្ឌ** ........ ២៦

២.១.១. ការរៀបចំផែនការអភិវឌ្ឍខណ្ឌ ........ ២៦

២.១.២. វិស័យដឹកជញ្ជូន ........ ២៨

២.១.៣. បរិស្ថានសំណង់ ........................................................................................................ ២៩
២.១.៤. ការគ្រប់គ្រងសំរាម/សំណល់រឹង.......................................................................................... ៣០
២.១.៥. ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌ ............................................................................. ៣១
**២.២. របៀបនៃការរៀបចំខណ្ឌជូនពេញនាពេលបច្ចុប្បន្ន** ................................................................. ៣៣
២.២.១. ការរៀបចំខណ្ឌឱ្យមានសោភ័ណភាពក្នុងការទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិ ........................ ៣៣
២.២.២. ការរៀបចំខណ្ឌឱ្យមានសណ្តាប់ធ្នាប់ សន្តិសុខ និងហេដ្ឋារចនាសម្ព័ន្ធ ................................... ៤១
**២.៣. គម្រោងការអភិវឌ្ឍខណ្ឌជូនពេញនាពេលអនាគត** ..................................................................៤៥
២.៣.១. បន្តរៀបចំសណ្តាប់ធ្នាប់ ផ្លូវសាធារណៈ និងកាត់បន្ថយការកកស្ទះចរាចរណ៍ ...........................៤៥
២.៣.២. បន្តការណែនាំ និងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ............................................ ៤៧
**សេចក្តីសន្និដ្ឋាន** ...................................................................................................................... ៥០
**អនុសាសន៍** ...............................................................................................................................៥១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសជាច្រើននៅក្នុងអាស៊ានមានការផ្តោតសំខាន់លើទីក្រុងស្អាត រហូតឈានទៅដល់ការដាក់ឱ្យមានការប្រកួតប្រជែងគ្នា ក្នុងនោះប្រទេសកម្ពុជាក៏ជាបេក្ខភាពចូលរួមប្រឡងប្រជែងផងដែរ វាក្លាយជាយុទ្ធសាស្ត្រល្អមួយក្នុងការអភិវឌ្ឍប្រទេសកាន់តែជឿនលឿនក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ បណ្តារាជធានី-ខេត្ត ក្រុង-ខណ្ឌបានបញ្ចេញ និងបង្អួតពីតំបន់របស់ខ្លួនរៀងៗខ្លួន ជាមួយនេះផងដែរ ខណ្ឌដូនពេញ ជាខណ្ឌមួយដែលមានប្រជាប្រិយភាព និងទទួលបានការកោតសរសើរពីមហាជនក្នុងចំណោមទីក្រុងផ្សេងៗទៀត ក៏មិនមែនបានសេចក្តីថាខណ្ឌដូនពេញល្អជាងគេដែរ គ្រាន់តែអាចស្វែងយល់ពីខណ្ឌមួយនេះមានគុណសម្បត្តិអាចឈានចូលក្នុងលំដាប់លេខជួរមុខនៃទីក្រុងស្អាតបាន ហេតុនេះហើយទើបក្រុង-ខណ្ឌគប្បីសង្កេតទៅមើលបញ្ញតិនៃការប្រឡងប្រណាំងទីក្រុងស្អាតឱ្យបានត្រឹមត្រូវ ឱ្យគ្រប់ជ្រុងជ្រោយ ពោលគឺមានលក្ខណ្ឌពិសេសផ្សេងៗទៀតដែលក្រុង-ខណ្ឌត្រូវតែតាមដានយ៉ាងល្អិតល្អន់។

បច្ចុប្បន្ន ខណ្ឌដូនពេញមានការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍខណ្ឌយ៉ាងសកម្ម ជាពិសេសគឺរៀបចំសោភ័ណភាព អនាម័យ បរិស្ថានល្អ ឱ្យចំគោលបំណងនៃព្រះរាជក្រឹត្យ នស/រកត/០៦១១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។ ការប្រកួតប្រជែងទីក្រុងស្អាត ពិតជាមានសារៈសំខាន់ណាស់ ដើម្បីជ្រើសរើសតំបន់ដែលល្អបំផុតទាល់តែប្រកាន់ភ្ជាប់នូវការវាយតម្លៃគួរឱ្យជឿជាក់។ ចំពោះប្រធានបទ ការប្រឡងប្រណាំងទីក្រុងស្អាតនៃរដ្ឋបាលខណ្ឌដូនពេញ គឺជាប្រធានបទមួយដែលទាក់ទាញចំណាប់អារម្មណ៍សិស្សនិស្សិតទូទៅក្នុងការសិក្សាស្រាវជ្រាវ ស្វែងយល់ ពង្រឹងនូវពុទ្ធិ ជាពិសេសសម្រាប់ប្រជាពលរដ្ឋទាំងក្នុង និងក្រៅប្រទេសដែលមានបំណងចង់យល់ដឹងពីការរៀបចំមូលដ្ឋានខ្លួន ឱ្យមានសុវត្ថិភាព សុខុមាលភាព ការធានា ការអប់រំ ផាសុកភាព រមណីយដ្ឋានទេសចរណ៍គំរូ បដិសណ្ឋារកិច្ចល្អ ក៏រួមចំណែកឱ្យតំបន់ខ្លួនទទួលបានការកោតសរសើរ ដោយយកគំរូតាមខណ្ឌដូនពេញដែរ ដូចនេះថ្នាក់លើមិនបានខំតែម្នាក់ឯងទេ គឺប្រជាពលរដ្ឋក៏បានជួយលើកទឹកចិត្ត និងសម្រាលការងារខ្លះៗបាន។ ទន្ទឹមនឹងមានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល និងកម្រងបទដ្ឋានគតិយុត្តសម្រាប់ទ្រទ្រង់ដំណើរការគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតកម្ពុជាក៏បានបង្កើតសកម្មភាពប្រឡងប្រណាំងទីក្រុងស្អាតសាកល្បងចំពោះខណ្ឌដូនពេញ ដើម្បីឱ្យដំណើរការប្រឡងពិតប្រាកដ ប្រព្រឹត្តទៅយ៉ាងត្រឹមត្រូវ និងឯកភាពគ្នាយ៉ាងរលូនផងដែរ។

ដូច្នេះប្រធានបទនេះនឹងផ្តល់នូវខ្លឹមសារ និងផលប្រយោជន៍ជាច្រើនដល់អ្នកសិក្សា និងក្រុង-ខណ្ឌផ្សេងៗទៀត ហើយអាចចូលរួមចំណែកចែករំលែកនូវឯកសារសិក្សាស្រាវជ្រាវសម្រាប់និស្សិតជំនាន់ក្រោយៗ មានបំណងចង់យកអានបន្ត សង្ឃឹមថា ប្រធានបទនេះមានភាពទូលំទូលាយជាងនេះ មិនចង់លើគ្រប់គ្នាគិតថា ទាល់តែមន្ទីរ

ជំនាញខាងបរិស្ថាន ខាងទេសចរណ៍ទើបយល់ដឹងពីរឿងនេះ និស្សិត ប្រជាពលរដ្ឋមួយចំនួនមិនទាំងស្គាល់ អ្វីទៅដែលហៅថា ទីក្រុងស្អាតផង?

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងបើកទទួលភ្ញៀវទេសចរណ៍ទាំងជាតិ និងអន្តរជាតិក្នុងប្រទេសឡើងវិញ។ រដ្ឋបាលខណ្ឌដូនពេញ បានចាត់ចែងយុទ្ធសាស្ត្រដើម្បីរង់ចាំទទួលភ្ញៀវទេសចរណ៍អញ្ជើញមកទស្សនាតំបន់ស្អាតៗ រមណីយដ្ឋាន ភោជនីយដ្ឋាន និងកន្លែងសប្បាយជាច្រើន។ ម្យ៉ាងវិញទៀត ផ្នែកសណ្ដាប់ធ្នាប់បរិស្ថានគ្មានសំរាម សន្តិសុខ សុវត្ថិភាពទាំងអស់ ត្រូវតែយាមល្បាតយ៉ាងត្រឹមត្រូវជៀសវាងការបង្កនូវភាពរាយប៉ាយសំរាម និងភាពចលាចលពីសំណាក់ក្រុមអ្នកលេង ក្មេងទំនើងមួយចំនួន អាចប៉ះពាល់ដល់សង្គម ក៏ដូចជាបាក់បែក បំផ្លាញទ្រព្យសម្បត្តិសាធារណៈ។ ចំណែកឯវិស័យសំខាន់ៗក្នុងខណ្ឌ ក៏មិនត្រូវរំលងដែរ ដោយសារជាផ្នែកមួយជួយអភិវឌ្ឍន៍និរន្តរភាពខណ្ឌ ប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានទទួលបានជីវភាពធូរធា។ ស្ដែងឱ្យឃើញពីភាពរុងរឿងនៃខណ្ឌ ទើបអាចប្រឡងប្រណាំងទីក្រុងស្អាតបាន។

- តើការរៀបចំការប្រឡងប្រណាំងទីក្រុងស្អាតត្រូវបានរៀបចំយ៉ាងដូចម្ដេច? មានលក្ខខណ្ឌិកៈអ្វីខ្លះក្នុងការចូលរួមប្រឡងប្រណាំងទីក្រុងស្អាត?
- តើខណ្ឌដូនពេញមានយុទ្ធសាស្ត្រយ៉ាងដូចម្ដេច ក្នុងការប្រឡងប្រណាំងទីក្រុងស្អាត? តើខណ្ឌដូនពេញទទួលបានជ័យលាភីនៃការប្រឡងប្រណាំងទីក្រុងស្អាតដែរឬទេ?
- តើខណ្ឌដូនពេញនឹងរៀបចំគម្រោងផែនការសកម្មភាពអ្វីខ្លះបន្ថែមទៀត ក្នុងការប្រឡងប្រណាំងទីក្រុងស្អាតសម្រាប់ឆ្នាំបន្តបន្ទាប់?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ចំពោះគោលបំណងនៃការស្រាវជ្រាវលើប្រធានបទនេះ ដោយរូបនាងខ្ញុំបានឃើញពីបញ្ហាមួយចំនួនៈ

ទី១ ដើម្បីសិក្សាស្វែងយល់អំពីឯកសារស្ដង់ដាក្នុងការប្រឡងប្រណាំងទីក្រុងស្អាត

ទី២ ដើម្បីសិក្សាស្វែងយល់ពីការអនុវត្តជាក់ស្ដែងទៅលើការប្រឡងប្រណាំងទីក្រុងស្អាត

ទី៣ ដើម្បីរួមចំណែកក្នុងការបំផុសផ្សព្វផ្សាយដល់សាធារណជនទាំងអស់ ឱ្យយល់ពីការប្រឡងប្រជែងមួយនេះ ដោយលើកយកតែខណ្ឌដូនពេញជាគំរូ ដែលជាបេក្ខភាពឆ្នើមផងដែរ

ទី៤ ដើម្បីទុកជាស្នាដៃសម្រាប់និស្សិតជំនាន់ក្រោយ សិក្សាស្រាវជ្រាវលើប្រធានបទខាងលើវាគ្រាន់តែជាជ្រុងមួយនៃប្រធានបទនេះតែប៉ុណ្ណោះ ព្រោះទាក់ទងនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការប្រឡងប្រណាំងទីក្រុងស្អាត វាមានទំហំទូលំទូលាយណាស់ ហើយសង្ឃឹមថា វាអាចជាប្រទីបដ៏តូចមួយសម្រាប់និស្សិតជំនាន់ក្រោយសិក្សាស្រាវជ្រាវ និងពង្រីកន័យសេចក្ដីនៃប្រធាន

បទ និងឱ្យកាន់តែធំទូលាយបន្ថែមទៀត ព្រោះប្រទេសកម្ពុជាយើងជាប្រទេសដែលឱ្យតម្លៃលើតំបន់ដែលមានបដិសណ្ឋារកិច្ចល្អ ផ្សារស្អាត សាលាស្អាត ធុរកិច្ចក្នុងវិស័យទេសចរណ៍ និងទីក្រុងទេសចរណ៍ស្អាតអាស៊ាន។ ហេតុនេះ ដូចជាខណ្ឌដូនពេញអញ្ចឹង ប្រាដកជាមានចំណុចល្អៗពាក់ព័ន្ធនឹងផ្នែកខាងលើនេះហើយទើបអាចឈរក្នុងចំណោមបេក្ខភាពឆ្នើមបាន។ ការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើពិតជាមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះប្រធានបទនេះនឹងអាចជាចំណែកមួយនៃការយល់ដឹង ចំពោះប្រជាពលរដ្ឋ និងនិស្សិតជាច្រើនដែលកំពុងតែសិក្សានៅតាមបណ្តាសាកលវិទ្យាល័យ។ សម្រាប់ក្រុមនាងខ្ញុំ ប្រធានបទនេះពិតជាសំខាន់ណាស់ ព្រោះថាជាការសិក្សារបស់និស្សិតភាគច្រើន ពុំទាន់ស្វែងយល់ឱ្យមានភាពស៊ីជម្រៅទាក់ទងនឹងប្រធានបទនៃការប្រឡងប្រណាំងទីក្រុងស្អាតនៃខណ្ឌដូនពេញនៅឡើយ ហើយចំពោះប្រធានបទនេះ វាជាប្រធានបទថ្មីមួយសម្រាប់ក្រុមនាងខ្ញុំ ហើយក្រុមនាងខ្ញុំនឹងព្យាយាមសិក្សាស្វែងយល់លើប្រធានបទនេះ ឱ្យបានល្អប្រសើរ ហើយស្វែងរកទិន្នន័យថ្មី និងឯកសារពាក់ព័ន្ធនានាដើម្បីជាពន្លឺមួយសម្រាប់មិត្តនិស្សិតជំនាន់ក្រោយ សិក្សាស្រាវជ្រាវស្វែងយល់ឱ្យកាន់តែសុក្រឹត និងធំទូលាយជាងនេះទៅទៀត។

ចំពោះប្រធានបទខាងលើនេះ ពិតជាមានសារៈសំខាន់ និងមានភាពចាំបាច់ណាស់សម្រាប់និស្សិត និងប្រជាពលរដ្ឋក្នុងតំបន់នាពេលបច្ចុប្បន្ននេះ ព្រោះការយល់ដឹងនៅមានកម្រិតតិចតួចពីការប្រឡងប្រណាំងទីក្រុងស្អាតនេះ និស្សិតមិនស្គាល់ ប្រជាពលរដ្ឋនៅក្នុងតំបន់សាមី មិនជ្រាបទៀត ធ្វើមិចទើបអាចឱ្យក្រុង-ខណ្ឌដំណើរការបានស្រុះគ្នាទៅ។ គួរឱ្យកោតសរសើរខណ្ឌដូនពេញ ដែលប្រជាជនភាគច្រើនមានភាពទាន់សម័យ បានស្តាប់ព័ត៌មាន និងពីការផ្សព្វផ្សាយតាមទូរទស្សន៍ ឬប្រព័ន្ធអ៊ីនធឺណែត (ទូរស័ព្ទ) ជាដើម។ ចំពោះប្រធានបទមួយនេះនឹងផ្តល់នូវខ្លឹមសារ និងប្រយោជន៍ជាច្រើនដល់អ្នកសិក្សា ក្រុង-ខណ្ឌផ្សេងទៀត ដើម្បីជំនួយផ្នែកពុទ្ធិ ស្មារតីឱ្យកាន់តែច្បាស់ និងស៊ីជម្រៅថែមមួយកម្រិតទៀត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះទំហំនៃការសិក្សាស្រាវជ្រាវនេះ វាទាក់ទងជាមួយនឹងព្រះរាជក្រឹត្យ នស/រកត/០៦១១/៦១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១។ អនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២។ សេចក្តីសម្រេចលេខ៦៨៦/២១ សសរ.អ ស្តីពីការបង្កើតក្រុមវាយតម្លៃទីក្រុងស្អាតខណ្ឌដូនពេញ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១។

ដោយប្រធានបទខាងលើពាក់ព័ន្ធនឹងការប្រឡងប្រណាំងទីក្រុងស្អាតនៃខណ្ឌដូនពេញ ដូច្នេះខ្លឹមសារនៃប្រធានបទនេះផ្តោតសំខាន់ទៅលើ៖

ទី១ ទាក់ទងនឹងចលនានៃការប្រឡងប្រណាំងទីក្រុងស្អាត

ទី២ ទាក់ទងនឹងលទ្ធផលនៃការចុះស្រាវជ្រាវនៅខណ្ឌដូនពេញ

ទី៣ ការពិភាក្សាលើប្រធានបទដែលបានស្រាវជ្រាវ។

ចំពោះដែនកំណត់ នៃការស្រាវជ្រាវលើប្រធានបទនេះ ថាតើវិធានគតិយុត្តនៃការប្រឡងប្រណាំងទីក្រុងស្អាត មានសារៈសំខាន់អ្វីខ្លះ តើមានអានុភាពគតិយុត្តយ៉ាងដូចម្តេច។ ចុះលទ្ធផលនៃការស្រាវជ្រាវផ្តល់ផលប្រយោជន៍អ្វីខ្លះដល់អ្នកសិក្សា ហើយតើគួរពិភាក្សាដេញដោលលើប្រធានបទនេះត្រង់ចំណុចណាខ្លះ និងផ្តល់ប្រយោជន៍អ្វីខ្លះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវៈ

សារៈសំខាន់នៃប្រធានបទដែលក្រុមនាងខ្ញុំលើកមកធ្វើការសិក្សាស្រាវជ្រាវ ជាទូទៅបានគិតពិចារណាលើត្រង់ចំណុចមួយចំនួនគឺៈ

- មានសារៈសំខាន់ចំពោះសង្គម ប្រជាពលរដ្ឋបានរស់នៅក្នុងកន្លែងដែលទំនើប ស៊ីវិល័យ ទីក្រុងស្អាត និងជាតំបន់ដ៏ល្បីល្បាយសម្រាប់ប្រទេសជាតិទាំងមូល។
- មានសារៈសំខាន់ចំពោះវិស័យទេសចរណ៍ កាលណាមានភ្ញៀវទេសចរណ៍អញ្ជើញមកកំសាន្តអារម្មណ៍ច្រើនកុះករ នោះជាសញ្ញាល្អដែលអាចនាំចំណូលចូលរដ្ឋបានកាន់តែប្រសើរ ហើយខណ្ឌដូនពេញក៏ជាខណ្ឌសម្បូរទៅដោយជនជាតិបរទេសមកទស្សនៈកិច្ច និងដើរលេងដែរ សបញ្ជាក់ឱ្យឃើញថា ទាល់តែមានការប្រឡងប្រណាំងគ្នា ទើបមានការអភិវឌ្ឍហើយវិស័យទេសចរណ៍ជាតិនឹងបម្រើនូវសេវាកាន់តែល្អ។
- មានសារៈសំខាន់ចំពោះគោលការណ៍តម្លាភាព ឱ្យឃើញថាការដាក់ពិន្ទុទៅលើក្រុង-ខណ្ឌនីមួយៗ ប្រកបដោយការវិនិច្ឆ័យច្បាស់លាស់ពីគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត និងកិច្ចសហការត្រូវតែគោរពតាម និងអនុវត្តតាមគ្រប់ភាគីពាក់ព័ន្ធដើម្បីធានាប្រសិទ្ធភាព។ ដូចនេះប្រជាពលរដ្ឋមានទំនុកចិត្តគ្រប់បេក្ខភាពយល់ស្រប និងបណ្តាប្រទេសក្នុងអាស៊ានជឿជាក់លើការជ្រើសរើសចេញពីប្រទេសកម្ពុជា។
- មានសារៈសំខាន់ចំពោះក្រុង-ខណ្ឌនានា ស្វែងរកចំណុចល្អៗ របៀបចាត់ចែង យុទ្ធសាស្ត្រគ្រប់គ្រងនៃខណ្ឌដូនពេញ ដោយសារចលនាប្រឡងប្រណាំងនេះ អនុញ្ញាតឱ្យចែករំលែកបទពិសោធន៍ អំណះអំណាង និងសកម្មភាពអនុវត្តរបស់ខ្លួនដែលបានធ្វើកន្លងមក។

មានសារៈប្រយោជន៍ចំពោះរូបនាងខ្ញុំផ្ទាល់ បន្ថែមចំណេះដឹងដល់រូបនាងខ្ញុំឱ្យកាន់តែទូលំទូលាយជាងមុន និងយល់កាន់តែច្បាស់អំពីដំណើរការនៃការប្រឡងប្រណាំងទីក្រុងស្អាត ដោយបន្លឺថាទីក្រុងស្អាតមិនសំដៅចំពោះតែបរិស្ថានមួយផ្នែកទេ គឺស្តែងបង្ហាញពីក្រុង-ខណ្ឌទាំងមូលគ្រប់ផ្នែកទាំងអស់តែម្តង។ ជាពិសេសនាងខ្ញុំបានចុះទៅកន្លែងផ្ទាល់ បានត្រួតពិនិត្យរបាយការណ៍លម្អិត និងសមិទ្ធផល តថភាពច្បាស់ៗនៅខណ្ឌដូនពេញ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ទិន្នន័យដែលបានស្រាវជ្រាវ គឺយកមកវិភាគតាមរយៈពិពណ៌នាបែបគុណភាព ដើម្បីទទួលបានលទ្ធផលនៃការស្រាវជ្រាវនេះ មានលក្ខណៈវិទ្យាសាស្ត្រ និងកម្រិតនៃការជឿជាក់អាចទទួលយកបានដោយប្រើទិន្នន័យទី១ (Primary Data) និងទិន្នន័យទី២ ( Secondary Data) បូករួមបញ្ចូលគ្នា។

- ទិន្នន័យទី១ ជាប្រភេទទិន្នន័យផ្ទាល់ (Primary Data) សាកសួរទៅកាន់សាស្ត្រាចារ្យជំនាញ តាមរយៈទូរស័ព្ទ និងបានសួរសំណួរដោយផ្ទាល់ទៅកាន់មន្ត្រីជំនាញទេសចរណ៍ និងបរិស្ថាននៅខណ្ឌដូនពេញ។
- ទិន្នន័យទី២ ( Secondary Data) បានមកពីការដកស្រង់ខ្លឹមសារសំខាន់ៗ ច្បាប់ និងបទដ្ឋានគតិយុត្តនានា សៀវភៅរបាយការណ៍ សៀវភៅសារណារបស់សិស្សច្បងមុនៗ សៀវភៅរបស់សាស្ត្រាចារ្យយកមកពីបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បណ្ណាល័យផ្សេងៗទៀត តាមរយៈ Google Website និង Youtube ជាដើម។

បន្ទាប់ពីទទួលបានទិន្នន័យរួច នាងខ្ញុំបានយកមកធ្វើការវិភាគដោយស្វែងរក និងដាក់តាមចំណុច រួចយកមកធ្វើការវែកញែកស្វែងរកចំណុចខ្លាំងនៃខណ្ឌដូនពេញ គុណសម្បត្តិ រួចហើយចុងក្រោយទើបទទួលបាននូវទិន្នន័យរួមមួយដែលជាទិន្នន័យជាក់លាក់យកមកធ្វើការពិពណ៌នា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ត្រូវបានចែកចេញជាសេចក្តីផ្តើម និង២ជំពូក

សេចក្តីផ្តើមនិយាយអំពី៖ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

- **ជំពូកទី១ "ការប្រឡងប្រណាំងទីក្រុងស្អាត"៖** នៅក្នុងជំពូកនេះនាងខ្ញុំនឹងបែងចែកជាបីចំណុចបន្ថែមទៀត ដោយចំណុចទី១ និយាយអំពីសញ្ញាណទូទៅ ចំណុចទី២ បង្ហាញអំពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត និងចំណុចទី៣ លក្ខន្តិកៈនៃការចូលរួមប្រឡងប្រណាំងទីក្រុងស្អាត និងទទួលបានជ័យលាភី។
- **ជំពូកទី២ "យុទ្ធសាស្ត្រនៃខណ្ឌដូនពេញក្នុងការប្រឡងប្រណាំងទីក្រុងស្អាត"៖** នៅក្នុងជំពូកនេះនាងខ្ញុំនឹងបែងចែកជាបីចំណុចបន្ថែមទៀត ដោយចំណុចទី១ និយាយអំពីវិស័យសំខាន់ៗសម្រាប់ការអភិវឌ្ឍនិរន្តរភាពនៅក្នុងខណ្ឌ ចំណុចទី២ បង្ហាញអំពីរបៀបនៃការរៀបចំខណ្ឌដូនពេញនាពេលបច្ចុប្បន្ន និងចំណុចទី៣ គម្រោងការអភិវឌ្ឍខណ្ឌដូនពេញនាពេលអនាគត។

# ជំពូកទី១
# ការរៀបចំប្រឡងប្រណាំងទីក្រុងស្អាត

# ជំពូកទី១
# ការរៀបចំប្រឡងប្រណាំងទីក្រុងស្អាត

## ១.១. ទិដ្ឋភាពទូទៅ

អស់កាលកន្លងទៅហើយក្នុង (គ.ស ១៣៧២) មានដូនចាស់ម្នាក់ឈ្មោះ "ពេញ" ជាអ្នកមានទ្រព្យសម្បត្តិបរិបូរណ៍មានលំនៅក្បែរច្រាំងទន្លេបួនមុខ។ ផ្ទះរបស់គាត់សង់នៅលើទួលខាងកើតភ្នំតូចមួយ។ ថ្ងៃមួយនៅទីនោះមានភ្លៀងធ្លាក់ខ្លាំងទឹកទន្លេជន់លិច ស្រាប់តែពេលនោះដែលដូនពេញបានចុះទៅកំពង់ទឹក ក៏បានឃើញ ដើមគគីរមួយធំអណ្តែតមកក្បែរច្រាំង ហើយដោយអំណាចទឹកហូរចុះឡើង ដើមគគីរនោះចេះតែអណ្តែតវិលវល់នៅក្បែរច្រាំងនោះ។

លុះដូនពេញឃើញដូច្នេះ ក៏ប្រញាប់ទៅអំពាវនាវហៅអ្នកជិតខាង ឱ្យមកជួយទាញយកដើមគគីរនោះ។ អ្នកជិតខាងបាននាំគ្នាយកពួរទៅចង ហើយអូសរំកិលបន្តិចម្តងៗទាល់តែមកដល់មាត់ច្រាំង។ ពេលនោះដូនពេញយកកំណាត់ឈើទៅ កោសកៀរសំអាតភក់ចេញ គាត់ក៏បានឃើញក្នុងប្រហោងឈើគគីរមានព្រះពុទ្ធរូប ៤អង្គ តូចៗធ្វើអំពីសំរឹទ្ធិ និងទេវរូប មួយអង្គទៀតធ្វើអំពីថ្ម។ ទេវរូបនោះ ទ្រង់ឈរ ព្រះហស្តម្ខាងទ្រង់កាន់ដំបង ព្រះហស្តម្ខាងទៀតទ្រង់កាន់ស័ង្ខ ព្រះកេសាបួង។

ដូនពេញ និងអ្នកជិតខាងដែលទៅជួយមានសេចក្តីត្រេកអរណាស់ ដោយរើសបានរបស់ជាទីគោរព ក៏នាំគ្នាដង្ហែព្រះបដិមាករទាំងនោះមកដល់ផ្ទះដូនពេញ ហើយដូនពេញចាត់ការសង់ខ្ទមមួយតូចតម្កល់ជាបណ្តោះអាសន្ន។

ថ្ងៃក្រោយមក ដូនពេញអំពាវនាវឱ្យអ្នកជិតខាងជួយលើកដីពូនភ្នំ ដែលនៅខាងលិចផ្ទះរបស់គាត់នោះឱ្យទៅជាភ្នំពិតប្រាកដ។ បន្ទាប់ពីនោះគាត់ឱ្យគេអារឈើគគីរនោះធ្វើជាសសរវិហារដែលគាត់បម្រុងសង់លើភ្នំនោះ។ ក្នុង គ.ស ១៣៧២ ដូនពេញ និងអ្នកស្រុកជាច្រើននាក់ ស្រុះស្រួលបបួលគ្នាសាងសង់ព្រះវិហារ មួយខ្ទងប្រក់ស្បូវភ្លាំងនៅលើកំពូលភ្នំនោះ ហើយគាត់នាំគ្នាដង្ហែព្រះពុទ្ធរូបសំរឹទ្ធិទាំង ៤អង្គ ទៅតម្កល់ទុកក្នុងវិហារនោះ។ ចំណែកទេវរូបថ្ម មួយអង្គគាត់ដង្ហែទៅតម្កល់ទុកលើអាសនៈមួយនៅជើងភ្នំខាងកើត ហើយដោយគាត់យល់ថាទេវរូបនោះ អណ្តែតទឹក មកពីស្រុកលាវ និងមានភាពដូចជាលាវ គាត់ក៏បានសន្មតនាមថា អ្នកតាព្រះចៅ នាមនោះជាប់ បន្ទាប់មកទីក្រុងមួយនេះក៏បានក្លាយឈ្មោះថា ភ្នំពេញរហូតដល់សព្វថ្ងៃ។ ចំណែកឯខណ្ឌដូនពេញត្រូវបានគេចាត់ទុកថាជាខណ្ឌមួយដ៏មានប្រជាប្រិយភាពបំផុត ហើយវាជាតំបន់ពាណិជ្ជកម្មធំបំផុតក្នុងទីក្រុងភ្នំពេញ។ វាបណ្តុំដោយស្ថាបត្យកម្មប្រណិតៗ ផ្សារ ហាងលក់ទំនិញជាច្រើនដែលផ្តល់នូវតម្រូវការជាច្រើនដូចជាអាហារ និងភេសជ្ជៈ ហើយ គឺជាខណ្ឌមួយដែលស្ថិតនៅជាប់ផ្លូវសំខាន់ៗនៅក្នុងរាជធានីភ្នំពេញ។ ខណ្ឌដូនពេញមានទីតាំងស្ថិតចំកណ្តាល និងជាបេះដូងនៃរាជធានីភ្នំពេញ ជាមជ្ឈមណ្ឌលប្រមូលផ្តុំលើ

គ្រប់វិស័យ ដែលរួមមានទាំងសន្តិសុខ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច បេតិកភណ្ឌវប្បធម៌ និងសំបូរទៅដោយរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ ព្រមទាំងប្រមូលផ្តុំទៅដោយស្ថាប័នជាតិធំៗ និងស្ថានទូតដែលមានផ្ទៃដីសរុបចំនួន៧,៤១km$^2$ ៤៤ហិតា ៥០អារ ៩សង់ត្យា ដែលមានព្រំប្រទល់ខាងត្បូងជាប់នឹងខណ្ឌចំការមន និងខណ្ឌបឹងកេងកង ខាងជើងជាប់ខណ្ឌឬស្សីកែវ ខាងលិចជាប់ខណ្ឌ៧មករា និងខណ្ឌទួលគោក ហើយខាងកើតជាប់ទន្លេសាប ចែកចេញជា១១សង្កាត់ ១៣៤ភូមិ ៩៥៣ក្រុម ក្នុងនោះរួមមានប្រជាពលរដ្ឋសរុបចំនួន ១៣.៨០៦គ្រួសារ។ មានមនុស្សចំនួន ៩៦.៨២៣នាក់ ស្រីចំនួន ៣៥.៨០៦នាក់ ដែលមានដង់ស៊ីតេប្រជាពលរដ្ឋចំនួន ៩.៣៧៨/km$^2$។

ខណ្ឌដូនពេញមាន ១១សង្កាត់ ដូចជា៖ សង្កាត់ស្រះចក សង្កាត់ផ្សារចាស់ សង្កាត់ផ្សារកណ្តាល១ សង្កាត់ផ្សារកណ្តាល២ សង្កាត់ជ័យជំនះ សង្កាត់ចតុមុខ សង្កាត់ផ្សារថ្មី១ សង្កាត់ផ្សារថ្មី២ សង្កាត់ផ្សារថ្មី៣ សង្កាត់បឹងរាំង ហើយនិងកន្លែងដែលយាយពេញដាក់ព្រះពុទ្ធរូបនោះគឺ សង្កាត់វត្តភ្នំ។

### ១.១.១. ប្រវត្តិនៃការរៀបចំទីក្រុងស្អាត

ចាប់តាំងពីដើមសតវត្សរ៍ទី២១ នេះមក ប្រទេសកម្ពុជាមានការអភិវឌ្ឍយ៉ាងខ្លាំងក្លាលើវិស័យទេសចរណ៍គួរឱ្យកត់សំគាល់។ ចំនួនភ្ញៀវទេសចរណ៍អន្តរជាតិមកទស្សនាកម្ពុជាមានសន្ទុះកើនឡើង ក្នុងអត្រាកំណើន ២ខ្ទង់ជាមធ្យមដោយលោតផ្លោះពី ៧០១.០១៤នាក់ នៅឆ្នាំ២០០៣ ដល់ ២.៥០៨.២៨៩នាក់ នៅឆ្នាំ២០១០។

អ្វីដែលគួរឱ្យកត់សំគាល់នោះ កំណើនភ្ញៀវទេសចរណ៍នៅកម្ពុជានៅតែមានសូម្បីក្នុងដំណាក់កាលវិបត្តិសេដ្ឋកិច្ចសកលលោកក៏ដោយ។ ជាការពិតណាស់ ភ្ញៀវទេសចរណ៍អន្តរជាតិសរុបនៅកម្ពុជាក្នុងឆ្នាំ២០០៩ នៅតែរក្សាបាននូវកំណើនក្នុងអត្រាប្រមាណ ១,៣០% ធៀបនឹងឆ្នាំ២០០៨ ខណៈពេលដែលវិស័យទេសចរណ៍សកលលោកមានការធ្លាក់ចុះ ៤%។

លទ្ធផលសម្រេចបានទាំងនេះ សុទ្ធសឹងជាមោទកភាពរបស់ប្រទេសជាតិក៏ដូចជាក្រសួងទេសចរណ៍ដែលបានខិតខំប្រឹងប្រែងអនុវត្តតាមគោលនយោបាយ និងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា។ យ៉ាងណាមិញ ក្រសួងទេសចរណ៍មានទស្សនវិស័យចង់សម្រេចឱ្យបាននូវសមិទ្ធផលធំៗ ០៣បន្ថែមទៀតរួមមាន៖

- រក្សាឱ្យបាននូវកំណើន ២ខ្ទង់ រៀងរាល់ឆ្នាំ
- ជំរុញការពិពិធកម្មផលិតផល និងតំបន់ទេសចរណ៍តាមរយៈការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍នានាឱ្យមានសន្ទុះខ្លាំងក្លាដូចករណីតំបន់អង្គរ
- បង្កើនរយៈពេលស្នាក់នៅរបស់ភ្ញៀវទេសចរណ៍ឱ្យកាន់តែយូរ។

ឆ្លើយតបជាមួយនេះ ការប្រឡងប្រណាំងទីក្រុងស្អាត ត្រូវបានផ្តួចផ្តើមគំនិតរៀបចំឡើង ហើយនឹងត្រូវ

អនុវត្តដោយយោងលើឯកសារស្តង់ដាមួយ ដែលត្រូវបានរៀបចំឡើងដោយផ្អែកលើសូចនាករសំខាន់ៗទាក់ទង នឹងហេដ្ឋារចនាសម្ព័ន្ធ នគរូបនីយកម្ម បរិស្ថាន ទេសចរណ៍ សេដ្ឋកិច្ច និងសង្គម។

មកដល់បច្ចុប្បន្ននេះ ការប្រឡងប្រណាំងទីក្រុងស្អាត បានរៀបចំការប្រឡងចំនួន ០២ដង ហើយក៏បាន ឆ្លងកាត់ការប្រឡងសាកល្បងចំនួន ១ម្តងដែរ។

### ១.១.២. និយមន័យ

ដើម្បីងាយស្រួលដល់ការកំណត់ន័យនៃអត្ថបទទាំងមូល គួរគប្បីកំណត់និយមន័យនៃពាក្យគន្លឹះដែល មាននៅក្នុងប្រធានបទជាមុនសិន ហើយពាក្យគន្លឹះទាំងនោះរួមមាន៖ ការប្រឡងប្រណាំង ទីក្រុង និងស្អាត។

**ការប្រឡងប្រណាំង៖** មានន័យថាជាការប្រកួតប្រជែងដណ្តើមយកឈ្នះគ្នា។

**ទីក្រុង៖** សំដៅដល់ទីកន្លែងមួយដែលមិនមានសកម្មភាពកសិកម្ម និងមានលក្ខណៈវិនិច្ឆ័យផ្សេងទៀត អាចរួមបញ្ចូលបាន គឺមានចំនួនប្រជាជន, ទីធ្លាទំនេរ។[1]

**ស្អាត៖** មានន័យថាបរិសុទ្ធ ទីស្អាត ចិត្តស្អាត ធ្វើការស្អាត ស្អាតស្អំ។[2]

ជាការពិតណាស់ ការប្រឡងប្រណាំងទីក្រុងស្អាត គឺបង្ហាញអំពីការរៀបចំទីក្រុងមួយឱ្យបានស្អាតត្រូវធ្វើ ឡើងដោយមានការប្រកួតប្រជែងដណ្តើមដើម្បីយកជ័យលាភី សម្រាប់ទីតាំងដែលយើងចង់អភិវឌ្ឍឆ្ពោះទៅកាន់ ភាពលិចធ្លោប្រកបដោយភាពច្បាស់លាស់ ហ្មត់ចត់គ្រប់ជ្រុងជ្រោយ និងទីក្រុងមួយដែលមានសក្តានុពលខ្ពស់ ផ្នែកបរិស្ថាន។

### ១.១.៣. បរិបទនៃមូលហេតុនាំឱ្យមានការរៀបចំទីក្រុងស្អាត

#### ក. គោលបំណង

ចលនាប្រឡងប្រណាំងទីក្រុងស្អាត រៀបចំឡើងក្នុងគោលបំណងលើកកម្ពស់សោភ័ណភាពបរិស្ថាន អនាម័យ និងសណ្តាប់ធ្នាប់ក្រុង-ខណ្ឌ (២៧ក្រុង - ១៤ខណ្ឌ) រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសចូលរួមក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍនានារបស់រាជរដ្ឋាភិបាល។ ដើម្បីជាការលើក ទឹកចិត្ត រាជរដ្ឋាភិបាលនឹងផ្តល់រង្វាន់ដល់ក្រុង-ខណ្ឌ ដែលបានខិតខំប្រឹងប្រែងក្នុងការរៀបចំ និងអភិវឌ្ឍ ក្រុង-ខណ្ឌរបស់ខ្លួន ពិសេសថែរក្សាការពារបរិស្ថាន និងបានជំរុញឱ្យតួអង្គសំខាន់ៗក្នុងវិស័យទេសចរណ៍ បង ប្អូនប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធបានចូលរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រង បរិស្ថាននៅតាមបណ្តា ក្រុង-ខណ្ឌ។[3] ការប្រឡងប្រណាំងនេះបានបញ្ជ្រាបការយល់ដឹង និងលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

[1] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១

[2] សម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ

[3] គេហទំព័រ www.cambodiacleancity.gov.kh (ចូលទស្សនាចុងក្រោយថ្ងៃទី៤ មីនា ២០២២)

និងប្រតិបត្តិទេសចរណ៍សំខាន់ៗដែលអនុវត្តសកម្មភាពរបស់ខ្លួននៅក្នុងទីក្រុង ឱ្យយកចិត្តទុកដាក់បន្ថែមទៀតទៅលើភាពស្អាត និងមជ្ឈដ្ឋានរស់នៅក្នុងទីក្រុង ដែលនឹងបានជាប្រយោជន៍ដល់សកម្មភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជន។ ទាំងនេះ គឺដើម្បីធ្វើឱ្យមានភាពប្រសើរឡើងនូវគុណភាពផលិតផល និងសេវាកម្ម ព្រមទាំងជួយលើកកម្ពស់សោភ័ណភាពទូទៅនៃទីក្រុងទាំងអស់ ដែលសុទ្ធសឹងជាកត្តាចម្បងចូលរួមចំណែកដល់ការអភិវឌ្ឍន៍វិស័យ ទេសចរណ៍តំបន់ទីក្រុង។

**ខ. ផលប្រយោជន៍ដែលចូលរួមការប្រឡងប្រណាំងទីក្រុងស្អាត**

គ្រប់បណ្ដាក្រុង-ខណ្ឌនៅក្នុងប្រទេសកម្ពុជាដែលបានចូលរួមប្រឡងប្រណាំងទីក្រុងស្អាត ដោយសារតែមានផលប្រយោជន៍ជាច្រើនសម្រាប់តំបន់សាមី ដូចជា៖

- ជួយលើកកម្ពស់ជីវភាព និងមជ្ឈដ្ឋានរស់នៅរបស់ប្រជាពលរដ្ឋនៅតាមបណ្ដាទីក្រុង
- ជួយពង្រឹង និងលើកកម្ពស់រូបភាពវិជ្ជមានរបស់ទីក្រុងនៅទូទាំងព្រះរាជណាចក្រកម្ពុជា ដោយទីក្រុងស្អាតជាឧបករណ៍ផ្សព្វផ្សាយ « សេវាកម្មបៃតង »
- ចូលរួមការពារ និងលើកកម្ពស់បរិស្ថាន
- ពង្រឹង និងអភិវឌ្ឍសេដ្ឋកិច្ចនៅតាមបណ្ដាទីក្រុងធ្វើឱ្យមានសមភាពក្នុងសង្គម ជាពិសេសការកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៍ដោយជំរុញ និងពង្រីកលំហូរភ្ញៀវទេសចរណ៍ទៅគ្រប់តំបន់នៃព្រះរាជាណាចក្រកម្ពុជា។[4]

## ១.២. ការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ដែលសរសេរអក្សរកាត់ថា **គ.ជ.វ.ទ.** បង្កើតឡើងដើម្បីវាយតម្លៃទីក្រុងស្អាត តាមរយៈការប្រឡងប្រណាំង ក្នុងគោលបំណងលើកកម្ពស់សោភ័ណភាព អនាម័យ បរិស្ថានល្អនៅតាមបណ្ដាទីក្រុង ពិសេសចូលរួមធ្វើឱ្យទីក្រុងនៃព្រះរាជាណាចក្រកម្ពុជា ក្លាយជាគោលដៅទេសចរណ៍ដែលទាក់ទាញ និងប្រកបដោយភាពកក់ក្ដៅ។

### ១.២.១. សមាសភាព

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត មានសមាសភាពដូចខាងក្រោម៖**

- សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា — ប្រធានកិត្តិយស
- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ — ប្រធាន

[4] គេហទំព័រ www.camboiacleancity.gov.kh ((ចូលទស្សនាចុងក្រោយថ្ងៃទី៥ មីនា ២០២២)

| | | |
|---|---|---|
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន | ០១ រូប | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |
| - ប្រធានគណៈកម្មការគ្រប់គ្រង អភិវឌ្ឍន៍ទេសចរណ៍រាជធានី ខេត្តទាំង២៤ | | សមាជិក |
| - អគ្គលេខាធិការគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត | | សមាជិកអចិន្ត្រៃយ៍។ |

សភាពជាក់ស្តែងរបស់ គ.ជ.វ.ទ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។[5]

### ១.២.២. តួនាទីភារកិច្ចរបស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

**គ.ជ.វ.ទ. មានតួនាទី និងភារកិច្ចដូចតទៅ៖**

- អនុវត្តយុទ្ធនាការអប់រំ និងផ្សព្វផ្សាយជាសាធារណៈ អំពីការប្រឡងប្រណាំងទីក្រុងស្អាត កំណត់ទម្រង់ និងបែបបទនៃការចុះឈ្មោះក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- រៀបចំ និងដាក់ឱ្យដំណើរការ ការប្រឡងប្រណាំងទីក្រុងស្អាត
- វាយតម្លៃទីក្រុងស្អាត ដោយផ្អែកលើស្តង់ដាទីក្រុងស្អាត ដែលជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ
- ចេញស្លាកសញ្ញាផ្លូវការឱ្យទីក្រុងដែលជាជ័យលាភី
- ពិនិត្យ និងតាមដាន ការអនុវត្តរបស់ទីក្រុងជ័យលាភី ក្រោយទទួលបានស្លាកសញ្ញាពី គ.ជ.វ.ទ.
- ផ្តល់អនុសាសន៍ និងណែនាំដល់ទីក្រុងបេក្ខភាព ដែលពុំទាន់បានឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យក្នុង ស្តង់ដាទីក្រុងស្អាត

[5] មាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត០៦១១/៦១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ មិថុនា ២០១១

- ដកហូតស្លាកសញ្ញាពីទីក្រុងជ័យលាភីទាំងឡាយណា ដែលបាត់បង់ឬមិនគោរពតាមលក្ខណៈវិនិច្ឆ័យនៃស្តង់ដាទីក្រុងស្អាត
- រៀបចំ និងធ្វើបច្ចុប្បន្នភាពលើសូចនាករ និងនីតិវិធីក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- ធ្វើសហការជាមួយនឹងក្រសួង ស្ថាប័ន ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួលការងារខាងលើឱ្យកាន់តែមានប្រសិទ្ធភាព
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។[6]

### ១.២.៣. រចនាសម្ព័ន្ធ និងការគ្រប់គ្រង

ការប្រព្រឹត្តទៅរបស់ គ.ជ.វ.ទ. គឺបើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។[7] ហើយ គ.ជ.វ.ទ. អាចអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំពិគ្រោះយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងក្របខណ្ឌការងាររបស់ខ្លួន។[8] បែបបទ និងនីតិវិធីការងាររបស់ គ.ជ.វ.ទ. ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.វ.ទ.។[9] គ.ជ.វ.ទ. អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ ឬអន្តរជាតិនានាមួយចំនួន តាមការចាំបាច់។[10] គ.ជ.វ.ទ. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលត្រូវមានទីតាំងស្ថិតនៅក្នុងក្រសួងទេសចរណ៍។[11] អគ្គលេខាធិការដ្ឋាននៃ គ.ជ.វ.ទ. ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរង មួយចំនួន តាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.វ.ទ. ត្រូវកំណត់ដោយអនុក្រឹត្យ។[12] គ.ជ.វ.ទ. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។[13]

អគ្គលេខាធិការដ្ឋាននៃ គ.ជ.វ.ទ. មានរចនាសម្ព័ន្ធដូចតទៅ៖

- ផ្នែកបច្ចេកទេសវាយតម្លៃទីក្រុងស្អាត
- ផ្នែកផែនការ បណ្តុះបណ្តាល និងនីតិកម្ម
- ផ្នែកសហប្រតិបត្តិការ និងការផ្សព្វផ្សាយ
- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ។

[6] មាត្រា៣ នៃព្រះរាជក្រឹត្យលេខ នស/រកត០៦១១/៦១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ មិថុនា ២០១១
[7] មាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត០៦១១/៦១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ មិថុនា ២០១១
[8] មាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត០៦១១/៦១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ មិថុនា ២០១១
[9] មាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត០៦១១/៦១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ មិថុនា ២០១១
[10] មាត្រា៧ នៃព្រះរាជក្រឹត្យលេខ នស/រកត០៦១១/៦១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ មិថុនា ២០១១
[11] មាត្រា៨ នៃព្រះរាជក្រឹត្យលេខ នស/រកត០៦១១/៦១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ មិថុនា ២០១១
[12] មាត្រា៩ នៃព្រះរាជក្រឹត្យលេខ នស/រកត០៦១១/៦១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ មិថុនា ២០១១
[13] មាត្រា១០ នៃព្រះរាជក្រឹត្យលេខ នស/រកត០៦១១/៦១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ មិថុនា ២០១១

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.វ.ទ. ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។[14]

**ក. ផ្នែកបច្ចេកទេសវាយតម្លៃទីក្រុងស្អាត មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- គ្រប់គ្រង និងអនុវត្តនីតិវិធីចុះឈ្មោះចូលរួមការប្រឡងប្រណាំងទីក្រុងស្អាត
- ចុះពិនិត្យដល់ទីតាំងជាក់ស្តែង និងផ្ទៀងផ្ទាត់ឯកសារដែលទីក្រុងបេក្ខភាពនីមួយៗបានផ្តល់ជូន
- ធ្វើការវាយតម្លៃបឋមទីក្រុងបេក្ខភាពយោងតាមឯកសារនានាដែលអនុម័តដោយ គ.ជ.វ.ទ
- ពិនិត្យ និងលើកសំណើដោះស្រាយទៅថ្នាក់ដឹកនាំ តាមឋានានុក្រមនូវរាល់ករណីមិនប្រក្រតីនៃការអនុវត្តរបស់ទីក្រុងជ័យលាភី
- ផ្តល់យោបល់ និងធ្វើការណែនាំអំពីការអនុវត្តល្អៗដល់ទីក្រុងបេក្ខភាពទាំងឡាយ
- ប្រមូល និងវិភាគទិន្នន័យពាក់ព័ន្ធនឹងការវាយតម្លៃទីក្រុងស្អាត
- សិក្សាស្រាវជ្រាវ និងចងក្រងឯកសារដែលពាក់ព័ន្ធនឹងការងារវាយតម្លៃទីក្រុងស្អាត
- រៀបចំប្រព័ន្ធគ្រប់គ្រង និងបញ្ចូលទិន្នន័យ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូនអគ្គលេខាធិការ គ.ជ.វ.ទ
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ គ.ជ.វ.ទ.។[15]

**ខ. ផ្នែកផែនការ បណ្តុះបណ្តាល និងនីតិកម្ម មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- ប្រមូល រៀបចំ គ្រប់គ្រង និងវិភាគទិន្នន័យលទ្ធផលការងារដែលទទួលបានពីគ្រប់អង្គភាពពាក់ព័ន្ធ ដើម្បីកំណត់ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីអភិវឌ្ឍន៍ ការងារប្រឡងប្រណាំងទីក្រុងស្អាត
- ធ្វើសហការរៀបចំ និងវាយតម្លៃតម្រូវការសម្រាប់ការបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.វ.ទ. និងគ្រប់ភាគីពាក់ព័ន្ធក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- ធ្វើសហការរៀបចំកម្មវិធីបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រីអគ្គលេខាធិការដ្ឋាននៃ គ.ជ.វ.ទ. និងគ្រប់ភាគីពាក់ព័ន្ធក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- រៀបចំ អង្កេត និងវាយតម្លៃការអនុវត្តផែនការ និងគម្រោងអភិវឌ្ឍន៍ប្រឡងប្រណាំងទីក្រុងស្អាតដើម្បីជូនយោបល់ប្រធាន គ.ជ.វ.ទ តាមរយៈអគ្គលេខាធិកានៃ គ.ជ.វ.ទ។

[14] មាត្រា៤ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់អគ្គលេខាធិកាដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី១៦ កុម្ភ ២០១២

[15] មាត្រា៨ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់អគ្គលេខាធិកាដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី១៦ កុម្ភ ២០១២

- សិក្សាស្រាវជ្រាវឯកសារច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋាននានា ពាក់ព័ន្ធនឹងចលនាប្រឡងប្រណាំងទីក្រុងស្អាត
- រៀបចំកសាងច្បាប់ និងលិខិតបទដ្ឋាននានា ដើម្បីគ្រប់គ្រងការងារពាក់ព័ន្ធនឹងចលនាប្រឡងប្រណាំងទីក្រុងស្អាត ដោយធ្វើសហការជាមួយអង្គភាពជំនាញ និងក្រសួងស្ថាប័នពាក់ព័ន្ធ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូនអគ្គលេខាធិការនៃ គ.ជ.វ.ទ.
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការ គ.ជ.វ.ទ.។[16]

**គ. ផ្នែកសហប្រតិបត្តិការ និងផ្សព្វផ្សាយ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- រៀបចំគម្រោងសហប្រតិបត្តិការជាមួយអង្គការ សមាគមជាតិនិងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ
- សម្របសម្រួល និងធ្វើទំនាក់ទំនងកិច្ចសហប្រតិបត្តិការ ជាមួយប្រទេសសមាជិកអាស៊ានលើរាល់សកម្មភាពដែលទាក់ទងនឹងចលនាទីក្រុងស្អាត
- តាមដាននិងវាយតម្លៃលើរាល់សកម្មភាព ដែលមានចែងក្នុងកំណត់ហេតុអនុស្សរណៈនៃការឯកភាពយល់គ្នា ពិធីសារ និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ជូនថ្នាក់ដឹកនាំពិនិត្យ ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌចលនាប្រឡងប្រណាំងទីក្រុងស្អាត
- ជំរុញការចូលរួមពីសាធារណជន និងគ្រប់ភាគីពាក់ព័ន្ធក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត
- សហការរៀបចំកម្មវិធីអប់រំ និងនាទីផ្សព្វផ្សាយចលនាប្រឡងប្រណាំងទីក្រុងស្អាត
- បង្កើត គ្រប់គ្រងរចនា និងធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់ គ.ជ.វ.ទ.
- ពិនិត្យ រៀបចំ និងចងក្រងគ្រប់ឯកសារផ្សព្វផ្សាយអំពីចលនាប្រឡងប្រណាំងទីក្រុងស្អាត និងអំពីសកម្មភាពរបស់ គ.ជ.វ.ទ.
- សហការជាមួយផ្នែកជំនាញពាក់ព័ន្ធ ដើម្បីសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារស្តីពីការអនុវត្តផ្សេងៗដែលបានផ្សារភ្ជាប់នឹងចលនាប្រឡងប្រណាំងទីក្រុងស្អាត
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូនអគ្គលេខាធិការនៃ គ.ជ.វ.ទ.
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ គ.ជ.វ.ទ.។[17]

[16] មាត្រា៩ នៃអនុក្រឹត្យលេខ២៧.អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់អគ្គលេខាធិកាដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី១៦ កុម្ភ ២០១២

[17] មាត្រា១០ នៃអនុក្រឹត្យលេខ២៧.អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់អគ្គលេខាធិកាដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី១៦ កុម្ភ ២០១២

**ឃ. ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ចដូចតទៅ៖**

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែក និងក្រុមការងាររបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.វ.ទ.**
- គ្រប់គ្រង ចាត់ចែង និងចារចរឯកសាររដ្ឋបាលរបស់ **គ.ជ.វ.ទ.**
- ធានាប្រសិទ្ធភាព សុវត្ថិភាព និងគ្រប់គ្រងការងាររដ្ឋបាល
- ទទួលបន្ទុករៀបចំសន្និបាត កិច្ចប្រជុំ សិក្ខាសាលា និងពិធីការនានា ព្រមទាំងធ្វើរបាយការណ៍ឬកំណត់ហេតុ
- គ្រប់គ្រងចំណូល ចំណាយ និងលើកគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ.ជ.វ.ទ**
- គ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិកក្នុងអគ្គលេខាធិការដ្ឋាននៃ **គ.ជ.វ.ទ.**
- បូកសរុប និងធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.វ.ទ**
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូនអគ្គលេខាធិការនៃ **គ.ជ.វ.ទ.**
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ជ.វ.ទ.**។[18]

### ១.២.៤. អាណត្តិនៃការប្រឡងប្រណាំងទីក្រុងស្អាត

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤/ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១ ត្រូវទុកជានិរាករណ៍។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យលេខ ២៧.អនក្រ.បក ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់អគ្គលេខាធិកាដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ត្រូវទុកជានិរាករណ៍។ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធាន គ.ជ.វ.ទ. រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈរដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានាថ្ងៃនេះតទៅ។

ការប្រឡងប្រណាំងទីក្រុងស្អាត មានរយៈពេល បីឆ្នាំម្តង។ បេក្ខភាពដែលចូលរួមប្រឡងត្រូវតែគោរពទៅតាមវិញ្ញាសាដែរគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតដាក់ជូន។

[18] មាត្រា១១ នៃអនុក្រឹត្យលេខ២៧.អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់អគ្គលេខាធិកាដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី១៦ កុម្ភ ២០១២

## ១.៣. លក្ខន្តិកៈនៃការចូលរួមប្រឡងប្រណាំងទីក្រុងស្អាត

### ១.៣.១. នីតិវិធីនៃការប្រឡងប្រណាំង

ក្រុងខណ្ឌបេក្ខភាពទាំងអស់មានរយៈពេល ៣០ថ្ងៃ ក្នុងការទទួលដាក់ពាក្យសុំ និងបំពេញឯកសារចូលរួមប្រឡងប្រណាំងចាប់ពីថ្ងៃប្រកាសផ្សព្វផ្សាយជាផ្លូវការនៃការប្រឡងប្រណាំងទីក្រុងស្អាតដោយ គ.ជ.វ.ទ.។

ក្រោយពីទទួលបានឯកសារបំពេញដោយក្រុង-ខណ្ឌបេក្ខភាព គ.ជ.វ.ទ. មានរយៈពេល ០៧ (ប្រាំពីរ)ខែ ក្នុងការពិនិត្យ និងវាយតម្លៃជាលើកចុងក្រោយ មុននឹងបញ្ចូលខណ្ឌបេក្ខភាពណាមួយ។ ក្រោយទទួលបាននូវវិញ្ញាបនបត្រទទួលស្គាល់ដោយនាយករដ្ឋមន្ត្រី គ.ជ.វ.ទ. នឹងរៀបចំពិធីប្រគល់រង្វាន់ និងស្លាកសញ្ញាជាផ្លូវការដល់ក្រុង-ខណ្ឌដែលទទួលបានជ័យលាភី។[19]

គ.ជ.វ.ទ. នឹងធ្វើការរៀបចំការប្រឡងប្រណាំងទីក្រុងស្អាតជារៀងរាល់ ០៣ (បី)ឆ្នាំម្តង ដោយមានការចូលរួមពីក្រុង-ខណ្ឌ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា (ក្រុង-ខណ្ឌទាំងអស់ត្រូវចូលរួមការប្រឡងប្រណាំងដោយកាតព្វកិច្ច) ដែលមានឈ្មោះដូចខាងក្រោម៖

- **ក្រុងតាមបណ្តាខេត្តមានចំនួន ២៧ ក្រុង-ខណ្ឌ**

១. ក្រុងកំពង់ចាម
២. ក្រុងសួង
៣. ក្រុងតាខ្មៅ
៤. ក្រុងបាត់ដំបង
៥. ក្រុងព្រៃវែង
៦. ក្រុងសៀមរាប
៧. ក្រុងប៉ោយប៉ែត
៨. ក្រុងសេរីសោភណ្ឌ
៩. ក្រុងដូនកែវ
១០. ក្រុងច្បារមន
១១. ក្រុងស្ទឹងសែន
១២. ក្រុងកំពង់ឆ្នាំង
១៣. ក្រុងកំពត
១៤. ក្រុងស្វាយរៀង
១៥. ក្រុងបាវិត
១៦. ក្រុងពោធិ៍សាត់
១៧. ក្រុងខេមរភូមិន្ទ
១៨. ក្រុងក្រចេះ
១៩. ក្រុងព្រះសីហនុ
២០. ក្រុងបានលុង
២១. ក្រុងព្រះវិហារ
២២. ក្រុងស្ទឹងត្រែង
២៣. ក្រុងសំរោង
២៤. ក្រុងសែនមនោរម្យ
២៥. ក្រុងប៉ៃលិន
២៦. ក្រុងកែប
២៧. ក្រុងកោះរ៉ុង។

- **ខណ្ឌនៅក្នុងរាជធានីមានចំនួន ១៤ខណ្ឌ**

១. ខណ្ឌ៧មករា
២. ខណ្ឌចំការមន
៣. ខណ្ឌដង្កោ
៤. ខណ្ឌដូនពេញ
៨. ខណ្ឌឬស្សីកែវ
៩. ខណ្ឌពោធិ៍សែនជ័យ
១០. ខណ្ឌជ្រោយចង្វារ
១១. ខណ្ឌច្បារអំពៅ

[19] គេហទំព័រ www.cambodiacleancity.gov.kh (ចូលទស្សនាចុងក្រោយថ្ងៃទី៨ មីនា ២០២២)

៥. ខណ្ឌទួលគោក ១២. ខណ្ឌព្រែកព្នៅ

៦. ខណ្ឌមានជ័យ ១៣. ខណ្ឌកំបូល

៧. ខណ្ឌសែនសុខ ១៤. ខណ្ឌបឹងកេងកង។

**សំគាល់** ក្រុង-ខណ្ឌបេក្ខភាពអាចទទួលបានពាក្យសុំចូលរួមការប្រឡងប្រណាំងពី **គ.ជ.វ.ទ**។ **គ.ជ.វ.ទ** នឹងធ្វើការពិនិត្យលើពាក្យសុំចូលរួមរបស់ក្រុង-ខណ្ឌបេក្ខភាព និងឯកសារពាក់ព័ន្ធនានា ដែលភ្ជាប់មកជាមួយ ( គ.ជ.វ.ទ.) រក្សាសិទ្ធិក្នុងការស្នើសុំឯកសារពាក់ព័ន្ធបន្ថែម។[20]

### ១.៣.២. កាលបរិច្ឆេទ និងទទួលពាក្យ

**ការប្រឡងដែលបានរៀបចំរួចរាល់៖**

- ការប្រឡងសាកល្បងនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២-២០១៥។
- ការប្រឡងជាក់ស្តែងលើកទី១ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥-២០១៨។
- ការប្រឡងជាក់ស្តែងលើកទី២ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៨-២០២១។

**យោងទៅតាមឯកសារបានកំណត់យកកាលបរិច្ឆេទក្នុងការប្រឡងជាក់ស្តែងលើកទី៣៖**

ថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ កាលបរិច្ឆេទផ្តល់ និងទទួលពាក្យសុំចូលរួមការប្រឡងប្រណាំងទីក្រុងស្អាតលើកទី៣ តាមប្រព័ន្ធអនឡាញ។

ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២២ កាលបរិច្ឆេទក្នុងការពិនិត្យលើឯកសារ និងទីតាំង និងការវាយតម្លៃជាលើកចុងក្រោយរបស់ គ.ជ.វ.ទ។

ថ្ងៃទី១៦ ខែមករា ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ កាលបរិច្ឆេទនៃការពិនិត្យបូកសរុបពិន្ទុនៃការប្រឡងប្រណាំងទីក្រុងស្អាតលើកទី៣។

ការប្រកាសលទ្ធផលផ្លូវការ ក្នុងខែតុលា ឆ្នា២០២២។ ការប្រគល់ជ័យលាភីទីក្រុងស្អាតលើកទី៣ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣។ ក្នុងឱកាសទិវាជាតិទីក្រុងស្អាត។

### ១.៣.៣. សូចនាករ និងលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃ

សូចនាករ និងលក្ខណៈវិនិច្ឆ័យនៃស្តង់ដាទីក្រុងស្អាត ត្រូវកែសម្រួលចាំបាច់ និងការវិវត្តជាក់ស្តែងនៃចលនាប្រឡងប្រណាំងទីក្រុងស្អាតនៅកម្ពុជា។ ចំណែកឯអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននាយកដ្ឋានវាយតម្លៃទីក្រុងស្អាត ប្រធានក្រុមការងារវាយតម្លៃទីក្រុងស្អាតថ្នាក់រាជធានី ខេត្ត និងក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តតាមសេចក្តីសម្រេច ០០២

[20] គេហទំព័រ www.cambodiacleancity.gov.kh (ចូលទស្សនាចុងក្រោយថ្ងៃទី៩ មីនា ២០២២)

សសរ.គជវទ ចុះថ្ងៃចន្ទ ៦រោច ខែបុស្ស ឆ្នាំជូតទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ មូលដ្ឋាននៃការវាយតម្លៃផ្អែកលើសូចនាករគោលសំខាន់ៗមានចំនួន ០៧ (ប្រាំពីរ)។

បន្ទាប់ពីបានកែសម្រួលសូចនាករ និងលក្ខណៈវិនិច្ឆ័យស្តង់ដាទីក្រុងស្អាតបច្ចុប្បន្ន មានចំនួន ០៧ សូចនាករគោល ៤១ សូចនាករលម្អិត និង១១៣ លក្ខណៈវិនិច្ឆ័យ (ស្មើនឹង ១២០ ពិន្ទុ)។[21]

## ១. សូចនាករគោលនៃការរៀបចំ និងគ្រប់គ្រងបរិស្ថាន

| សូចនាករគោលនៃការរៀបចំ និងគ្រប់គ្រងបរិស្ថាន | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ៤-E4 សូចនាករលម្អិតនៃគុណភាពខ្យល់ | វិធានការដែលទាក់ទងនឹងបរិស្ថានគ្មានផ្សែងបារី | មាន មិនមាន- | ១ |
| **- ចំនួនសូចនាករលម្អិត៖ ១**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ១** | | សរុប | ១ |

## ២. សូចនាករគោលនៃភាពស្អាត

| សូចនាករគោលនៃភាពស្អាត | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ៩-P1 សូចនាករលម្អិតនៃភាពស្អាតនៅទីកន្លែងសាធារណៈ | ភាពស្អាតនៅតាមសាលារៀន | មាន-មិនមាន | ១ |
| | ភាពស្អាតនៅតាមវត្តអារាម | មាន-មិនមាន | ១ |
| | ភាពស្អាតនៅតាមផ្សារ | មាន-មិនមាន | ១ |
| | ភាពស្អាតនៅតាមរោងចក្រ | មាន-មិនមាន | ១ |

[21] ឧបសម្ព័ន្ធស្តីពីការកែសម្រួលសូចនាករ និងលក្ខណៈវិនិច្ឆ័យនៃស្តង់ដាទីក្រុងស្អាតនៃសេចក្តីសម្រេចលេខ ០០២ សសរ.គជវទ ចុះថ្ងៃទី០៤ មករា ២០២១

| | | | |
|---|---|---|---|
| ១០-P2 សូចនាករលម្អិតនៃភាពស្អាតនៅតាមបង្គន់សាធារណៈ | បង្គន់សាធារណៈទាំងនោះជាកម្មវត្ថុនៃការថែរក្សា និងសម្អាតយ៉ាងទៀងទាត់ | យ៉ាងហោចណាស់ ៤ដងក្នុង១ថ្ងៃ | ២ |
| ១១-P3 សូចនាករលម្អិតនៃភាពស្អាតនៅតាមគោលដៅទេសចរណ៍ និងសម្បទាទេសចរណ៍ (សារមន្ទីរ ប្រាសាទ សួនកំសាន្ត ឆ្នេរ) | មានបង្គន់សាធារណៈនៅតាមគោលដៅទេសចរណ៍ (រមណីយដ្ឋាន និងសម្បទាទេសចរណ៍) | យ៉ាងហោចណាស់ ៥០% | ១ |
| | ភាគរយនៃភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ដែលបានចូលរួមអនុវត្តយុទ្ធនាការ «ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ស្អាត» | មាន-មិនមាន | ២ |
| **- ចំនួនសូចនាករលម្អិត៖ ៣**<br>**- ចំនួនលក្ខណៈវិនិច្ឆយ៖ ៧** | | សរុប | ៩ |

## ៣. សូចនាករគោលនៃការគ្រប់គ្រងសំណល់

| សូចនាករគោលនៃការគ្រប់គ្រង់សំណល់ | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១៨-D4 សូចនាករលម្អិតនៃការស្តុក និងការធ្វើប្រព្រឹត្តកម្មលើសំណល់រឹង | ទីកន្លែងកែច្នៃសំណល់រឹង ដោយរដ្ឋ ឬឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល ។ ល។ | មាន-មិនមាន | ១ |
| ១៩-D5 សូចនាករលម្អិតនៃការបែងចែងសំណល់រឹង | ការបំពាក់ធុងសំរាមដែលមានបែងចែងប្រភេទសំរាម (ទីតាំងសាធារណៈ លំនៅឋានប្រជាពលរដ្ឋ ។ល។) | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| | រថយន្តប្រមូលសំរាមដែលមានការបែងចែងប្រភេទសំរាម | មាន-មិនមាន | ១ |
| **- ចំនួនសូចនាករលម្អិតៈ ២<br>- ចំនួនលក្ខណៈវិនិច្ឆ័យៈ ៣** | | សរុប | ៣ |

## ៤. សូចនាករគោល នៃការបញ្ជ្រាបការយល់ដឹង

| សូចនាករគោលនៃការបញ្ជ្រាបការយល់ដឹង | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ២៣-I4 សូចនាករលម្អិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់កម្មករ-កម្មការិនីរោងចក្រ ឬសហគ្រាស | សកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់កម្មករ កម្មការិនីរោងចក្រ ឬសហគ្រាស | មាន-មិនមាន | ១ |
| | តើសកម្មភាពបញ្ជ្រាបការយល់ដឹងទាំងនេះធ្វើឡើងញឹកញាប់ដែរឬទេ? | យ៉ាងហោច ២ដងក្នុង១ឆ្នាំ | ១ |
| | មធ្យោបាយផ្តល់ព័ត៌មានអំពីបរិស្ថាន (បដាព័ត៌មាន ខិតប័ណ្ណផ្សព្វផ្សាយ ។ល។) | មាន-មិនមាន | ១ |
| **- ចំនួនសូនាករលម្អិតៈ ១<br>- ចំនួនលក្ខណៈវិនិច្ឆ័យៈ ៣** | | សរុប | ៣ |

## ៥. សូចនាករគោលនៃតំបន់បៃតង នឹងខ្សែក្រវាត់បៃតង

| សូចនាករគោលនៃតំបន់បៃតង និងខ្សែក្រវាត់បៃតង | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ២៤-V1 សូចនាករលម្អិតនៃការបង្កើត និងបែងចែងតំបន់បៃតង | ភាគរយតំបន់បៃតងធៀបនឹងផ្ទៃក្រឡាទីក្រុងទាំងមូល | ធំជាង ៥% | ២ |
| | សួនទេសចរណ៍នៅក្នុងក្រុង-ខណ្ឌ ឬតំបន់ជុំវិញ | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| ២៥-V2 សូចនាករលម្អិតនៃការថែទាំ និងរៀបចំតំបន់បៃតង | ភាពញឹកញាប់ក្នុងការរៀបចំកម្មវិធីដាំដើមឈើ | យ៉ាងហោច ៤ដងក្នុង ១ឆ្នាំ | ១ |
| ២៧-V4 សូចនាករលម្អិតនៃការរៀបចំទីតាំងលក់ផលិតផលក្នុងស្រុក | ផ្សារ ឬផ្សាររាត្រី ឬហាងដែលលក់ផលិតផលក្នុងស្រុក | មាន-មិនមាន | ១ |
| | មានការតាំងពិព័រណ៍អំពីផលិតផលក្នុងស្រុក | យ៉ាងហោច ១ដងក្នុង ១ឆ្នាំ | ១ |
| ២៨-V5 សូចនាករលម្អិតនៃការបញ្ជ្រាបការយល់ដឹងអំពីការប្រើប្រាស់ផលិតផលក្នុងស្រុក | ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់ប្រតិបត្តិការទេសចរណ៍អំពីការប្រើប្រាស់ផលិតផលក្នុងស្រុក | យ៉ាងហោច ១ដងក្នុង ១ឆ្នាំ | ១ |
| | ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់សាធារណជនអំពីការប្រើប្រាស់ផលិតផលក្នុងស្រុក | យ៉ាងហោច ១ដងក្នុង ១ឆ្នាំ | ១ |
| | ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់ទេសចរជាតិ និងអន្តរជាតិពីការប្រើប្រាស់ផលិតផលក្នុងស្រុក | យ៉ាងហោច ១ដងក្នុង ១ឆ្នាំ | ១ |
| ២៩-V6 សូចនាករលម្អិតនៃការរៀបចំខ្សែក្រវាត់បៃតង | ដៃគូសហប្រតិបត្តិការ (ដូចជា អង្គការជាតិ អន្តរជាតិ រដ្ឋាភិបាល ផ្នែកឯកជន សហគមន៍មូលដ្ឋាន ។ល។) ក្នុងការរៀបចំខ្សែក្រវាត់បៃតងនៅតាមគោលដៅទេសចរណ៍ និងតំបន់ជុំវិញទីក្រុង | មាន-មិនមាន | ១ |
| | បណ្តាញអ្នកប្រមូលទិញ ឬអន្តរការីដើម្បីជំរុញឱ្យមានការប្រើប្រាស់ផលិតផលក្នុងស្រុក | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| | សហគមន៍ ឬសហគមន៍កសិកម្ម និងសិប្បកម្ម ដែលមានការផ្គត់ផ្គង់សម្រាប់វិស័យទេសចរណ៍ | មាន-មិនមាន | ១ |
| | ដៃគូសហប្រតិបត្តិការក្នុងការរៀបចំខ្សែទស្សនកិច្ចកសិ-ទេសចរណ៍នៅតាមគោលដៅតំបន់ជុំវិញទីក្រុង | មាន-មិនមាន | ១ |
| ៣០-V7 សូចនាករលម្អិតនៃការជំរុញការប្រើប្រាស់ និងផលិតផលិតផលក្នុងស្រុក | វិធានការជំរុញ និងលើកទឹកចិត្តដល់អ្នកប្រើប្រាស់ផលិតផលក្នុងស្រុក (ពិសេសសម្រាប់ប្រតិបត្តិការទេសចរណ៍) | មាន-មិនមាន | ១ |
| | វិធានការជំរុញនិងលើកទឹកចិត្តដល់អ្នកផលិតផលិតផលក្នុងស្រុកដែលផ្គត់ផ្គង់វិស័យ ទេសចរណ៍ | មាន-មិនមាន | ១ |
| - **ចំនួនសូចនាករលម្អិត៖ ៦**<br>- **ចំនួនលក្ខណៈវិនិច្ឆ័យ៖ ១៤** | | សរុប | ១៥ |

## ៦. សូចនាករគោលនៃសុវត្ថិភាពសុខភាពសាធារណៈ សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង

| សូចនាករគោលនៃសុវត្ថិភាពសុខភាពសាធារណៈសន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ៣២-S2 សូចនាករលម្អិតនៃសន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង | ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាក្នុងការរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងបរិស្ថាន | មាន-មិនមាន | ១ |
| | ការអនុវត្តវិធានការភូមិ -ឃុំ-សង្កាត់ មានសុវត្ថិភាព | មាន-មិនមាន | ២ |

| | | | |
|---|---|---|---|
| ៣៣-S3សូចនាករលម្អិតនៃសកម្មភាពបង្ការ និងទប់ស្កាត់អំពើល្មើស | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ដែលមានបណ្ណសរសើរពីក្រសួងមហាផ្ទៃ | យ៉ាងហោច ៥០% | ២ |
| ៣4-S4 សូចនាករលម្អិតនៃវិធានសុវត្ថិភាពទេសចរណ៍ | វត្តមានជំរុញវិធានសុវត្ថិភាពទេសចេណ៍នៅក្នុងក្រុង/ខណ្ឌ | មាន-មិនមាន | ១ |
| | ការប្រឡងប្រណាំងជំរុញការអនុវត្តវិធានសុវត្ថិភាព ទេសចរណ៍របស់បេក្ខភាព (ទទួលវិញ្ញាបនបត្រ) | មាន-មិនមាន | ១ |
| ៣៥-V5 សូចនាករលម្អិតនៃស្លាកយីហោអាជីវកម្មនៅក្នុងទីក្រុង | យន្តការនៃការរៀបចំ និងគ្រប់គ្រងស្លាកយីហោពាណិជ្ជកម្មប្រកបដោយសណ្តាប់ធ្នាប់ និងមានរបៀប | មាន-មិនមាន | ១ |
| | វិធានការជំរុញដល់អាជីវកម្មឱ្យគោរពទៅតាមបទដ្ឋាន និងការណែនាំរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃស្លាកយីហោអាជីវកម្ម | មាន-មិនមាន | ១ |
| | វិធានការទប់ស្កាត់ការដាក់តាំងស្លាកយីហោអាជីវកម្ម ឬស្លាកយីហោពាណិជ្ជកម្មអំពីគ្រឿងស្រវឹង និងថ្នាំជក់ នៅជិតសាលារៀន និងវត្តអារាម | យ៉ាងហោចចម្ងាយ៥០០ ម៉ែត្រពីសាលារៀន និងវត្តអារាម | ១ |
| **- ចំនួនសូចនាករលម្អិត៖ ៤**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ៨** | | សរុប | ១០ |

## ៧. សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍

| សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|

| | | | |
|---|---|---|---|
| ៣៦-T1 សូចនាករលម្អិតនៃហេដ្ឋារចនាសម្ព័ន្ធទីក្រុង | កំពង់ផែទេសចរណ៍ ឬចំណតរថយន្តទេសចរណ៍ដែលមាននៅក្នុងទីក្រុង | មាន-មិនមាន | ១ |
| ៣៧-T2 សូចនាករលម្អិតនៃប្លង់មេសម្រាប់ការអភិវឌ្ឍទេសចរណ៍ | តើមានផែនការមេ/ផែនការអភិវឌ្ឍទេសចរណ៍ដែរឬទេ? | មាន-មិនមាន | ២ |
| ៣៨-T3 សូចនារកលម្អិតនៃមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ | តើមានមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍នៅតាមតំបន់ទេសចរណ៍សំខាន់ៗគ្រប់គ្រាន់ដែរឬទេ? | គ្រប់គ្រាន់ មិនគ្រប់គ្រាន់ | ២ |
| | តើមានផែនទីទេសចរណ៍របស់ក្រុង/ខណ្ឌដែរឬទេ? | មាន-មិនមាន | ១ |
| | តើមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការផ្សព្វផ្សាយតំបន់ទេសចរណ៍ដែរឬទេ? | មាន-មិនមាន | ១ |
| ៤១-T6 សូចនាករលម្អិតនៃការរៀបចំវិថីលក់ម្ហូបអាហារ (Food Street) និងការពង្រឹងគុណភាពតូបលក់ម្ហូបអាហារ (Street Food) នៅតាមក្រុង/ខណ្ឌ និងទីប្រជុំជននានា | តើមានវិថីលក់ម្ហូបអាហារ (Food Street)នៅក្នុងទីក្រុងដែរឬទេ? | យ៉ាងហោច ១ | ១ |
| | ភាគរយតូបលក់ម្ហូបអាហារ (Food Street) ដែលមានលិខិតបញ្ជាក់អនាម័យពីក្រសួង ឬមន្ទីរសុខាភិបាល ឬស្ថាប័នពាក់ព័ន្ធ | យ៉ាងហោចណាស់ ៥០% | ១ |
| - **ចំនួនសូចនាករលម្អិត៖ ៤**<br>- **ចំនួនសូចនាករលម្អិត៖ ៧** | | **សរុប** | **៩** |

សូចនាករលម្អិតចំនួន ៤១ និងត្រូវបានដាក់ពិន្ទុតាមលក្ខណៈវិនិច្ឆ័យ ចំនួន ១១៣(ស្មើ នឹង ១២០ពិន្ទុ) សម្រាប់ធ្វើការវាយតម្លៃ និងសម្រេចផ្តល់ជ័យលាភីជូនក្រុង-ខណ្ឌបេក្ខភាព។

ការប្រើប្រាស់តារាងវាយតម្លៃ គឺផ្អែកលើការប្រៀបធៀបរវាងលក្ខណៈវិនិច្ឆ័យខុសៗគ្នានៃការប្រណាំងទីក្រុង

ស្អាត ដែលបានរៀបរាប់ខាងលើ។

ការវាយតម្លៃ គឺជាគោលទុកសម្រាប់ធ្វើការវាស់វែងអំពីកម្រិតរបស់លក្ខណៈវិនិច្ឆ័យរបស់ទីក្រុងនីមួយៗ ថាតើលក្ខណវិនិច្ឆ័យទាំងនោះបានបំពេញលក្ខខណ្ឌនៃការប្រឡងប្រណាំងដែរឬទេ។

តារាងវាយតម្លៃនឹងអនុញ្ញាតឱ្យធ្វើចំណាត់ថ្នាក់នៃទីក្រុង-ខណ្ឌជ័យលាភី ទៅតាមកម្រិតពិន្ទុដែលទទួលបាន។ ស្លាកសញ្ញា (Logo)៣ ប្រភេទនឹងត្រូវផ្តល់ជូនជាអនុគមន៍ទៅនឹងចំនួនពិន្ទុដែលទទួលបាន។ ប្រភេទនៃស្លាកសញ្ញា(Logo) ឬរង្វាន់ នឹងត្រូវកំណត់ដោយ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។

### ១.៣.៤. សុពលភាព និងកម្រិតពានរង្វាន់ និងស្លាកសញ្ញាសម្រាប់ទីក្រុងជ័យលាភី

ក្រុង-ខណ្ឌបេក្ខភាពដែលបំពេញ បានតាមសូចនាករ និងលក្ខណៈវិនិច្ឆ័យ ដែលបានចែងក្នុងស្តង់ដាទីក្រុងស្អាតនិងទទួលពានរង្វាន់ និងស្លាកសញ្ញាទីក្រុងស្អាត ដែលមានឡាបិលរូបផ្កាវំដួលសម្រាប់រយៈពេល ០៣ (បី)ឆ្នាំ។ ក្រុង-ខណ្ឌបេក្ខភាព ដែលទទួលបានជ័យលាភីទៅលើការប្រឡងប្រណាំង នឹងទទួលបានឡាបិលទីក្រុងស្អាត ដែលទទួលស្គាល់ពីគុណភាព និងការយកចិត្តទុកដាក់ដល់បរិស្ថាន ភាពស្អាត និងមជ្ឈដ្ឋានរស់នៅប្រកបទៅដោយភាពទាក់ទាញ និងផ្តល់ភាពកក់ក្តៅដល់ ប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍។ ពានរង្វាន់ និងស្លាកសញ្ញាទីក្រុងស្អាត ដែលនឹងទទួលបានជាអនុគមន៍នឹងពិន្ទុ ដូចខាងក្រោម៖[22]

- **ឡាបិលរូបផ្កាវំដួល ៣ទង**

ឡាបិលរូបផ្កាវំដួល ០៣ ទង ត្រូវប្រគល់ជូនក្រុង-ខណ្ឌ ដែលបានពិន្ទុចន្លោះពី ៩០ និង ១២០ នៃលក្ខណៈវិនិច្ឆ័យ (យ៉ាងហោចណាស់ស្មើនឹង ៧៥% នៃពិន្ទុសរុប)។

- **ឡាបិលរូបផ្កាវំដួល ២ទង**

ឡាបិលរូបផ្កាវំដួល ០២ទង ត្រូវប្រគល់ជូន ក្រុង-ខណ្ឌ ដែលបានពិន្ទុចន្លោះពី ៧២ និង ៨៩ នៃលក្ខណៈវិនិច្ឆ័យ (យ៉ាងហោចណាស់ស្មើនឹង ៦០% នៃពិន្ទុសរុប)។

- **ឡាបិលរូបផ្កាវំដួល ១ទង**

ឡាបិលរូបផ្កាវំដួល ០១ទង ត្រូវប្រគល់ជូន ក្រុង-ខណ្ឌ ដែលបានពិន្ទុចន្លោះពី ៤៨ និង ៧១ នៃលក្ខណៈវិនិច្ឆ័យ (យ៉ាងហោចណាស់ស្មើនឹង ៤០% នៃពិន្ទុសរុប)។

### ១.៣.៥. ការផ្លាស់ប្តូ ឬដកហូតឡាបិលទីក្រុងស្អាត

**គ.ជ.វ.ទ.** មានសិទ្ធិធ្វើការស្នើសុំទៅរាជរដ្ឋាភិបាលដើម្បីធ្វើការផ្លាស់ប្តូរ ឬដកហូតឡាបិលទីក្រុងស្អាតភ្លាមៗពីក្រុង-ខណ្ឌជ័យលាភី ឬក្នុងរយៈពេលកំណត់ណាមួយ ដោយធ្វើការជូនដំណឹងជាមុន។

[22] គេហទំព័រ www.cambodiacleancity.gov.kh (ចូលទស្សនាថ្ងៃទី១០ មីនា ២០២២)

ការផ្លាស់ប្តូរ ឬការដកហូតឡាបិល ទីក្រុងស្អាតធ្វើឡើងដោយផ្អែកលើភាពមិនប្រក្រតី ដែលនាំឱ្យមានការប៉ះពាល់ដល់លក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងស្តង់ដាទីក្រុងស្អាត។

**គ.ជ.វ.ទ.** នឹងធ្វើការជូនដំណឹងដល់ក្រុង-ខណ្ឌជ័យលាភីនៅពេលដែល **គ.ជ.វ.ទ.** ពិនិត្យឃើញលក្ខណៈវិនិច្ឆ័យ ដែលធ្លាប់បំពេញមានការប្រែប្រួលនឹងផ្ទុយពីការកំណត់ក្នុងទីក្រុងស្អាត។

ក្រោយទទួលបានសេចក្តីជូនដំណឹង ពី **គ.ជ.វ.ទ.** ក្រុង-ខណ្ឌជ័យលាភីត្រូវ រៀបចំវិធានការជាបន្ទាន់ក្នុងការកែលម្អ។ ករណីមិនអនុវត្តតាម **គ.ជ.វ.ទ.** នឹងធ្វើការស្នើសុំទៅរាជរដ្ឋាភិបាលដើម្បីផ្លាស់ប្តូរ ឬដកហូតឡាបិលទីក្រុងស្អាតពីក្រុង-ខណ្ឌទាំងនោះ។

# ជំពូកទី២
# យុទ្ធសាស្ត្រនៃខណ្ឌដូនពេញក្នុង
# ការប្រឡងប្រណាំងទីក្រុងស្អាត

# ជំពូកទី២

# យុទ្ធសាស្ត្រនៃខណ្ឌដូនពេញក្នុងការប្រឡងប្រណាំងទីក្រុងស្អាត

## ២.១. វិស័យសំខាន់ៗសម្រាប់ការអភិវឌ្ឍនិរន្តរភាពនៅក្នុងខណ្ឌ

### ២.១.១. ការរៀបចំផែនការអភិវឌ្ឍខណ្ឌ

ខណ្ឌដូនពេញ ជាខណ្ឌមួយមានទីតាំងស្ថិតនៅចំកណ្ដាល និងជាបេះដូងនៃរាជធានីភ្នំពេញដែលមានព្រំប្រទល់ជាប់ខណ្ឌសំខាន់ៗ និងអ័ក្សទន្លេសាបទៀតផង។ ហេតុដូចនេះ ជាផ្នែកមួយជំរុញឱ្យមានការរៀបចំកិច្ចដំណើរការអភិវឌ្ឍខណ្ឌឱ្យកាន់តែប្រសើរលើសមុនទៀត។

កិច្ចដំណើរការអភិវឌ្ឍមូលដ្ឋានខណ្ឌដូនពេញ ទាមទារការចូលរួមសហការលើគ្រប់វិស័យពីសំណាក់គ្រប់ស្ថាប័នជាតិ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ទាំងអស់ទៀត ដើម្បីឱ្យការរៀបចំផែនការអភិវឌ្ឍ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២១-២០២៣) ពីឆ្នាំទី១ និងឆ្នាំបន្តបន្ទាប់នៃអាណត្តិរបស់ខ្លួនទទួលបានជោគជ័យទៅតាមគម្រោង ដែលបានគ្រោងទុក និងឆ្លើយតបទៅនឹងក្របខណ្ឌអភិវឌ្ឍដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍប្រាំឆ្នាំ (២០២០-២០២៥) របស់រដ្ឋបាលខណ្ឌដូនពេញ។

កម្មវិធីវិនិយោគ៣ឆ្នាំរំកិលខណ្ឌដូនពេញ បានរៀបចំឡើងដោយផ្អែកតាមផែនការអភិវឌ្ឍប្រាំឆ្នាំសម្រាប់ជាជំនួយដល់គណៈអភិបាលខណ្ឌ ក្នុងការសម្របសម្រួល និងកៀរគរធនធាននានា ក្នុងការអនុវត្តគម្រោងសកម្មភាពជាអាទិភាព ដើម្បីអភិវឌ្ឍមូលដ្ឋានខណ្ឌដូនពេញ ប្រកបដោយការចូលរួម តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព សំដៅកែលម្អ លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច គុណភាពនៃការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ កម្រិតជីវភាពរស់នៅ សុខុមាលភាពប្រជាពលរដ្ឋ និងសកម្មភាពសេវាសង្គម ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។[23] កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២១-២០២៣ របស់រដ្ឋបាលខណ្ឌដូនពេញ បានរៀបចំឡើងដោយផ្អែកតាមប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងផែនការលេខ ០៧៥ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេស និងស្ដីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ ដែលត្រូវបានក្រុមប្រឹក្សាខណ្ឌ អនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី១២ នាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ និងបម្លែងផែនការអភិវឌ្ឍប្រាំឆ្នាំរបស់ក្រុមប្រឹក្សាខណ្ឌទៅជាសកម្មភាព និងសេវាជាក់ស្ដែងដែលមានភ្ជាប់នូវចំណាយមូលនិធិ សំដៅលើកកម្ពស់ការផ្ដល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍន៍នៅក្នុងមូលដ្ឋានខណ្ឌ សម្រាប់រយៈពេល បីឆ្នាំ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

[23] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ២០២១-២០២៣ របស់រដ្ឋបាលខណ្ឌដូនពេញ រាជធានីភ្នំពេញ

ដូចជាបញ្ហាផ្សេងៗដែលកើតមានឡើងនៅក្នុងខណ្ឌ គម្រោងផែនការត្រូវតែឆ្លើយតបនឹងបញ្ហាទាំងនោះ។ ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាមួយមិនអាចមើលរំលងបានឡើយ យើងគ្រប់គ្នា ក៏បានសម្គាល់ឃើញមានការផ្លាស់ប្តូរនៃអាកាសធាតុ នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំនេះ ពេលខ្លះអាកាសធាតុក្តៅខ្លាំង នៅសុខៗក៏ភ្លៀងមួយរំពេច។ ខណ្ឌដូនពេញមានគ្រោះធម្មជាតិ ដូចជា ទឹកជំនន់ ដូចសេចក្តីរាយការណ៍មួយបានរាយការណ៍ពីខណ្ឌដូនពេញមានសង្កាត់ផ្សារថ្មី ខណ្ឌចំការមន មានសង្កាត់ទន្លេបាសាក់ និងខណ្ឌទួលគោកមាន ផ្សារដើមគរត្រូវបានលិចទឹក។ ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីកាត់បន្ថយការលិចទឹកកំពុងតែត្រូវបានធ្វើឡើងយ៉ាងប្រញាប់ប្រញាល់។ មានស្ថានីយបូមទឹកច្រើនជាង១០ ក្នុងទីក្រុងភ្នំពេញបន្ទាប់ពីមានការសាងសង់ស្ថានីយបូមទឹកបានចាប់ផ្តើមក្នុងឆ្នាំ ២០១៥។[24]

អ្នកនាំពាក្យសាលាក្រុង បាននិយាយថា "ផ្អែកលើស្ថានីយបូមទឹកថ្មីៗដែលបំពាក់ដោយឧបករណ៍គ្រប់គ្រាន់ជាមួយកម្លាំងបូមខ្លាំងដែលពួកយើងបានរៀបចំឡើង រដ្ឋាភិបាលធានាថាទីក្រុងភ្នំពេញនឹងមិនលិចទឹកម្តងទៀតនោះទេ។"[25]

ប្រសិនបើអ្នកចង់ឱ្យប្រាកដថាកន្លែងដែលអ្នកនឹងទៅរស់នៅគ្មានបញ្ហាទឹកជំនន់ អ្នកត្រូវត្រួតពិនិត្យមើលតំបន់ជុំវិញ ឬមើលទីតាំងអចលនទ្រព្យនោះដោយផ្ទាល់។ កត្តាទាំងនេះតែងតែមិនមានភាពទាក់ទាញហើយស្ថិតនៅបន្ទាត់ក្រោមបំផុតអ្នកក៏អាចពិនិត្យមើលឱ្យបានច្បាស់នូវឫសគល់នៃអចលនទ្រព្យនោះ។ ប្រសិនបើអ្នកបានទិញ ឬជួលផ្ទះរួចរាល់ហើយអ្នកត្រូវអានអត្ថបទនេះហើយធ្វើដំណើរជុំវិញទីក្រុងអំឡុងពេល ទឹកជំនន់ អ្នកនឹងអាចគ្រប់គ្រងបានដោយប្រើប្រាស់ម៉ូតូកង់បី ឬតាក់ស៊ី។ ព្យុះក្នុងប្រទេសកម្ពុជាជាធម្មតា គឺខ្យល់ ដូច្នេះអ្នកអាចពាក់អាវក្រាស់ៗដែលមិនជ្រាបទឹក និងមិនអាចជ្រាបទឹកបានអាចប្រសើរជាងការប្រើប្រាស់ឆត្រ។

ក្នុងដែនសមត្ថកិច្ចរដ្ឋបាលខណ្ឌ ក្រៅពីគ្រោះមហន្តរាយបណ្តាលមកពីការប្រែប្រួលអាកាសធាតុដែលជានិន្នាការរួមរបស់ប្រទេស ក៏ដូចជាពិភពលោកទាំងមូលត្រូវប្រឈម រដ្ឋបាលខណ្ឌ ត្រូវយកចិត្តទុកដាក់គ្រោះមហន្តរាយដែលបណ្តាលមកពីអគ្គិភ័យ គឺជាគ្រោះថ្នាក់ដែលបង្កការខូចខាតទ្រង់ទ្រាយធំ បណ្តាលឱ្យបាត់បង់ផ្ទះសំបែង ទ្រព្យសម្បត្តិ និងអាយុជីវិតប្រជាពលរដ្ឋទៀតផង។ គ្រោះអគ្គិភ័យនេះ អាចបណ្តាលមកពីការធ្វេសប្រហែសរបស់ប្រជាជន ក្នុងការដុតទៀន ធូប និងការតចរន្តអគ្គិសនី មិនបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ កន្លងមក អាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងខណ្ឌ បានប្រើប្រាស់វិធានការចាំបាច់ ក្នុងការបង្ការទប់ស្កាត់គ្រោះ

[24] គេហទំព័រ https://www.phnompenhpost.com/national/one-dead-heavy-rains-wreak-havoc-kandal-and-phnom-penh (ចូលទស្សនាថ្ងៃទី១៦ មីនា ២០២២)

[25] គេហទំព័រ https://www.phnompenhpost.com/post-property/city-hall-reassures-phnom-penh-citizens-flooding (ចូលទស្សនាថ្ងៃទី១៧ មីនា ២០២២)

អគ្គិភ័យដូចជា ចេញសេចក្តីជូនដំណឹងដល់ប្រជាពលរដ្ឋទូទៅ ក៏ដូចជា អាជីវករលក់ដូរក្នុងផ្សារ ឱ្យលើកកម្ពស់ស្មារតីទប់ស្កាត់គ្រោះអគ្គិភ័យ ដោយត្រូវមានបំពង់ពន្លត់អគ្គិភ័យតាមផ្ទះ តាមតូបក្នុងផ្សារ និងពន្លត់ទៀន ធូប ចង្ក្រាន ឱ្យបានត្រឹមត្រូវមុនពេលចាកចេញពីគេហដ្ឋាន-ផ្សារ។[26]

ទាំងនេះសុទ្ធសឹងតែជាការផ្សព្វផ្សាយ និងដោះស្រាយបញ្ហាឱ្យចំគោលដៅ។ ពេលដែលខណ្ឌត្រូវទឹកជន់លិច ដំណោះស្រាយត្រូវតែរៀបប្រព័ន្ធលូថ្មី ដោយយើងឃើញថាសព្វថ្ងៃ ខណ្ឌដូនពេញលែងលិចទឹកតាមដងផ្លូវទៀតហើយ។ ចំណែកឯរឿងគ្រោះអគ្គិភ័យ រដ្ឋបាលខណ្ឌក៏បានចាត់វិធានការទប់ស្កត់តាមរយៈក្រុមការងារចូលទៅជម្រាប និងណែនាំផ្ទាល់ដែរ។ សបញ្ជាក់ឱ្យឃើញថា គ្រប់ជំហ៊ាន និងគម្រោងរៀបចំខណ្ឌ គឺសិក្សាយ៉ាងច្បាស់លាស់ពីបញ្ហារបស់ប្រជាជននៅក្នុងតំបន់ និងផ្តល់នូវទំនុកចិត្តដោយចូលទៅដោះស្រាយជូនភ្លាមៗ។

### ២.១.២. វិស័យដឹកជញ្ជូន

ការអភិវឌ្ឍមួយដែលច្បាស់លាស់ ត្រូវបានធ្វើឡើងដោយធ្វើការពង្រីកទំហំទីក្រុង។ ប្រព័ន្ធគមនាគមន៍ គំរូដែលរួមមានផ្លូវធ្វើដំណើរ និងរចនាសម្ព័ន្ធ។ សមាហរណកម្មមួយដ៏ប្រសើរ គឺការអភិវឌ្ឍពីតំបន់ដែលឆ្លងកាត់ឱ្យក្លាយទៅជាតំបន់អភិវឌ្ឍន៍។ សហគមន៍ដែលមានការប្រែប្រួលពីផ្លូវធម្មតាទៅជាផ្លូវរថភ្លើង ដើម្បីឱ្យស្របទៅនឹងផ្លូវធ្វើដំណើរដែលមានការកើនឡើង។ ទាំងអស់នេះ គឺជាការកាត់បន្ថយតម្រូវការនៃការប្រើប្រាស់ផ្លូវដែលធ្វើឱ្យការអភិវឌ្ឍផ្តោតសំខាន់ទៅលើការកាត់បន្ថយ ការឆ្លងកាត់ផ្លូវ ឬហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវថ្មើរជើង។ ជាក់ស្តែងនៅតំបន់ជាយក្រុង គឺមានការលើកទឹកចិត្តដល់អ្នកថ្មើរជើង និងអ្នកជិះកង់នៅលើផ្លូវណាដែលមានរថយន្តច្រើនប្រើប្រាស់បើទោះបីជាភាគរយនៃអ្នកប្រើប្រាស់ផ្លូវមានការកើនឡើង ឬអត់ក៏ដោយ។

សព្វថ្ងៃនេះការធ្វើដំណើរជុំវិញទីក្រុង មានជម្រើសដឹកជញ្ជូនជាច្រើនក្នុងខណ្ឌដូនពេញដែលដឹកជញ្ជូនដោយស្ថានីយជាច្រើនដោយភ្ជាប់ទំនាក់ទំនងជាមួយតំបន់មួយចំនួននៅតាមខេត្ត និងក្រុងនៃប្រទេសកម្ពុជា។ ស្ថានីយរថភ្លើងកម្ពុជា គឺជាស្ថានីយមួយក្នុងចំណោមស្ថានីយនៅក្នុងប្រទេសកម្ពុជា ហើយស្ថានីយនេះអាចដឹកអ្នកដំណើរទៅខេត្តកំពត និងខេត្តព្រះសីហនុ។ ស្ថានីយមួយចំនួនទៀតរួមមានស្ថានីយរថយន្តតាក់ស៊ីបាត់ដំបង ស្ថានីយរថយន្តក្រុងផ្សារធំថ្មី ស្ថានីយរថយន្តក្រុងលឿន G.S.T ស្ថានីយរថយន្តក្រុងសាកលវិទ្យាល័យឱសថសាស្ត្រ ស្ថានីយរថយន្តក្រុង BKC ស្ថានីយរថយន្តក្រុង៣៦ តាមមហាវិថីព្រះមុនីវង្ស កំពង់ចម្លងភ្នំពេញ ស្ថានីយរថយន្តក្រុងពេទ្យព្រះកេតុមាលា ស្ថានីយរថយន្តក្រុងមន្ទីរពេទ្យកាល់ម៉េត ស្ថានីយរថយន្តក្រុងវង្វង់មូលស្តាតចាស់ និងស្ថានីយមណ្ឌលសុខភាពខណ្ឌដូនពេញ។ មួយវិញទៀត យើងក៏អាចធ្វើដំណើរបាន តាមរយៈម៉ូតូកង់បី និងម៉ូតូឌុបជាច្រើនផងដែរនៅក្នុងតំបន់នេះ ប៉ុន្តែអ្នកក៏អាចប្រើប្រាស់យានយន្ត និងកង់ របស់អ្នកដើម្បី

[26] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ ២០២១-២០២៣ របស់រដ្ឋបាលខណ្ឌដូនពេញ រាជធានីភ្នំពេញ, ទំព័រទី ១៥

ធ្វើដំណើរជុំវិញខណ្ឌដូនពេញបានដែរ។ ហើយក៏មានយានយន្តដឹកជញ្ជូនទៅតំបន់ផ្សេងៗនៃរាជធានីភ្នំពេញដែរ តាមរយៈផ្លូវសំខាន់ៗព័ទ្ធជុំវិញខណ្ឌដូនពេញ។ អ្វីដែលសំខាន់ជាងគេ នោះមានសេវាដឹកជញ្ជូនសាធារណៈរបស់រដ្ឋ ដែលជួយសម្រួលអ្នកដំណើរដោយមិនចាំបាច់ប្រើយានយន្តរបស់ខ្លួនផ្ទាល់។ សេវាដឹកជញ្ជូនសាធារណៈបានកំណត់ម៉ោង និងខ្សែរត់ច្បាស់លាស់៖

- ម៉ោងប្រតិបត្តិការ ចាប់ពី ៥:៣០ ដល់ ២០:៣០។
- រយៈពេលចេញដំណើរ និងតាមខ្សែរត់ គឺ ៥-១០នាទី (ខ្សែ១A, ២, ៣, ៤B), ១០-១៥នាទី (ខ្សែ៥B, ៦, ៩) និង ១៥-២០នាទី (ខ្សែលេខ១B, ៤A, ៤C, ៥A, ៧, ៨, ១០, ១១, ១២,១៣)។

សម្រាប់មនុស្សពេញវ័យ គ្រាន់តែចំណាយថ្លៃសំបុត្រត្រឹមតែ ១៥០០៛ ប៉ុណ្ណោះ។ ក្នុងសម័យនេះ កាន់តែងាយស្រួលទៀត អ្នកធ្វើដំណើរមានជម្រើសក្នុងការបង់ប្រាក់ តាមរយៈទឹកប្រាក់ផ្ទាល់ Wing និងអេស៊ីលីដាទាន់ចិត្តក៏បាន។ ម្យ៉ាងវិញទៀត រថយន្តក្រុង ផ្តល់អាទិភាពពិសេសចំពោះ ព្រះសង្ឃ ជនពិការ សិស្ស មនុស្សចាស់ (៧០ឆ្នាំឡើងទៅ) កុមារ (កម្ពស់ក្រោម ១ម៉ែត្រ) កម្មករ កម្មការិនីរោងចក្រ គ្រូបង្រៀន កីឡាករ កីឡាការិនីជំនាញ ធ្វើដំណើរដោយឥតគិតថ្លៃ។[27] ដូចនេះមិនថាប្រជាពលរដ្ឋខ្មែរ និងភ្ញៀវបរទេស មានមធ្យោបាយធ្វើដំណើរយ៉ាងងាយស្រួលបំផុត។

### ២.១.៣. បរិស្ថានសំណង់

បរិស្ថានសំណង់នៅខណ្ឌដូនពេញ រួមមានរចនាបទស្ថាបត្យកម្ម និងរចនាបទលំនៅដ្ឋានជាច្រើនប្រភេទ។ សំណង់អគារ និងវិទ្យាដែលមានរចនាបទសម័យអាណានិគមបារាំង គឺមានច្រើននៅពាសពេញទីក្រុងផងដែរ។ ពេលនេះអគារទាំងនេះមួយចំនួនត្រូវបានស្តារឡើងវិញ ប៉ុន្តែអគារជាច្រើនត្រូវបានបំផ្លាញ ឬមានភាពទ្រុឌទ្រោម។ បច្ចុប្បន្ននេះ សំណង់ផ្ទះសម្បែងទូទៅ គឺរួមមានផ្ទះបើកអាជីវកម្មតាមរចនាបទចិន ឬវិឡារទោលនៅដាច់តែឯង។ ផ្ទះបើកអាជីវកម្មមានចំនួនច្រើនជាងគេបំផុត ព្រោះផ្ទះប្រភេទនេះមានតម្លៃធូរថ្លៃ និងអាចប្រើប្រាស់បានសម្រាប់បើកអាជីវកម្មផង និងជួលបន្តជាបន្ទប់តូចៗផង។

ថ្មីៗនេះ មានការវិនិយោគយ៉ាងច្រើនទៅលើប្រភេទអគារប្រណិតខ្ពស់ៗ (Apartments) មណ្ឌលកម្សាន្ត អគារពាណិជ្ជកម្ម និងទីក្រុងរណប។ ហេដ្ឋារចនាសម្ព័ន្ធសំណង់ប្រភេទទាំងនេះ និងមានតម្រូវការប្រើប្រាស់ថាមពលច្រើន បើមិនមានវិធានការ ឬគោលការណ៍សន្សំសំចៃថាមពល និងប្រសិទ្ធភាពថាមពលត្រូវបានបញ្ចូលទៅក្នុងបែបបទ ឬបទដ្ឋាននៃការសាងសង់ និងប្រតិបត្តិការរបស់សំណង់អគារប្រភេទនេះទេ តម្រូវការថាមពលក្នុងវិស័យនេះ និងបន្តកើនឡើងជាលំដាប់។[28] ឧទាហរណ៍ ដូចជាអត្រាជួលសម្រាប់ការិយាល័យក្នុង

---

[27] គេហទំព័រ https://phnompenh.gov.kh/phnom-penh-city/ (ចូលទស្សនាថ្ងៃទី៤ ខែមេសា ឆ្នាំ២០២២)

[28] ផែនការអភិវឌ្ឍទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ

ខណ្ឌដូនពេញទាបបំផុតមានតម្លៃ ៦ដុល្លារក្នុងមួយម៉ែត្រការ៉េសម្រាប់មួយខែ ហើយខ្ពស់បំផុត ១៥លានដុល្លារសម្រាប់ការទិញអគារការិយាល័យទាំងមូលដែលមានទំហំដី ១.០៧០ម៉ែត្រការ៉េ។ តំបន់ពាណិជ្ជកម្មសំខាន់ៗនៅទីនេះគឺ អគារធនាគារកាណាឌីយ៉ា ស្ថិតនៅតាមបណ្តោយវិថីព្រះអង្គឌួង។ អគារមួយនេះមានកម្ពស់ ៣២ជាន់ ហើយមានទំហំសរុប ៦.០០០ម៉ែត្រការ៉េ។ វាមានកន្លែងអាជីវកម្ម កន្លែងធ្វើការ បន្ទប់ប្រជុំការិយាល័យការងារក្រៅម៉ោង ការិយាល័យពេញម៉ោង ការិយាល័យខាងក្នុង និងការិយាល័យខាងក្រៅដែលអ្នកអាចរកជួលបានតាមការពេញចិត្ត។ អគារវឌ្ឍនៈ គឺជាអគារមួយដែលមានទីតាំងមានសក្តានុពលបំផុត សម្រាប់អាជីវកម្មក្នុងរាជធានីភ្នំពេញ វាមានកម្ពស់សរុប ១៨៧,៣ម៉ែត្រ និងមានកម្ពស់ ៣៩ជាន់។ វាត្រូវបានសាងសង់ឡើងប្រកបដោយស្តង់ដារអន្តរជាតិបានទទួលវិញ្ញាបនបត្រជាអគារល្អបំផុតផ្នែកថាមពល និងបរិស្ថានពីសហរដ្ឋអាមេរិក។ អគារភ្នំពេញ គឺជាតំបន់ពាណិជ្ជកម្មមួយផ្សេងទៀតនៅតំបន់នេះ។ អគារនេះមានទំហំសរុបចំនួន ១.១៧២ម៉ែត្រការ៉េ។ វាផ្តល់នូវការិយាល័យតាមតែអ្នកត្រូវការហើយអាចធ្វើឱ្យអ្នកជួបជុំគ្នាពីម្នាក់ ទៅច្រើននាក់ទៀតផង។ អគារការិយាល័យ Grade A ក៏អាចជួលបានដែរតាមរយៈ Hong Kong Land ដែលសាងសង់រួចរាល់ក្នុងឆ្នាំ២០១៧។ គម្រោងអភិវឌ្ឍន៍នោះមានទំហំ៣០.០០០ម៉ែត្រការ៉េ ហើយអគារនេះក៏មានហាងលក់ទំនិញចំនួន ៤ជាន់ផងដែរ។[29]

### ២.១.៤. ការគ្រប់គ្រងសំរាម/សំណល់រឹង

សំរាមនៅរាជធានីភ្នំពេញមានប្រហែល ១.៨៦៨តោន ក្នុងមួយថ្ងៃ (ទិន្នន័យឆ្នាំ២០១៥)។ ការសិក្សាមួយបានសន្និដ្ឋានថា សំរាមប្រហែល ៧២% គឺជាសំរាមសរីរាង្គ។ ការវិភាគលម្អិតផ្នែកបច្ចេកទេសបានបង្ហាញពីលក្ខណៈសំរាមនៅរាជធានីភ្នំពេញដូចខាងក្រោម៖

- ចំណុះសារធាតុឆេះ = ៩០% (ដោយសារចំណុះម្ហូបអាហារខ្ពស់នៅក្នុងសំណល់)
- ចំណុះសំណើម = ៦៤% - តម្លៃកាឡូរី = ១.៥៩៨គីឡូកាឡូរីក្នុងមួយគីឡូក្រាម និង
- សមាមាត្រកាបូន/អាស៊ូត = ២០:១

ស្តីពីលក្ខណៈរបស់សំរាមអាចបញ្ជាក់ថា សំរាមនៅរាជធានីភ្នំពេញ មានភាពសមស្របក្នុងការធ្វើជាប្រភពបង្កើតថាមពល ឬសម្រាប់ការធ្វើជីកំប៉ុស្តិ៍ប្រើប្រាស់ឡើងវិញបាន។

ការគ្រប់គ្រងសំរាមនៅតំបន់ក្រុង ត្រូវបានទទួលស្គាល់ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ថាជាបញ្ហាប្រឈមផ្នែកបរិស្ថានដ៏ចម្បងមួយជាពិសេសពាក់ព័ន្ធ ទៅនឹងកង្វះការប្រមូលសំរាមឱ្យបានគ្រប់ជ្រុងជ្រោយនៅរាជធានីភ្នំពេញ ព្រោះការប្រមូលនៅតំបន់មួយចំនួនក្នុងទីក្រុង គឺនៅមិនទាន់មានសេវាប្រមូលសំរាមទៅដល់ ឬការប្រមូលមានភាពយឺតយ៉ាវ។ ជាលទ្ធផលសំណល់សំរាមជាច្រើនតោនត្រូវបានចាក់គរចោល ឬបោះទៅក្នុងទន្លេ

[29] គេហទំព័រ https://www.propertyarea.asia/archives/83762 (បានចូលទស្សនាថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០២២)

ស្រះ ប្រឡាយ ឬត្រូវបានកប់ក្នុងរណ្តៅនៅតាមផ្ទះ។ សំរាមដែលមិនបានប្រមូល គឺនៅរាយប៉ាយតាមទីធ្លាផ្លូវសាធារណៈហើយជាញឹកញាប់ធ្វើឱ្យស្ទះប្រព័ន្ធលូនៅតាមមូលដ្ឋាន និងបង្កើតជាបរិយាកាសខ្វះអនាម័យ។

ដោយឃើញមានការចោលសំរាម គ្មានសណ្តាប់ធ្នាប់បែបនេះ បណ្តាខណ្ឌនីមួយៗត្រូវតែមានវិធានការបន្ថែម ដើម្បីអាចឱ្យតំបន់របស់ខ្លួនស្អាត និងអនាម័យគ្រប់ច្រក។ ដូចជាខណ្ឌដូនពេញ បានសហការជាមួយក្រុមហ៊ុន មីហ្ស៊ូដា សានីថេសិន (ខេមបូឌា) ឯ.ក ក្នុងការរៀបចំសេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាមក្នុងខណ្ឌដូនពេញតែម្តង។

- **ការសម្អាតផ្លូវ**

គ្រប់សង្កាត់ទាំងអស់ក្នុងខណ្ឌដូនពេញ តម្រូវឱ្យមានការសម្អាតផ្លូវឱ្យបានស្អាតបំផុត។ ចំណែកឯខាងក្រុមហ៊ុនបានរៀបចំកម្មវិធីសម្អាតច្បាស់លាស់។ កម្មវិធីសម្អាតបែងចែកជា ៣ផ្នែកគឺ ក្រុមសម្អាតជារៀងរាល់ថ្ងៃ ក្រុមសម្អាតថ្ងៃចន្ទ-ពុធ-សុក្រ និងក្រុមថ្ងៃអង្គារ-ព្រហស្បតិ៍-សៅរ៍។ ម្យ៉ាងទៀត ក្រុមទាំងនោះត្រូវតែបំពេញភារកិច្ចរបស់ខ្លួនតាមវេន។ វេនទី១ ចាប់ពីម៉ោង ៥:០០ ដល់ ៩:០០ ព្រឹក និងវេនទី២ ចាប់ពីម៉ោង ១:០០ ដល់៤:០០ល្ងាច។

- **ការប្រមូល និងដឹកជញ្ជូនសំរាមតាមសួនច្បារ**

សួនច្បារ ជាផ្នែកមួយទាក់ទាញក្រសែភ្នែកប្រជាពលរដ្ឋគ្រប់តំបន់ មកគយគន់លេង ពេលធ្វើដំណើរតាមផ្លូវ ហេតុដូចនេះ បើមានសួនច្បារស្អាត ក៏ប៉ុន្តែមានសំរាមចោលពេញវាល។ តើនោះអាចជាសួនច្បារទៀតទេ? សបញ្ជាក់ឱ្យឃើញ ពិតជាមានសារៈសំខាន់ដែលរដ្ឋបាលខណ្ឌ បានយកចិត្តទុកដាក់ឱ្យមានការប្រមូលនិងដឹកជញ្ជូនសំរាមតាមសួនច្បារ ឱ្យបានទៀងទាត់ដោយកុំឱ្យមានលក្ខណៈសំរាមគរលើគ្នា បង្កជាក្លិនមិនល្អជាដើម។ ក្រុមសម្អាត ត្រូវតែសម្អាតជារៀងរាល់ថ្ងៃតែម្តង ដោយគោរពទៅតាមវេនដែលបានកំណត់វេនទី១ ម៉ោង ៤:០០ ដល់ម៉ោង ៨:០០ព្រឹក និងវេនទី២ ចាប់ពីម៉ោង ២:០០ ដល់ម៉ោង ៦:០០ល្ងាច។

- **ការប្រមូល និងដឹកជញ្ជូនសំរាមតាមដងផ្លូវ**

សកម្មភាពដែលក្រុមប្រមូលសំរាម និងដឹកជញ្ជូនសំរាម ភាគច្រើនធ្វើតែពេលយប់ទេ ក្នុងចន្លោះម៉ោង ៦ល្ងាចដល់ ១២យប់។ ចំណែកឯពេលព្រឹកវិញ គឺ ៦ព្រឹក ដល់ ១២ថ្ងៃត្រង់។ ក្រុមប្រមូល និងបញ្ចេញសំរាមធ្វើបែបនេះរៀងរាល់ថ្ងៃទើបអាចឱ្យមានដងផ្លូវយ៉ាងស្រស់ស្អាតសម្រាប់អ្នកដំណើរឆ្លងកាត់ទៅវិញទៅមកបាន។

### ២.១.៥. ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌

តាមប្រវត្តិសាស្ត្រ រាជធានីភ្នំពេញសម្បូរទៅដោយខ្យល់ តំបន់បៃតង ព្រមទាំងអគារ និងតំបន់បេតិកភណ្ឌវប្បធម៌។ ទោះជាយ៉ាងនេះក្តីការអភិវឌ្ឍឡើងវិញរបស់ទីក្រុងចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ បានធ្វើឱ្យតំបន់បៃតង ព្រមទាំងអគារ និងតំបន់បេតិកភណ្ឌវប្បធម៌របស់ទីក្រុងជាច្រើនកំពុងត្រូវបានរុះរើ ដើម្បីគម្រោងអភិវឌ្ឍថ្មី

ឬត្រូវបានទុកចោលឱ្យទ្រុឌទ្រោម។ ខណ្ឌដូនពេញ មានសំណង់អគារចាស់ៗរបស់បារាំងច្រើន ដែលត្រូវបានសាងសង់ឡើង ក្នុងរយៈពេលដែលប្រទេសកម្ពុជា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់បារាំងជិត ១០០ឆ្នាំ។ លោកប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ បានឱ្យដឹងថាខណ្ឌដូនពេញបានចាត់ទុកជាតំបន់បេតិកភណ្ឌដោយសារមានសំណង់ចាស់ៗជាអគាររដ្ឋបាល លំនៅដ្ឋាន ទីកន្លែងសាធារណៈ យ៉ាងច្រើនដែលសាងសង់នាសម័យអាណានិគមបារាំង។ សំណង់ទាំងនោះ រចនាជាស្ថាបត្យកម្មបែបទំនើប និងបែបខ្មែរ។ សំណង់គួរឱ្យចាប់អារម្មណ៍មានដូចជាសំណង់សារមន្ទីរជាតិ ដែលបានកសាងនៅឆ្នាំ១៩១៧ តាមរចនាបថខ្មែរ។ ក្រៅពីនោះមានសំណង់បែបបារាំងដូចជាផ្សារធំថ្មី រាជាយស្ម័យយាន រួមទាំងសំណង់មានអាយុកាលមួយសតវត្សរ៍ជាអគាររដ្ឋបាល អគារស្នាក់នៅរបស់មន្ត្រីរាជការ ដែលជាមរតកសម្បត្តិបេតិកភណ្ឌជាតិ។ បើតាមមន្ត្រីមន្ទីរវប្បធម៌ សំណង់ទាំងនេះ បច្ចុប្បន្នគ្រប់គ្រងដោយឯកជនផុតពីដៃរបស់អាជ្ញាធរ។ កន្លងទៅខាងមន្ត្រីក៏ធ្លាប់ចុះពិនិត្យ តែមន្ត្រីគ្មានសិទ្ធិប៉ះពាល់នោះទេ ពីព្រោះជាកម្មសិទ្ធិរបស់ឯកជន មានតែស្នើឱ្យនាំគ្នាជួយថែរក្សាតែប៉ុណ្ណោះ។ "ពេលមន្ត្រីចុះពិនិត្យនៅពេលមានការសាងសង់អី ពួកគាត់សួរថាបើមិនឱ្យជួសជុល ឬសាងសង់ថ្មីពេលមានបញ្ហាបាក់រលំនរណាគេទទួលខុសត្រូវ វាពិបាកក្នុងការហាមឃាត់ ដោយសារជាសិទ្ធិសម្រេចរបស់ម្ចាស់សំណង់"។

បច្ចុប្បន្ននេះ គេមិនមានឯកសារជាក់លាក់ តើមានសំណង់អគារសល់ពីសម័យអាណានិគមបារាំងប៉ុន្មាននៅរាជធានីភ្នំពេញ។ ប៉ុន្តែនៅខណ្ឌដូនពេញសំណង់បុរាណសម័យបារាំងសល់ច្រើនជាងគេជាក់ស្តែងនៅម្តុំផ្សារចាស់ និងផ្សារកណ្តាល។ យ៉ាងណាសំណង់ខ្លះចាស់ទ្រុឌទ្រោម មានការជួសជុលស្ទើរបាត់រូបរាងដើម ហើយខ្លះក៏មានការរើចោលសាងសង់ថ្មីតែម្តង។ ក្រៅពីសំណង់អគារសម័យអាណានិគមបារាំងជាបេតិកភណ្ឌជាតិ នៅរាជធានីភ្នំពេញមិនមានសំណង់ប្រាសាទបុរាណនៅសល់រូបរាងនោះទេ។ ប្រាសាទបុរាណមួយនៅវត្តឧណ្ណាលោមនៅសល់តួបន្តិចបន្តួចលែងមានរូបរាងជាប្រាសាទ ហើយក៏មានការសាងសង់ចេតិយថ្មីស្ទើរតែមើលមិនស្គាល់។ ក្រៅពីនេះមានសំណង់ប្រាសាទមួយចំនួនទៀត ដែលបាក់បែកនៅសល់តែស្លាកស្នាមខ្លះៗ ជាតឹកតាងសំណង់ប្រាសាទពីដើម។ រាជធានីភ្នំពេញមានសំណង់ជាព្រះវិហារ កុដ្ឋិ និងចេតិយបុរាណដែលមានអាយុកាលរាប់សតវត្សរ៍មួយចំនួន ហើយកន្លងទៅនេះក្រុមអ្នកបុរាណវិទ្យា ក៏បានរកឃើញឡកុលាលភាជន៍នៅជើងឯក តាមរយៈការធ្វើកំណាយផងដែរ។[30]

ចំនួនលំហបៃតង និងតំបន់ចំហនៅរាជធានីភ្នំពេញ បានថយចុះយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ យោងតាមផែនការមេស្តីពីមធ្យោបាយដឹកជញ្ជូនទីក្រុងនៅរាជធានីភ្នំពេញឆ្នាំ ២០៣៥។ រាជធានីភ្នំពេញមាន

[30] គេហទំព័រ https://www.kampucheathmey.com/local-news/207945 (ចូលទស្សនាថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២២)

តំបន់បៃតងក្នុងប្រជាជនម្នាក់តិចខ្លាំងជាងទីក្រុងធំៗផ្សេងទៀតដែលមានប្រជាជនច្រើននៅក្នុងពិភពលោក។ ពាក់ព័ន្ធនឹងស្ថានភាពលំហសាធារណៈរាជធានីភ្នំពេញ គួរកត់សម្គាល់ថាផ្លូវដើរលំហែមាត់ទន្លេនៅព្រះស៊ីសុវត្ថិនៅខណ្ឌដូនពេញ ត្រូវបានជួសជុលកែលម្អទៅជាលំហសារធារណៈដែលត្រូវបានរៀបចំទេសភាព និងអាចចូលបាន ដែលបង្កើតកាលានុវត្តភាពសម្រាប់ការកម្សាន្តក្នុងទីក្រុងសម្រាប់ប្រជាជន និងអ្នកទស្សនាជាច្រើននៅក្នុងតំបន់។ ឧទ្យានសាធារណៈក្នុងទីក្រុងផ្សេងៗដែលមានភាពទ្រុឌទ្រោម ពេលនេះត្រូវបានជួសជុលកែលម្អដោយមានការរចនាទេសភាព។

## ២.២. របៀបនៃការរៀបចំខណ្ឌដូនពេញនាពេលបច្ចុប្បន្ន

### ២.២.១. ការរៀបចំខណ្ឌឱ្យមានសោភ័ណភាពក្នុងការទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិ

ដើម្បីរៀបចំទីក្រុងប្រកបដោយបរិស្ថានស្រស់បំព្រង អាជ្ញាធរមានសមត្ថកិច្ចត្រូវគិតគូរពីកត្តាចម្បងៗ ២យ៉ាងដូចជា៖ ការគ្រប់គ្រងការបំពុល (ទឹក ដី សំណល់រឹងរាវ ខ្យល់ និងសំឡេង) និងការរៀបចំតំបន់បៃតង។

**ក. ការគ្រប់គ្រងការបំពុល**

ការបំពុលភាគច្រើនកើតចេញពីសំណល់ ហើយសំណល់ គឺកើតចេញពីសកម្មភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស។ ដើម្បីគ្រប់គ្រងការបំពុលបាន គឺត្រូវគ្រប់គ្រងកាកសំណល់ទាំងអស់ ដូចជាសំណល់ដែលនាំឱ្យមានការបំពុលទឹក ដី និងបរិយាកាស។

**ការបំពុល** គឺជាសកម្មភាពទាំងឡាយណាដែលធ្វើឱ្យពុល។[31]

**សំណល់រឹង** គឺសំដៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬកម្ទេចកម្ទីដែលលែងត្រូវបានប្រើប្រាស់ ហើយត្រូវបានបោះចោល មានបំណង់បោះចោល ឬត្រូវតែបោះចោល។[32]

**សំណល់រាវ** គឺសំដៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី។[33]

**ប្រភពបំពុល** គឺសំដៅលើទីតាំងទាំងឡាយណា រួមទាំងលំនៅឋាន និងអគាររដ្ឋបាលសាធារណៈនានា ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុបំពុល ឬសារធាតុដែលបង្កឱ្យគ្រោះថ្នាក់ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តីចូលទៅក្នុងតំបន់ទឹកសាធារណៈចូលទៅក្នុងបណ្តាញលូសាធារណៈ។

[31] វចនានុក្រមខ្មែរ, សម្តេចព្រះសង្ឃរាជជួនណាត

[32] មាត្រា៣ នៃអនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណង់រឹង ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩

[33] មាត្រា៣ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៩

ជាទូទៅរាល់ការបង្កឡើងឱ្យមានការបំពុលបរិស្ថាន ទោះជាកម្រិតណាក្តី វិធានការចាំបាច់នឹងត្រូវរៀបចំឡើង ដើម្បីធានាដល់គុណភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ និងស្ថិរភាពរបស់ប្រព័ន្ធជីវសាស្ត្រ ដោយសារការបំពុលបរិស្ថានធ្វើឱ្យមានផលអវិជ្ជមានយ៉ាងច្រើនចំពោះបុគ្គលគ្រប់រូប ក៏ដូចជាសង្គមទាំងមូល។ម្យ៉ាងវិញទៀតក្នុងការបំពុលទាំង ៥ ខាងលើ សុទ្ធសឹងតែមានវិធានការក្នុងការដោះស្រាយ ព្រោះវាជាកត្តាមួយដ៏ចាំបាច់ក្នុងការធានានូវនិរន្តរភាពនៃបរិស្ថានស្អាត ហើយវិធានការទាំងនោះត្រូវរៀបចំ និងសិក្សាឱ្យបានហ្មត់ចត់ និងល្អិតល្អន់ជាទីបំផុតដោយថ្នាក់ដឹកនាំ និងក្រសួង អង្គការនានាដែលពាក់ព័ន្ធ ដើម្បីធានារក្សានូវការការពារឱ្យមានប្រសិទ្ធភាពខ្ពស់ជាទីបំផុត។[34] ការរស់នៅស្អាត ត្រូវបានក្រសួងអប់រំ យុវជន និងកីឡា ដាក់ឱ្យកូនខ្មែររៀន តាំងពីថ្នាក់មត្តេយ្យសិក្សារហូតមក។ ការរស់នៅដែលមានបរិស្ថាននៅជុំវិញខ្លួនល្អ មានខ្យល់អាកាសល្អបរិសុទ្ធ មានដើមឈើពណ៌បៃតង គ្មានក្លិនស្អុយ និងគ្មានសំឡេងរំខានជាដើម គឺសុទ្ធសឹងជាក្តីស្រម៉ៃរបស់មនុស្សគ្រប់គ្នាប្រាថ្នាចង់បាន។

យុទ្ធនាការទីក្រុងស្អាត ត្រូវបានក្រសួងបរិស្ថាន និងក្រសួងទេសចរណ៍ បានផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋជួយថែរក្សា និងដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ រហូតដល់បានបង្កើតនូវពាក្យស្លោក មួយឃ្លាថា "**ទីក្រុងស្អាត រមណីដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ**"។ ប៉ុន្តែការផ្សព្វផ្សាយពាក្យ ស្លោកនេះ ហាក់នៅមិនទាន់មានប្រសិទ្ធិភាព នៅឡើយ ពោល គឺរាជធានីភ្នំពេញ នៅមានគំនរសំរាម ស្ទើរគ្រប់ទីកន្លែង។ នៅតាមផ្សារមួយចំនួនក្នុងខណ្ឌដូនពេញ គេបានឃើញថាសំរាម ព្រោងព្រាត ត្រូវបានគេយកទៅចាក់ចោលនៅមុខផ្សារដោយ បានជះក្លិនស្អុយដល់អ្នកធ្វើដំណើរ តាមដងផ្លូវ និងប្រជាពលរដ្ឋដែលទៅទិញទំនិញ និងអ្នកដែលមានផ្ទះនៅជិតគំនរសំរាម។ ហេតុដូចនេះ គប្បីត្រូវគ្រប់គ្រងការបំណុលទាំងនោះដោយយ៉ាងត្រឹមត្រូវ។

- **ការគ្រប់គ្រងការបំពុលទឹក**

ទឹក គឺជាប្រភពនៃជីវិត ហើយក៏ជាតម្រូវការប្រចាំថ្ងៃនៃមនុស្ស សត្វ និងរុក្ខជាតិផងដែរ។ ម្យ៉ាងវិញទៀតទឹកជាប្រភពចំណែកមួយ ដែលជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចឱ្យជឿនលឿនក្នុងវិស័យឧស្សាហកម្ម កសិកម្ម ទេសចរណ៍ គមនាគមន៍។ល។ ក៏ប៉ុន្តែការលេចចេញនូវឥទ្ធិពលអវិជ្ជមានលើគុណភាពបរិស្ថានបង្កឱ្យមានផលវិបាកដល់ជីវិត មនុស្ស សត្វ ដោយការប៉ះពាល់ សារធាតុគីមីមានរាប់សែនប្រភេទ រួមទាំងកាកសំណល់ដែលផ្ទុកជាតិពុលផ្សេងៗជាច្រើន។

ការបំពុលទឹក គឺជាសកម្មភាពទាំងឡាយធ្វើឱ្យទឹកប្រើប្រាស់ខុសពីលក្ខណៈដើម ការបំពុលទឹក អាចជះឥទ្ធិពលអាក្រក់ដល់សោភ័ណភាពបរិស្ថាន អាស្រ័យទៅតាមកម្រិតនៃការបំពុល ភាគច្រើនមាននៅតាមកន្លែងសំខាន់មួយចំនួនដូចជា រមណីយដ្ឋាន ទីក្រុង ទីកម្សាន្ត និងទីសាធារណៈជាដើម។

[34] មាត្រា២ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦

ការគ្រប់គ្រងមិនឱ្យមានការបំពុលទឹក គឺជាកត្តាសំខាន់ និងជាតួនាទីចាំបាច់របស់អាជ្ញាធរក្នុងការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីទប់ស្កាត់ការបំពុលទឹក និងគ្រប់គ្រងប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់។ នេះមិនមែនតែជាភារៈកិច្ចរបស់អាជ្ញាធរម្នាក់ឯងនោះទេ ការចូលរួមពីសំណាក់ប្រជាជនគ្រប់រូបនូវរាល់សកម្មភាពសង្គមផ្សេងៗកាន់តែសំខាន់ដែរ អាចជួយដល់ការថែទាំប្រភពទឹកប្រកបដោយគុណភាព និងនិរន្តរភាព។ ការរៀបចំការគ្រប់គ្រងធនធានទឹក សម្រាប់ធានាដល់ការផ្គត់ផ្គង់ទឹកប្រកបដោយចីរភាព និងមានគុណភាពខ្ពស់ក្នុងទីក្រុងឆ្លាតវៃ។

ក្រសួងបរិស្ថានដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញនូវសំណល់រាវ ត្រូវពិនិត្យ គុណភាពនៃទឹក និងស្វែងរកប្រភពនៃការបំពុលជាមុនសិន មុនឈានដល់ការចេញនូវដំណោះស្រាយពាក់ព័ន្ធ។[35] ការត្រួតពិនិត្យទៅលើការបំពុលទឹក គឺទប់ស្កាត់ និងកាត់បន្ថយនូវការបំពុលដើម្បីការពារដល់សុខភាពមនុស្ស។[36] ការត្រួតពិនិត្យ និងស្វែងរករាល់ប្រភពបំពុល ក៏ដូចជាសកម្មភាពទាំងឡាយណាដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់សាធារណៈ គឺជាដំណោះស្រាយចម្បងមួយ ដែលប្រសើរបំផុតដើម្បីធ្វើឱ្យបរិស្ថានទឹកចៀសផុតពីការបំពុល ហើយជាពិសេស គឺជួយកែលម្អ សោភ័ណភាព និងប្រកបទៅដោយផាសុកភាពល្អក្នុងការរស់នៅប្រចាំថ្ងៃ។ វិធានការដោះស្រាយ សំខាន់ៗដែលគួរតែអនុវត្តន៍ឱ្យមានប្រសិទ្ធិភាព និងបានត្រឹមត្រូវមានដូចជា៖

**វិធានការសម្រាប់សាធារណៈ៖** គឺជាកត្តាចាំបាច់បំផុតដែលបំផុសគំនិតអប់រំតាមរយៈការផ្សព្វផ្សាយគ្រប់មធ្យោបាយ និងបង្កើនគំនិតឱ្យមានការយល់ដឹងផ្នែកថែរក្សាគុណភាព ទឹកស្អាត ដើម្បីតម្រូវការប្រចាំថ្ងៃ និងចៀសផុតពីការគ្រោះថ្នាក់ដោយការបំពុលទឹកជាដើម។

**វិធានការសម្រាប់រោងចក្រ សហគ្រាស សិប្បកម្ម៖** គឺមានន័យថាគ្រប់រោងចក្រ សហគ្រាស សិប្បកម្ម និងគ្រប់បណ្តាក្រុមហ៊ុននានាត្រូវតែអនុវត្តន៍ការគ្រប់គ្រង កាកសំណល់ឱ្យបានត្រឹមត្រូវ និងដាច់ខាតមិនត្រូវបង្ហូរកាកសំណល់សារធាតុរាវដែលមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្មចូលទៅប្រភពទឹកនោះទេ។ គ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ត្រូវចាត់វិធានការឱ្យរោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុនផ្សេងៗ ដែលបញ្ចេញនូវកាកសំណល់ជាសារធាតុរាវ ឬសារធាតុគីមីពុលត្រូវមានការធ្វើប្រព្រឹត្តកម្មនូវសំណល់ជាសារធាតុរាវទាំងនោះជាមុនសិនមុននឹងបង្ហូរចូលទៅក្នុងទឹក ឬក៏រៀបចំឱ្យមានអាងស្តុកកាកសំណល់សារធាតុរាវ។ ពិតជាការល្អណាស់ដែលខណ្ឌដូនពេញមិនមានរោងចក្រអ្វីទេ ដូចនេះគ្មានការភ័យព្រួយបារម្ភលើបញ្ហានេះ។

---

[35] មាត្រា១៨ និង១៩ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩

[36] មាត្រា១ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩

**ការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់៖** ការដែលមានភាពធូរលុងផ្នែកច្បាប់ចំពោះ ការត្រួតពិនិត្យសារធាតុពុល និងការត្រួតពិនិត្យក្នុងការគ្រប់គ្រងសំណល់ជាសារធាតុរាវ វានាំឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ជាហេតុនាំឱ្យការបំពុលទឹកនៅតែមានបន្តបន្ទាប់។ ហេតុដូចនេះថ្នាក់ដឹកនាំ និងក្រសួងស្ថាប័នដែលពាក់ព័ន្ធទាំងអស់ត្រូវចាត់វិធានការរឹងមាំ ចំពោះគ្រប់មធ្យោបាយដែលបង្ហូរកាកសំណល់ជាសារធាតុរាវទៅក្នុងប្រភពទឹក។

- **ការគ្រប់គ្រងការបំពុលដី**

ការបំពុលដីភាគច្រើន គឺដោយសារតែការប្រើប្រាស់ថ្នាំបាញ់សត្វល្អិតមិនបានត្រឹមត្រូវ ដែលថ្នាំនេះមានអាយុកាលនៃជាតិពុលពី ៧ ទៅ ១០ថ្ងៃ។ រីឯការប្រើប្រាស់ជីគីមីមិនត្រូវតាមកម្រិតស្តង់ដារ គឺវាបានបំផ្លាញដល់គុណភាពដី ហើយជាតិគីមីទាំងនោះមានកម្រិតខ្ពស់ ដែលប៉ះពាល់ដល់សុខភាពមនុស្ស សត្វ ពេលដែលបរិភោគទិន្នផលដែលកើតចេញពីដីដែលរងការបំពុលនោះ។ ម្យ៉ាងទៀត ការមិនបានគ្រប់គ្រងប្រព័ន្ធលូដែលចេញពីរោងចក្រ សហគ្រាស មន្ទីរពេទ្យ និងលំនៅដ្ឋានចូលទៅកាន់ដីស្រែចំការ ក៏ជាកត្តាបំពុលយ៉ាងចម្បងផងដែរ ព្រោះថាសារធាតុពុលជាច្រើន ប្រភេទមាននៅក្នុងកាកសំណល់នោះ។

ការបំពុលដីជាបញ្ហាប្រឈមមួយដែលគួរមានការព្រួយបារម្ភក្នុងពេលបច្ចុប្បន្ន ថ្វីត្បិតតែវាមិនសូវជះឥទ្ធិពលដល់អ្នករស់នៅកណ្តាលទីក្រុងប៉ុន្មានក៏ដោយ។ ចំណែកឯការបំពុលដីវិញ កើតឡើងជាទូទៅតាមរយៈការបំពុលដោយ សំរាម ការបំពុលដោយការបង្ហូរសារធាតុគីមី និងការប្រើប្រាស់ជីគីមីទៅលើដី។ វិធានការក្នុងការគ្រប់គ្រងទាក់ទងទៅនឹងការបំពុលដីមានដូចជា៖

- ធ្វើការប្រើប្រាស់វត្ថុដែលងាយរំលាយក្នុងរយៈពេលខ្លី ឬសម្ភារៈដែលអាចប្រើប្រាស់ ឬកែច្នៃម្តងទៀតបាន។
- អប់រំប្រជាពលរដ្ឋឱ្យយល់ដឹងក្នុងការគ្រប់គ្រង និងការវេចខ្ចប់ទុកដាក់សំរាមដោយបែងចែកសំរាមស្ងួត និងសំរាមរាវ។
- ចាត់ចែងឱ្យមានកន្លែងសម្រាប់ទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ដើម្បីងាយស្រួលក្នុងការប្រមូលផ្តុំសំរាម ចៀសវាងពីការចោលសំរាមពាសវាលពាសកាល។

- **ការគ្រប់គ្រងការបំពុលដោយសំណល់រឹងរាវ**

ក្នុងការគ្រប់គ្រងការបំពុលដោយសំណល់រឹងរាវ រដ្ឋបាល ឬអាជ្ញាធរដែនដីត្រូវរៀបចំបណ្តាញបញ្ចេញសំណល់រឹងរាវទាំងនោះ ហើយត្រូវកំណត់ឱ្យបានពីទំហំនៃសំណល់ ជាពិសេសចំនួនប្រជាពលរដ្ឋដែលភ្ជាប់បណ្តាញប្រមូលសំណល់រឹងរាវ ដើម្បីធានាដល់ការប្រមូលយកទៅកម្ទេច ឬកែច្នៃឡើងវិញទាន់ពេលវេលា និងមានប្រសិទ្ធិភាពខ្ពស់។ រដ្ឋបាល ឬអាជ្ញាធរដែនដី ត្រូវរៀបចំធុងសំរាម និងបែងចែកប្រភេទធុងសំរាមទៅតាមប្រភេទនៃកាកសំណល់ ដើម្បីងាយស្រួលក្នុងការប្រមូល និងកែច្នៃ ហើយត្រូវពន្យល់ប្រជាជនឱ្យយល់ដឹងពីការទុកដាក់សំរាមទាំងនោះឱ្យបានត្រឹមត្រូវ។

ការបំពុលដោយសំណល់រឹង និងរាវ សំណល់មិនថាជារឹង ឬរាវទេ គឺបណ្តាលមកពីមនុស្សមិនបានរៀបចំ ឬបែងចែកចំពោះសំណល់រឹង ឬរាវឱ្យបានត្រឹមត្រូវ ជាហេតុធ្វើឱ្យមានការបំពុល និងមានការកកស្ទះលូនៅពេលមានភ្លៀងធ្លាក់ទៀតផង។ ជារៀងរាល់ថ្ងៃ គឺមានសំរាមជាច្រើនដែលត្រូវបានបោះចោល ទោះបីជាសំរាមប្រភេទណាក៏ដោយ កាលដែលយើងទុកដាក់មិនបានត្រឹមត្រូវវាបង្កឱ្យមានមេរោគ ជាហេតុដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នករស់នៅប្រចាំថ្ងៃ។ ក្នុងនោះដែរគេបានឱ្យនិយមន័យដោយឡែកពីគ្នាអំពីសំណល់ រឹង រាវនេះថា៖

**សំណល់រឹង**៖ គឺសំដៅដល់វត្ថុរឹង ឬសារធាតុរឹង កម្ទេចកម្ទីដែលលែងត្រូវការប្រើប្រាស់ ឬបោះបង់ចោល។

**សំណល់រាវ**៖ គឺសំដៅដល់វត្ថុរាវដែលបញ្ចេញពីប្រភពបំពុលដែលហូរចូលទៅក្នុងតំបន់សាធារណៈ ឬហូរចូលទៅក្នុងបណ្តាញលូ ទោះមិនបាន ឬបានធ្វើប្រព្រឹត្តកម្មក្តី។ អាចនិយាយម្យ៉ាងទៀតថាសំណល់រាវ គឺសំដៅដល់វត្ថុរាវដែលជាសារធាតុរាវ រួមផ្សំគ្នាជាមួយនឹងសារធាតុរឹងខ្លះដែលត្រូវបានបោះចោលជាប្រចាំថ្ងៃទៅ តាមប្រព័ន្ធលូទឹកស្អុយផ្សេងៗ។

ដោយឡែកនៅក្នុងខណ្ឌដូនពេញយើងឃើញថា នៅតាមដងផ្លូវ ក៏ដូចជានៅតាមមុខផ្ទះរបស់ប្រជាពលរដ្ឋ ឃើញថាកាកសំណល់ជាច្រើនប្រភេទមិនត្រូវបានរៀបចំឱ្យមានរបៀបរៀបរយ និងមានលំដាប់នោះទេ។ ការគ្រប់គ្រងសំណល់រឹង រាវនៅតំបន់នេះនៅមានកម្រិតនៅឡើយ ហើយការដែលនៅតំបន់នេះមិនមានការរៀបចំសំណល់រឹងរាវឱ្យមានសណ្តាប់ធ្នាប់។

ក្នុងព្រះរាជាណាចក្រកម្ពុជា ការគ្រប់គ្រងសំណល់រឹងក៏ត្រូវបានរៀបចំ និងអនុវត្តន៍ដោយបន្ថែមអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ដែលបានចែងទាក់ទងទៅនឹងការគ្រប់គ្រងសំរាមទាំង ២ប្រភេទ៖ គឺសំរាមធម្មតា និងសំរាមដែលប្រកបដោយគ្រោះថ្នាក់។ ក្នុងនោះដែរ ការរៀបចំ និងចាត់ចែងសំរាមទាំង ២ប្រភេទនេះ ត្រូវស្ថិតនៅក្រោមការសម្រេចរបស់ក្រសួងបរិស្ថាន ក្នុងការពិនិត្យលើការអនុវត្តន៍ រៀបចំ ប្រមូល បោះចោល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយ និងការចាក់ចោលសំរាម។[37] សំណល់រឹងជាបញ្ហាមួយដែលរដ្ឋាភិបាលកំពុងប្រឈមមុខនឹងបញ្ហានេះ។

នាពេលបច្ចុប្បន្ននេះសំណល់រឹងជាច្រើន ត្រូវបានគេយកមកកែច្នៃជាថ្មីសម្រាប់ប្រើប្រាស់ឡើងវិញ និងប្រើក្នុងគោលដៅថ្មីផ្សេងទៀត។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាល និងក្រសួងបរិស្ថាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំណល់រឹងនៅក្នុងទីក្រុង ព្រមទាំងមានភារកិច្ចដូចជា៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ជាមួយក្រសួង ស្ថាប័ន និងដៃគូដែលពាក់ព័ន្ធ។

[37] មាត្រា៦ នៃអនុក្រឹត្យលេខ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩

- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថកិច្ចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការគ្រប់គ្រងសំណល់រឹង។
- គាំទ្រ និងលើកកម្ពស់ការអប់រំទាំងក្នុង និងក្រៅប្រព័ន្ធព្រមទាំងធ្វើការផ្សព្វផ្សាយអំពីការគ្រប់គ្រង់សំណល់រឹង ដែលប្រកបដោយសុវត្ថិភាពបរិស្ថាន។
- ណែនាំអំពីការកាត់បន្ថយការបង្កើត ការប្រើប្រាស់ថង់ប្លាស្ទិច ក៏ដូចជាសំណល់រឹងផ្សេងៗទៀតដែលអាចយកមកប្រើប្រាស់ឡើងវិញ ឬក៏អាចកែច្នៃបាន។
- លើកកម្ពស់សម្ភារៈដែលកើតឡើងពីការប្រើប្រាស់ឡើងវិញ ឬកើតចេញពីការឆ្នៃប្រឌិតដែលចេញពីសំណល់រឹង។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងក្នុងទីប្រជុំជន។[38]

តាមដាន ត្រួតពិនិត្យ ចំពោះបញ្ហាសំណល់ជាសារធាតុរាវជាទូទៅមានប្រភពចម្បងមកពីរោងចក្រ លំនៅដ្ឋាន សហគ្រាស សិប្បកម្ម និងក្រុមហ៊ុនផ្សេងៗ។ ចំពោះការគ្រប់គ្រងសំណល់រាវ យើងគប្បីដឹងអំពីវិធានការក្នុងការអនុវត្តន៍មួយចំនួនដូចជា៖

- ហាមឃាត់ដាច់ខាត រាល់ការចាក់ចោល ឬការបង្ហូរចេញនូវសំណល់ដែលជាសារធាតុរាវចេញពីប្រភពណាមួយដែលមិនបានឆ្លងកាត់ការអនុវត្តន៍តាមកម្រិត ស្តង់ដារនៃការបញ្ចេញសំណល់ជាសារធាតុរាវដូចមានចែងក្នុងអនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក។
- ក្រសួងបរិស្ថាន ត្រូវរៀបចំកម្រិតស្តង់ដារនៃការបញ្ចេញសំណល់រាវដូចមានចែងក្នុងមានចែងក្នុងមាត្រា៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ។[39]
- ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃក្នុងគោលបំណងណាមួយត្រូវមកសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន។[40]
- ក្រសួងបរិស្ថាន ត្រូវយកគំរូតាងសំណល់រាវ នៅគ្រប់ចំណុចបញ្ចេញចោលរបស់ប្រភពបំពុល។ ម្ចាស់សិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីក្រសួងបរិស្ថានដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស។[41]

[38] មាត្រ៥ នៃអនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជាជន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥
[39] មាត្រា៦ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៩
[40] មាត្រា១០ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៩
[41] មាត្រា១៩ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩

ចំពោះផែនការយុទ្ធសាស្ត្ររបស់ក្រសួងបរិស្ថានក្នុងការគ្រប់គ្រងសំណល់រឹង និងរាវ គឺមានការ រៀបចំគោលនយោបាយជាតិសម្រាប់ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាន រួមជាមួយផែនការមេពីវិធានការចម្រុះនូវការគ្រប់គ្រងសំណល់រឹង និងរាវប្រកបដោយនិរន្តរភាព។ ក្នុងនោះដែរ ក្រសួងបរិស្ថានក៏ព្យាយាមពង្រឹងទៅលើការអនុវត្តច្បាប់ លើកកម្ពស់ការអនុវត្តន៍កម្មវិធីកែច្នៃ និងការប្រើប្រាស់ឡើងវិញនៃសំណល់។ បង្កើតកម្មវិធីកាត់បន្ថយបរិមាណសំណល់ និងបង្កើតទីលានចាក់សំរាមប្រកបដោយបច្ចេកទេស និងមានអនាម័យ។

➢ **ការគ្រប់គ្រងការបំពុលខ្យល់**

កម្រិតនៃការបំពុលខ្យល់មានការកើនឡើង ដោយសារតែធូលី ផ្សែងចេញពីយានយន្ត រោងចក្រ ការបូជាសព ការសាកសព្វាវុធ ឬគ្រោះធម្មជាតិដូចជាភ្លើងឆេះព្រៃ និងបន្ទុះភ្នំភ្លើងជាដើម។ អាជ្ញាធរ ត្រូវមានវិធានការការពារ រាល់ការបំពុលដែលកើតចេញពីសកម្មភាពប្រចាំថ្ងៃរបស់ប្រជាជន ទោះយ៉ាងការបំពុលខ្យល់ដោយសារធម្មជាតិមិនអាចបង្ការបានក៏ដោយ។

បរិយាកាស គឺជាប្រព័ន្ធធម្មជាតិយ៉ាងរឹងមាំដែលទ្រទ្រង់រាល់ជីវិតមនុស្ស សត្វនានា នៅលើផែនដី។ ការបំផ្លាញស្រទាប់អូហ្សូន គឺជាការបំផ្លាញរនាំងការពារផែនដីពីកាំរស្មីអ៊ុលត្រាវីយ៉ូឡេដែលបង្កផលវិបាកដល់ជីវិតលើផែនដី។ ការបំពុលខ្យល់ គឺជាការបង្កើតឡើងដោយសារធាតុគីមី ឬជីវៈសរីរាង្គដែលបំផ្លាញ ឬបណ្តាយឱ្យមានផលប៉ះពាល់ដល់មនុស្ស ឬភាវៈមានជីវិតទាំងឡាយ និងបំផ្លាញដល់បរិស្ថានក្នុងបរិយាកាស។ សរុបមកវិញ ការបំពុលខ្យល់ត្រូវបានចាត់ទុកថាការគំរាមកំហែងដល់មនុស្ស និងឋានប្រព័ន្ធនានានៅលើផែនដី។[42]

បន្ថែមពីនេះ នៅក្នុងបរិយាកាសគេរកឃើញមានភ្នាក់ងារបំពុលរាប់រយប្រភេទ ប៉ុន្តែមានតែសារធាតុបំពុលចំនួន ៥ប៉ុណ្ណោះ ដែលត្រូវបានប្រទេសមួយចំនួនតាមដានអង្កេតជាប្រចាំ និងត្រូវបានគេប្រើជាសញ្ញាចង្អុលបង្ហាញពីគុណភាពនៃខ្យល់។ សារធាតុទាំងនោះមានដូចជា កាបូនម៉ូណូអុកស៊ីត ស្ពាន់ធ័រឌីអុកស៊ីត អាសូតអុកស៊ីត ចំហេះអុស ធ្យូងថ្ម ការបាចជី ការដុតកាកសំណល់ ធូលីដីជាដើម។

ជាទូទៅបញ្ហាក្នុងការបំពុលខ្យល់ត្រូវបានចាត់ចែង និងគ្រប់គ្រងដោយក្រសួងបរិស្ថានដែល មានតួនាទីក្នុងការត្រួតពិនិត្យ និងអនុញ្ញាតទៅលើការបញ្ចេញខ្យល់ដែលអាចផ្តល់ផលប៉ះពាល់ទៅដល់បរិស្ថាន។ បន្ថែមពីនេះទៅទៀត គុណភាពរបស់ខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានត្រួតពិនិត្យ និងតាមដានជាប្រចាំដោយក្រសួងបរិស្ថាន។[43] ហើយកត្តាបំពុលខ្យល់ជាទូទៅ ត្រូវបង្កើតឡើងភាគច្រើនដោយសារមនុស្សជាកត្តាចម្បង ដូច្នេះដំណោះស្រាយអាចមានដូចតទៅៈ

[42] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ឆ្នាំ២០១៣, ទំព័រ ៣៨

[43] មាត្រា២៦ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

**កត្តារដ្ឋាភិបាលៈ** រាជរដ្ឋាភិបាល គឺជាកត្តាមួយដែលសំខាន់ចម្បងមួយក្នុងការចូលរួម កាត់បន្ថយការបំពុលខ្យល់ ដោយត្រូវគ្រប់គ្រងឱ្យបាននូវការបញ្ចេញនូវឧស្ម័នពុល ឬការបញ្ចេញនូវផ្សែងនានាដែលចេញពីរោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុនទាំងអស់ឱ្យមានកម្រិតស្តង់ដារ ឬជំរុញឱ្យមានម៉ាស៊ីនបន្សុទ្ធខ្យល់មុនពេលបញ្ចេញខ្យល់ ដែលមានសារជាតុពុលទាំងនោះនៅក្នុងខ្យល់។ ចេញវិធានការឱ្យបញ្ឈប់ការដុតកាកសំណល់ និងផ្លាស្ទិចគ្រប់ប្រភេទ ព្រោះការដុតកាកសំណល់ពិតជាធ្វើឱ្យមានការបំពុលខ្យល់ធ្ងន់ធ្ងរដល់ផ្លូវដង្ហើម។ បញ្ឈប់ការបូជាសពក្នុងវត្តអារាមដែលនៅក្នុងក្រុង ដោយបញ្ហាខ្យល់ពុល ដែលបញ្ចេញពីឈាបនដ្ឋាន គឺជាខ្យល់ដែលពោរពេញទៅដោយមេរោគ បាក់តេរី និងជាតិពុលដែលចេញពីសរីរាង្គកាយមនុស្ស។ រដ្ឋាភិបាលក៏គួរតែរៀបចំឱ្យមានមធ្យោបាយដឹកជញ្ជូនសាធារណៈឱ្យបានច្រើនជាជាងប្រើប្រាស់យានយន្ត ផ្ទាល់ខ្លួនច្រើននាំឱ្យផ្សែងដែលចេញពីយានយន្តមានបរិមាណច្រើនលើសលុប។ ជាងនេះទៅទៀត គួរតែដំឡើងពន្ធនាំចូលយានយន្តចាស់ៗ ហើយបន្ថយពន្ធលើការនាំចូល រថយន្តថ្មី ជំរុញឱ្យប្រជាជនប្រើប្រាស់យានយន្តថ្មី ដើម្បីកាត់បន្ថយការបំពុលខ្យល់។

**កត្តាប្រជាជនៈ** ប្រជាជនជាកត្តាមួយដែលចូលរួមយ៉ាងសកម្មក្នុងកិច្ចការពារបរិស្ថានដោយកាត់បន្ថយនូវការប្រើប្រាស់អុស ធ្យូង សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃឱ្យបានតិចបំផុត។ បញ្ឈប់ការដុតកាកសំណល់ ហើយងាកមកកែច្នៃ ឬប្រើប្រាស់ឡើងវិញ នូវកាកសំណល់ទាំងនោះ ចៀសវាងការដុតដែលនាំឱ្យមានឧស្ម័នបំពុលខ្លាំងប៉ះពាល់ដល់ស្រទាប់អូហ្សូន។

➢ **ការបំពុលដោយសំឡេង**

ការគ្រប់គ្រងសំឡេងរំខាន គឺជាកត្តាចម្បង ដែលប្រជាជនក្នុងទីក្រុងទាមទារចង់បាន ព្រោះថាការបំពុល ដោយសំឡេង អាចបណ្តាលឱ្យប៉ះពាល់ដល់សុខភាពមនុស្សផងដែរ។ សំឡេងមានកម្រិតរបស់វា។ ជាការពិតណាស់ ការបំពុលដោយសូរសំឡេង គឺជាបញ្ហាបរិស្ថានចម្បងនៅក្នុងទីក្រុងដែលប្រមូលផ្តុំដោយសំឡេងចរាចរណ៍ សំឡេងយន្តហោះ សំឡេងរថភ្លើង សំឡេងតន្ត្រី ឧបករណ៍បំពងសំឡេង និងសំឡេងដែលចេញពីរោងចក្រ សហគ្រាស សិប្បកម្មជាដើម គឺសុទ្ធសឹងតែជាបណ្តុំនៃការបំពុលដោយសំឡេង។ បើទោះបីជាមនុស្សមួយចំនួនយល់ថា ការបំពុលដោយសំឡេងមិនសូវជាមានផលប៉ះពាល់ក៏ដោយ តែវាអាចជះឥទ្ធិពលអាក្រក់ខ្លាំងចំពោះជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់គ្នា។ អនុលោមតាមអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីអំពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ បានបង្ហាញថាមូលហេតុដែលនាំឱ្យមានការបំពុលដោយសំឡេង គឺមកពីប្រភពធំៗគឺៈ

**ការបំពុលដោយប្រភពចល័តៈ** ការបំពុលដោយប្រភពចល័តនេះ គឺសំដៅទៅលើការបំពុលដោយសំឡេងចេញពីយានយន្តនៅលើផ្លូវសាធារណៈ។ ដោយសារតែចំនួនយានយន្តនៅក្នុងរាជធានីភ្នំពេញមានការ

កើនឡើងខ្លាំងការបំពុលដោយសំឡេងក៏មានកើតឡើងដែរ។

**ការបំពុលដោយប្រភពអចល័តៈ** ចំពោះប្រភពអចល័តវិញ សំដៅទៅលើប្រភពបំពុលដែលកើតចេញពីទីតាំងជាក់លាក់ណាមួយដែលមិនមានការផ្លាស់ទី ដូចប្រភពចល័តនោះទេ។ ប្រភពចល័តនេះអាចជារោងចក្រ កន្លែងកំសាន្ត ក្លឹបកំសាន្ត សហគ្រាស ការដ្ឋានសំណង់ជាដើម។ល។

ជាមួយគ្នានេះការបញ្ចេញសំឡេងពីប្រភពយានយន្ត ទីតាំងផលិតកម្មផ្សេងៗ ការប្រើប្រាស់ម៉ាស៊ីនភ្លើងសំឡេងរំខានដែលចេញពីការដ្ឋានសំណង់នានា សំឡេងដែលចេញពីក្លឹបកម្សាន្ត ខារ៉ាអូខេ ផុងបាស និងការប្រើប្រាស់ឧបករណ៍បំពងសំឡេងគ្រប់ប្រភេទ ជាពិសេសសំឡេងរំខានដែលកើតចេញពីការកែច្នៃបំពង់ស៊ីម៉ាំងខុសពីបច្ចេកទេស ដែលបង្កឱ្យមានការបំពុលដោយសំឡេង គឺត្រូវធ្វើការហាមឃាត់ឱ្យបាន។ ហើយគប្បីកម្រិតស្តង់ដារនៃការបញ្ចេញសំឡេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកម្រិតស្តង់ដារសំឡេងអតិបរមាសម្រាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន។[44]

**ខ. ការរៀបចំតំបន់បៃតង**

ការរៀបចំឱ្យមានតំបន់បៃតងនៅក្នុងទីក្រុងពិតជាមានសារៈសំខាន់ណាស់ ព្រោះថាប្រជាជនគ្រប់រូប មិនថា ក្មេង ចាស់ ប្រុស ស្រី ឬជនពិការឡើយ តែងតែត្រូវការកន្លែងជួបជុំសម្រាកលំហែបាន។ តំបន់ទាំងនោះត្រូវបានរៀបចំឡើងដោយការលម្អដោយផ្កា ដើមឈើ ឬស្មៅជាដើម។ តំបន់បៃតងនេះ ធ្វើឱ្យការរស់នៅរបស់ប្រជាជនកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវទីកន្លែងធម្មជាតិនៅក្នុងតំបន់ទីក្រុង។ ដោយឡែកការចូលកម្សាន្តក្នុងតំបន់បៃតងនេះ អាជ្ញាធរមិនត្រូវឱ្យប្រជាជន ឬភ្ញៀវទេសចរណ៍បង់ថ្លៃសេវា ដូចនៅតាមរមណីយដ្ឋានឡើយ ហើយអាជ្ញាធរត្រូវរិះរកវិធានការថែទាំតំបន់បៃតងនេះ ឱ្យនៅស្ថិតស្ថេរ និងល្អជានិច្ច។

## ២.២.២. ការរៀបចំខណ្ឌឱ្យមានសណ្តាប់ធ្នាប់ សន្តិសុខ និងហេដ្ឋារចនាសម្ព័ន្ធ

### ២.២.២.១. ទីក្រុងទេសចរណ៍ស្អាត

ខណ្ឌដូនពេញមានផែនការប្លង់មេអភិវឌ្ឍន៍ទីក្រុង ចំពោះការអភិវឌ្ឍរដ្ឋបាលខណ្ឌដូនពេញ កំពុងអនុវត្តទៅតាមកម្មវិធី ៣ឆ្នាំរំកិល និងផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ។ ទាក់ទងនឹងការគ្រប់គ្រងបរិស្ថានសាលាខណ្ឌដូនពេញ បានអនុវត្តដោយផ្អែកទៅលើសេចក្តីណែនាំ គោលនយោបាយ និងប្រកាសរបស់ក្រសួងបរិស្ថាន និងក្រោមការចង្អុលបង្ហាញពីសំណាក់ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ តាមរយៈការផ្សព្វផ្សាយ និងបានបង្កើតការិយាល័យសាធារណការ សណ្តាប់ធ្នាប់ អនាម័យបរិស្ថាន។[45]

ការបំពុលទឹកនៅក្នុងទឹក សាលាខណ្ឌបានចុះផ្សព្វផ្សាយ និងណែនាំដល់ម្ចាស់ទូកទេសចរណ៍ លើការ

[44] មាត្រា៧ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

[45] កំណត់ហេតុ កិច្ចប្រជុំវាយតម្លៃចុងក្រោយសម្រាប់ការវាយតម្លៃទីក្រុងស្អាតលើកទី៣ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២

ចោលសំរាមសំណល់ និងការបន្ទោរបង់ទៅក្នុងទន្លេ ដែលជាហេតុបណ្ដាលឱ្យប៉ះពាល់ដល់បរិស្ថានក្នុងទឹក និងសោភ័ណភាព។

បន្ថែមពីនេះទៅទៀត ការគិតគូរពីបរិស្ថាន ក្រោមការរៀបចំ និងលើកទឹកចិត្តប្រជាពលរដ្ឋក្នុងការកាត់បន្ថយការប្រើប្រាស់យានជំនិះផ្ទាល់ខ្លួន ងាកមកប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ(រថយន្តក្រុង) ដើម្បីចូលរួមចំណែកមិនឱ្យកកស្ទះចរាចរណ៍។

ការប្រើប្រាស់ថាមពលប្រកបដោយនិរន្តរភាព រដ្ឋបាលខណ្ឌបានចុះជំរុញ និងណែនាំឱ្យប្រជាពលរដ្ឋ ប្រើប្រាស់សូឡា និងធ្វើការបំពាក់ប្រព័ន្ធសូឡានៅតាមសង្កាត់ទាំង១១ នៅតាមច្រកចូលភូមិ និងសហគមន៍ក្រីក្រ។

**២.២.២.២. ស្ដីពីភាពស្អាត**

ភាពស្អាតនៅតាមកន្លែងសាធារណៈសំខាន់ៗ ភាពស្អាតនៅតាមបង្គន់សាធារណៈ ភាពស្អាតនៅតាមរមណីយដ្ឋានទេសចរណ៍ ភាពស្អាតនៅតាមមហាវិថីធំៗ និងភាពស្អាតនៅតាមវាលលំហបៃតង និងសួនច្បារសាធារណៈ។ ភាពស្អាតនេះ ក៏ផ្ដោតទៅលើសណ្ដាប់ធ្នាប់ល្អ មានចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើង ចំណីអាហារគ្មានជាតិគីមី និងសន្តិសុខ សុវត្ថិភាពល្អក្នុងខណ្ឌ។ ការបំពាក់ធុងសំរាមចំនួន ១០១ធុង នៅតាមសួនច្បារទាំង ១៨កន្លែង និងមានរៀបចំធុងសំរាមចល័ត (ធុងកញ្ជេរ) តាមសួនច្បារក្នុងឱកាសពិធីបុណ្យធំៗ ដូចជាពេលបុណ្យអុំទូកនាពេលឆ្នាំមុន គឺបំពាក់ធុងសំរាមចល័ត សរុបរហូតដល់ ៥០០។

**២.២.២.៣. ការគ្រប់គ្រងសំណល់**

រដ្ឋបាលខណ្ឌ បានធ្វើការជាមួយសង្កាត់ទាំង១១ និងជាមួយភ្នាក់ងារប្រមូលសំរាមក្រុមហ៊ុន MIZUDA ក្នុងការប្រមូលសំរាម ដែលមានពីរវេន ចាប់ពីម៉ោង ០៦:00 ដល់១៨:00 និងម៉ោង ១៨:00 ដល់០៦:00 ដោយមានភ្នាក់ងារសម្អាតចំនួន ៧៨ នាក់ ធ្វើការផ្លាស់ប្ដូរជា ០២វេន ដោយមានប្រើប្រាស់កង់អាគុយ ម៉ូតូអនាម័យស្វ័យប្រវត្តិ ឡានបោសសំអាតផ្លូវ និងឡានប្រមូលសំរាម។ ទន្ទឹមនឹងនេះ រដ្ឋបាលខណ្ឌបានចុះអប់រំផ្សព្វផ្សាយសេចក្ដីណែនាំអំពីការវេចខ្ចប់ ញែក និងទុកដាក់សំរាម តាមខ្នងផ្ទះ អាជីវកម្ម វត្តអារាម ផ្សារ និងសាលារៀនបានជាប្រចាំ និងបានជំរុញយន្តការគ្រប់គ្រង និងពង្រឹងសេវាប្រមូលសំរាម។[46] ពាក់ព័ន្ធនឹងសំណល់រាវ ក្នុងភូមិសាស្ត្ររបស់ខណ្ឌ មានអាងប្រព្រឹត្តិកម្មសំណល់រាវចំនួន ០៤កន្លែង ដែលជាជំនួយរបស់រដ្ឋាភិបាលជប៉ុនតាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍ JICA មុខមជ្ឈមណ្ឌលអភិវឌ្ឍន៍នៃកម្ពុជា CDC ០១កន្លែង (នៅតាមបណ្ដោយមាត់ទន្លេ) និងក្នុងមូលដ្ឋានខណ្ឌដូនពេញ មានអាងស្ដុកចំរោះទឹក (ទឹកជំនន់) ៣កន្លែង ហើយរដ្ឋបាលខណ្ឌបានស្ដារប្រព័ន្ធអណ្ដូងលូ បាន ៩.២៤៩ម៉ែត្រ ៣៣៩អណ្ដូងលូ។ ដោយអនុវត្តតាមគម្រោងអភិវឌ្ឍន៍ក្រុង(ប្លង់មេ)

[46] កម្មវិធីស្ដីពីសេវាកម្មប្រមូល សម្អាត និងដឹកជញ្ជូនសំរាមក្នុងខណ្ឌដូនពេញ រវាងខណ្ឌដូនពេញ និងក្រុមហ៊ុនMIZUDA

រាល់សំណង់គ្រប់ប្រភេទត្រូវតែមានអាងចំពោះទឹក និងអាងប្រព្រឹត្តកម្មសំណល់រាវ ទើបអនុញ្ញាតច្បាប់សាងសង់ គ្រប់ខ្នងផ្ទះប្រជាពលរដ្ឋសុទ្ធតែបានភ្ជាប់ប្រព័ន្ធទឹកស្អាតប្រើប្រាស់ ១០០%។

**២.២.២.៤. ការបញ្ជ្រាបពីការយល់អំពីកិច្ចការពារបរិស្ថាន និងភាពស្អាត**

តាមរយៈវេទិកាសាធារណៈនៅតាមសង្កាត់ទាំង១១ រដ្ឋបាលខណ្ឌ បានខិតខំអប់រំណែនាំអំពីបញ្ហា សណ្តាប់ធ្នាប់ បរិស្ថាន អនាម័យ ដល់ប្រជាពលរដ្ឋមូលដ្ឋាន អាជីវកម្ម ភ្ញៀវទេសចរណ៍ជាប្រចាំ និងរៀបចំជា យុទ្ធនាការជាសាធារណៈដែលមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ អាជីវករ សហភាពសហព័ន្ធយុវជន កម្ពុជា មន្ត្រីរាជការ ព្រះសង្ឃ ក៏ដូចជាសង្គមស៊ីវិលនានាក្នុងការងារប្រមូលសំរាម និងសម្អាតបរិស្ថាន។ ក្នុង ករណីមិនអនុវត្តតាមការណែនាំ និងអប់រំ សាលាខណ្ឌនឹងអនុវត្តយន្តការផាកពិន័យ ។

| ប្រជាជនមូលដ្ឋានសង្កាត់ទាំង១១ (ជាប្រចាំ) | មូលដ្ឋានអាជីវករ (ជាប្រចាំ) | ភ្ញៀវទេសចរណ៍ (ជាប្រចាំ) | យុទ្ធនាការជាសាធារណៈ (២ដង/ខែ) |
|---|---|---|---|
| • លិខិតរដ្ឋបាល<br>• ខិតប័ណ្ណផ្សេងៗ<br>• តាមរមណីយដ្ឋានទេសចរណ៍នានា<br>• សួនច្បារ កន្លែងសាធារណៈ<br>• វត្តអារាម សាលារៀន<br>• ច្រកចូល និងផ្លូវសំខាន់ៗ<br>• ទីរួមផ្សារ<br>• ចំណតរថយន្តសាធារណៈ | • លិខិតរដ្ឋបាល<br>• អញ្ជើញមកប្រជុំផ្សព្វផ្សាយនៅសាលាខណ្ឌអំពីសេចក្តីណែនាំក្នុងប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ វិធានសុវត្ថិភាពទេសចរណ៍<br>• ចុះត្រួតពិនិត្យដល់ទីតាំងអាជីវកម្ម | • លិខិតរដ្ឋបាល<br>• សួនច្បារមុខវាំង និងរមណីយដ្ឋាននានា<br>• រក្សា៣កុំ៣ការពារ | • ទិវាជាតិទីក្រុងស្អាត<br>• ទីវាបរិស្ថាន<br>• យុទ្ធនាកាអប់រំកម្ពុជាស្អាត<br>• យុទ្ធនាការបឹងឬរ |

**២.២.២.៥. តំបន់បៃតង**

ក្នុងមូលដ្ឋានខណ្ឌដូនពេញ មានសួនច្បារ សួនកុមារ និងតំបន់បៃតង ២៥កន្លែង ដោយមានអង្គភាពសួន ច្បារ ជាអ្នកថែទាំ និងគ្រប់គ្រងតំបន់បៃតង និងសួនច្បារទាំងនេះ។ រដ្ឋបាលខណ្ឌ ក៏បានធ្វើការដាំដើមឈើបន្ថែម នៅសួនច្បារមុខវត្តបទុមវតីបានកែលម្អរង្វង់មូលមុខទូតបារាំង និងសួនច្បារទាំង២០កន្លែង ឱ្យមានភាពស្រស់

ស្អាតជាប្រចាំ និងបានប្តូរអំពូលភ្លើងបំភ្លឺផ្លូវសាធារណៈ និងរមណីយដ្ឋានវត្តភ្នំ។ ដោយសារមូលដ្ឋានខណ្ឌដូនពេញពុំមានដីដាំដំណាំបន្លែ កសិកម្មទេ តែមូលដ្ឋានខណ្ឌដូនពេញ មានទីរួមផ្សារ(ផ្សាររដ្ឋ) ៣កន្លែង ផ្សាររាត្រី ១កន្លែង និងផ្សារទំនើប និងមជ្ឈមណ្ឌលពាណិជ្ជកម្ម ៤កន្លែងដែលមានលក់ និងផ្សព្វផ្សាយផលិតផលក្នុងស្រុក ពិសេសផលិតផលកសិកម្ម។ ហើយក៏បានរៀបចំជាហេដ្ឋារចនាសម្ព័ន្ធសម្រាប់សម្បទានបៃតងដូចជាការបង្កើតឱ្យមានភូមិមួយ ផលិតផលមួយ ជាដើម។[47]

**២.២.២.៦. សុវត្ថិភាពសុខាភិបាល សុវត្ថិភាព និងសន្តិសុខទីក្រុង**

មូលដ្ឋានខណ្ឌដូនពេញមានមណ្ឌលសុខភាព ០១កន្លែង មន្ទីរពេទ្យបង្អែក ០១កន្លែង មន្ទីរពេទ្យធំៗ ០៧កន្លែង និងគ្លីនិកច្រើនកន្លែងទៀត។ រដ្ឋបាលខណ្ឌ បានដាក់ចេញនូវយន្តការអនុវត្តយ៉ាងម៉ឺងម៉ាត់ លើការងារសន្តិសុខចំណីអាហារអនាម័យ និងលិខិតអនុញ្ញាតអាជីវកម្ម នៅតាមអាហារដ្ឋាន និងភោជនីយដ្ឋាន។ ដោយមូលដ្ឋានអាជីវកម្មដែលមានលិខិតបញ្ជាក់អនាម័យ ពិសេសអាហារដ្ឋាន ភោជនីយដ្ឋានលក្ខណៈស្តង់ដារស្ទើរតែ១០០%។ រដ្ឋបាលខណ្ឌបានបំពាក់ប្រព័ន្ធសុវត្ថិភាពគ្រប់ច្រកចេញចូល និងភ្លើងស្តុប ដើម្បីការពារសុវត្ថិភាពភ្ញៀវទេសចរណ៍។ ការពង្រឹងការអនុវត្តតាមគោលនយោបាយភូមិ ឃុំសង្កាត់ មានសុវត្ថិភាព ក្រុមការងារចម្រុះនៃគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌ និងមាននគរបាលទេសចរណ៍ប្រចាំនៅតាមគោលដៅសំខាន់ៗ ហើយតំបន់ដែលមានប្រជាជន និងភ្ញៀវទេសចរច្រើន។

**២.២.២.៧. ហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទ្រទ្រង់ទេសចរណ៍**

ក្នុងភូមិសាស្ត្រខណ្ឌ គឺមានផ្លូវក្រាលបេតុង ៩០ខ្សែ ប្រវែង ១៣.៦៩០ម៉ែត្រ។ ផ្នែកទី២ ទីសាធារណៈ មានសួនសាធារណៈ ២០កន្លែង សួនកុមារ ០២កន្លែង កីឡាដ្ឋាន (កន្លែងលេងកីឡា) ៣៤កន្លែង ពហុកីឡាដ្ឋានជាតិ ០១កន្លែង ទីធ្លាសាធារណៈ ២២កន្លែង មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ ០១កន្លែង ផ្សាររាត្រី ០១កន្លែង។ ផ្នែកទី៣ មានទីរួមផ្សារ ០៣កន្លែង ចំណតរថយន្តឈ្នួល ០៣កន្លែង ចំណតរថយន្តទេសចរណ៍ ០៥កន្លែង។ ផ្នែកទី៤ មាន ០៤កន្លែង រមណីយដ្ឋានទេសចរណ៍ ០៩កន្លែង។ ផ្នែកទី៥ មានអគាររដ្ឋសាធារណៈ រដ្ឋ និងឯកជនគ្រឹះស្ថានសិក្សានានា សណ្ឋាគារ ៨៩កន្លែង ផ្ទះសំណាក់ ១៤៧កន្លែង ផ្ទះស្នាក់នៅរួម ០៦កន្លែង ភោជនីយដ្ឋាន និងអាហារដ្ឋាន ២៤៣កន្លែង បៀរហ្គាឌិន ០៨កន្លែង រង្គសាល ០២កន្លែង ខារ៉ាអូខេ ៤០កន្លែង ឌីស្កូតែក ១៤កន្លែង ម៉ាស្សាសុខភាព ២៦កន្លែង កីឡាទេសចរណ៍ ០៤កន្លែង រថយន្តទេសចរណ៍ ២៣កន្លែង ទីភ្នាក់ងារទេសចរណ៍ ១០៩កន្លែង រមណីយដ្ឋាន និងតំបន់ទាក់ទាញ ០៩កន្លែង។

[47] គោលនយោបាយជាតិ ស្តីពីការជំរុញភូមិមួយ ផលិតផលមួយ ឆ្នាំ២០១៦-២០២៦

## ២.៣. គម្រោងការអភិវឌ្ឍខណ្ឌដូនពេញនាពេលអនាគត

### ២.៣.១. បន្តរៀបចំសណ្តាប់ធ្នាប់ ផ្លូវសាធារណៈ និងកាត់បន្ថយការកកស្ទះចរាចរណ៍

ក្នុងរយៈពេលកន្លងមកនេះ រដ្ឋបាលរាជធានីភ្នំពេញ ពិនិត្យឃើញថា បងប្អូនប្រជាពលរដ្ឋមួយចំនួនដែលជាម្ចាស់លំនៅដ្ឋាន ម្ចាស់សហគ្រាស ម្ចាស់ហាង ម្ចាស់អាជីវកម្ម មន្ទីរពេទ្យ សាលារៀន ស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជនផ្សេងទៀត បាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងដាយផ្លូវមិនទាន់បានសមស្របទាំងស្រុង ឬដោយបំពានលើបទប្បញ្ញត្តិច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ជាពិសេសបំពានលើបទប្បញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់និងបទដ្ឋានគតិយុត្ត ដែលអនុវត្តក្នុងវិស័យនគរូបនីយកម្ម និងសំណង់។ អំពើរំលោភបំពានទាំងនោះមានជាអាទិ៍ ការយកទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងដាយផ្លូវធ្វើជាចំណតយានជំនិះ ការតសំយ៉ាប ការហ៊ុំព័ទ្ធយកចិញ្ចើមផ្លូវ ការយកផ្លូវថ្មើរជើង ឬចិញ្ចើមផ្លូវធ្វើទីតាំងការដ្ឋានទុកដាក់សម្ភារ ឬដាក់តាំងបង្ហាញទំនិញ ឬប្រកបអាជីវកម្មផ្សេងៗជាលក្ខណៈឯកជន ដែលបង្កឱ្យមានការកកស្ទះចរាចរណ៍ និងជះឥទ្ធិពលអវិជ្ជមានដល់សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពរាជធានីភ្នំពេញ។[48]

អនុវត្តតាមស្មារតីនៃកិច្ចប្រជុំគណៈបញ្ជាការឯកភាពកាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ រដ្ឋបាលរាជធានីភ្នំពេញសម្រេចជ្រើសយកផ្លូវសំខាន់ៗចំនួន ១១ខ្សែ ធ្វើជាអាទិភាពគំរូ សម្រាប់អនុវត្តវិធានការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់សាធារណៈ មុននឹងបន្តអនុវត្តចំពោះបណ្តាទីតាំងផ្សេងៗទៀតក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ ផ្លូវអាទិភាពគំរូទាំងនោះរួមមាន៖ ១-មហាវិថីសហព័ន្ធរុស្ស៊ី, ២-មហាវិថីព្រះមុនីវង្ស ៣-មហាវិថីកម្ពុជាក្រោម, ៤-មហាវិថីម៉ៅសេងទុង, ៥-មហាវិថីព្រះសីហនុ និងមហាវិថីនេរុហ៍, ៦-មហាវិថីព្រះនរោត្តម, ៧-មហាវិថីសម្តេចមុនីរ៉េត, ៨-ផ្លូវឧកញ៉ាទេពផន, ៩-មហាវិថីហ្សាលដឺហ្គោល, ១០-មហាវិថីយោធពលខេមរភូមិន្ទ ( ផ្លូវ២៧១) និងផ្លូវឧកញ៉ាឃ្លាំងមឿង (ផ្លូវលេខ៧០) និង ១១-តីរវិថីព្រះស៊ីសុវត្ថិ។

ដូចនេះ ដើម្បីដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវអាទិភាពខាងលើ រដ្ឋបាលរាជធានីភ្នំពេញ ដាក់ចេញនូវសេចក្តីណែនាំដូចខាងក្រោម៖

**ក. ចំពោះបងប្អូនប្រជាពលរដ្ឋ ម្ចាស់លំនៅដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន មន្ទីរពេទ្យ សាលារៀន វិស័យឯកជន អគារសាធារណៈ និងអ្នកប្រើប្រាស់ផ្លូវថ្នល់ ត្រូវអនុវត្តដូចខាងក្រោម៖**

- ហាមចតយានយន្តគ្រប់ប្រភេទនៅលើទ្រូងផ្លូវ
- ហាមដាច់ខាតមិនឱ្យម្ចាស់ការដ្ឋានសំណង់គ្រប់ប្រភេទ ធ្វើការហ៊ុមព័ទ្ធការដ្ឋានលើចិញ្ចើមផ្លូវលើសពី១/៣ (មួយភាគបី) ឬប្រើប្រាស់ទ្រូងផ្លូវដើម្បីទុកដាក់សម្ភារសំណង់របស់ខ្លួន ដូចជា ដែក

[48] សេចក្តីណែនាំលេខ០០៧/១៧ សណន.ច ស្តីពីការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៧

ខ្សាច់ គ្រួសថ្ម ជាដើម។

- រថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ ត្រូវចេញចូលគោរពតាមការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ និងចៀសវាងការប្រើប្រាស់ទ្រូងផ្លូវ ក្នុងការលើកដាក់ ផ្ទេរទំនិញ និងបាញ់បេតុង។ ក្នុងករណីចៀសវាងមិនបាន ត្រូវអនុវត្តការលើកដាក់ទំនិញ និងការបាញ់បេតុងចាប់ពីម៉ោង ២១:០០នាទី រហូតដល់ ម៉ោង០៦:០០នាទីព្រឹក។
- ការរៀបចំសម្ភារ ទំនិញ ម៉ូតូ និងរថយន្តដាក់តាំងលក់ អាចប្រើប្រាស់ចំណីចិញ្ចើមផ្លូវត្រឹម ១/៣ (មួយភាគបី) ជាលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ដោយទុក ២/៣ ( ពីរភាគបី) សម្រាប់ថ្មើរជើង និងបម្រើឱ្យការងារសណ្តាប់ធ្នាប់ និងចរាចរណ៍។
- រាល់ការប្រើប្រាស់ចិញ្ចើមផ្លូវជាទីតាំងផ្ញើកង់ ម៉ូតូ មិនត្រូវឱ្យលើសពី ១/៣ (មួយភាគបី) ឡើយ។

**ខ. ចំពោះគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១៤ ត្រូវអនុវត្តដូចខាងក្រោម៖**

- ត្រូវចុះធ្វើការអប់រំណែនាំដល់ប្រជាពលរដ្ឋ ដែលបាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវ ដោយរំលោភបំពាន ដោយប្រើប្រាស់វិធីសាស្ត្រទន់ភ្លន់ តែម៉ឺងម៉ាត់ ឱ្យចូលរួមអនុវត្តតាមស្មារតីនៃសេចក្តីណែនាំនេះ។ ក្នុងករណីនៅតែមិនអនុវត្តតាមការណែនាំនេះ មន្ត្រីអនុវត្តត្រូវធ្វើកំណត់ហេតុ និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។
- ត្រូវណែនាំដល់ម្ចាស់ទីតាំងភោជនីយដ្ឋាន និងម្ចាស់ទីតាំងអាជីវកម្មនានាឱ្យគោរពតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ក្នុងករណីពុំព្រមអនុវត្តតាម អាជ្ញាធរខណ្ឌត្រូវសហការជាមួយកម្លាំងមានសមត្ថកិច្ច និងជំនាញពាក់ព័ន្ធធ្វើការផាកពិន័យតាមច្បាប់ និងអាចឈានទៅបិទទីតាំងអាជីវកម្ម។
- ត្រូវធ្វើការណែនាំ និងធ្វើកំណត់ហេតុឱ្យបានត្រឹមត្រូវជាមួយម្ចាស់ការដ្ឋានដែលរំលោភបំពានទ្រូងផ្លូវ និងចិញ្ចើមផ្លូវ ក្នុងករណីមិនរាងចាល ត្រូវផ្អាកការដ្ឋាននោះភ្លាម។
- ត្រូវចុះល្បាត និងឃ្លាំមើលជាប្រចាំចំពោះរថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ និងត្រូវមានវិធានការឱ្យបានម៉ឺងម៉ាត់ក្នុងករណីការចេញ-ចូលរាជធានីភ្នំពេញខុសពីសេចក្តីណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ។
- ត្រូវអនុវត្តការងារតាមការណែនាំខាងលើនេះ ឱ្យបានត្រឹមត្រូវ ហ្មត់ចត់ និងទន់ភ្លន់ និងត្រូវរាយការណ៍ប្រចាំសប្តាហ៍អំពីលទ្ធផលនៃការងារនេះ មកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញឱ្យបានទៀងទាត់ និងទាន់ពេលវេលា។

**គ. ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញត្រូវ៖**

- បន្ថែមកម្លាំងនគរបាលចរាចរណ៍ ដោះស្រាយបញ្ហាចរាចរណ៍តាមគោលដៅដែលមានការកកស្ទះ

នៅចន្លោះម៉ោងមមាញឹក គឺម៉ោង ០៧:៣០នាទី ដល់ម៉ោង ០៨:៣០នាទី, ម៉ោង ១១:៣០នាទី ដល់ម៉ោង ១២:៣០នាទី និងម៉ោង ១៧:០០នាទី ដល់ម៉ោង ១៨:៣០នាទី។

- រៀបចំរថយន្តស្ទូច ដើម្បីសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១៤ ដើម្បីអនុវត្តវិធានការច្បាប់។ ទទួលបានសេចក្តីណែនាំនេះ ប្រជាពលរដ្ឋ គ្រឹះស្ថានឯកជន ស្ថាប័នសាធារណៈ និងអ្នកប្រើប្រាស់ផ្លូវ មានរយៈពេល ០២ (ពីរ)សប្តាហ៍ គិតចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះ ដើម្បីធ្វើការកែសម្រួល និងរៀបចំ ទីតាំងរបស់ខ្លួនឱ្យស្របតាមស្មារតីនៃសេចក្តីណែនាំនេះ។
- នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាលខណ្ឌទាំង១៤ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ បងប្អូនប្រជាពលរដ្ឋ អ្នកប្រើប្រាស់ផ្លូវទាំងអស់ត្រូវរួមគ្នាអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

### ២.៣.២. បន្តការណែនាំ និងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩

ការឆ្លងវីរុសកូវីដ-១៩ គឺជារឿងងាយស្រួលណាស់ ក៏ប៉ុន្តែការការពារជំងឺមួយនេះមិនឱ្យរាតត្បាតប៉ះពាល់ដល់ប្រជាជន គឺជារឿងលំបាក។ ដូចនេះ គណៈកម្មាការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩នៃខណ្ឌដូនពេញ មានតួនាទីតាមដានសភាពការណ៍ទាក់ទងនឹងជំងឺកូវីដ-១៩ អំពីសុខភាពសង្គម ព័ត៌មានក្លែងក្លាយ សកម្មភាពជនបំពុលសង្គម តាមដាន និង ស្រង់សំណួរ នឹងឆ្លើយតបយ៉ាងឆាប់រហ័ស តាមរយៈហ្វេសបុកថ្នាក់ដឹកនាំ និងត្រៀមរថយន្តគិលានសង្គ្រោះ សម្រាប់អន្តរាគមន៍សង្គ្រោះបន្ទាន់។[49] ការបញ្ជ្រាបអំពីព័ត៌មានសំខាន់ៗ ពាក់ព័ន្ធនឹងរបៀបការពារថែរក្សាអនាម័យ ការរក្សាគន្លាត គ្រប់ទីកន្លែងមិនថាសាលារៀន មន្ទីរពេទ្យ ទីសាធារណៈទាំងអស់ជាការចាំបាច់។

រដ្ឋបាលខណ្ឌ នៅតែបន្តការណែនាំ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ទៅរហូតមិនឈប់ឈរ ទោះបីជាពេលសព្វថ្ងៃនេះ ជំងឺកូវីដ-១៩ ហាក់បីជាគ្មានសន្ទុះអ្នកឆ្លងបន្តបន្ទាប់ច្រើនក៏ដោយ។ យ៉ាងណាមិញ ទោះបីជាអត្រានៃប្រជាពលរដ្ឋបានទទួលចាក់វ៉ាក់សាំងច្រើនក៏ដោយ ប៉ុន្តែរដ្ឋបាលខណ្ឌនៅតែបន្តផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបន្តគោរពតាមវិធានការសុខាភិបាល រក្សា ៣កុំ និង ៣ការពារ។ ប្រជាពលរដ្ឋត្រូវតែរក្សាអនាម័យ ការពាក់ម៉ាស ការរក្សាគម្លាតសុវត្ថិភាពសង្គម ការយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ការធ្វើចត្តាឡីស័ក ការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល ការធ្វើសេចក្តីប្រកាសសុខភាព និងវិធានការ

[49] ប្រការ២ នៃសេចក្តីសម្រេចលេខ៤៧៣/២០ សសរ.ដព ស្តីពីការបង្កើតគណៈកម្មការប្រយុទ្ធជំងឺកូវីដ-១៩ ខណ្ឌដូនពេញ ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០២២

សុខាភិបាលផ្សេងទៀតដែលចាំបាច់។[50] រដ្ឋបាលខណ្ឌ បានបន្តសកម្មភាពការងារ និងធ្វើរបាយការណ៍ជាប្រចាំខែ ពីចំនួនច្បាស់លាស់ របស់ប្រជាជនដែលវិជ្ជមានប៉ុន្មាននាក់ ទទួលបានការចាក់វ៉ាក់សាំង គ្រប់គ្នាហើយឬនៅ ក្មេងៗ ដល់មនុស្សចាស់ និងការព្យាបាលអ្នកជំងឺនៅមន្ទីរពេទ្យ ឬព្យាបាលនៅតាមផ្ទះជាដើម។ ខាងក្រោមនេះជារបាយការណ៍សម្រាប់ខែមិថុនា ឆ្នាំ២០២២៖

- **អ្នកកើតជំងឺកូវីដ-១៩ និងអ្នកទទួលមរណភាពដោយសារជំងឺកូវីដ-១៩**

**អ្នកមានវិជ្ជមានជំងឺកូវីដ-១៩** គឺមាន ៣.៧៨០នាក់ ស្រី ២.១៦៧នាក់ ក្នុងនោះអ្នកកើត COVID-OMICRON មានចំនួនសរុប ៣២៩នាក់ ស្រី ១៦០នាក់។

១- ពុំមានអ្នកជំងឺ បញ្ជូនទៅព្យាបាលនៅមណ្ឌលព្យាបាលទេ។ ដូចនេះចំនួនសរុបគឺ ៣.៣៨៤នាក់ ស្រី ១.៩៥៥នាក់ ក្នុងនោះអ្នកកើត COVID-OMICRON មានចំនួនសរុប ២៥៨នាក់ ស្រី ១១៧នាក់។

២- ពុំមានអ្នកជំងឺស្នើសុំព្យាបាលជំងឺកូវីដ-១៩ នៅតាមផ្ទះទេ ដូចនេះចំនួនសរុបគឺ ៣៩៦នាក់ ស្រី ២១២នាក់ ក្នុងនោះអ្នកកើត COVID-OMICRON មាន ចំនួន ៧១នាក់ ស្រី ៤៣នាក់។

**អ្នកទទួលមរណភាពដោយសារមានជំងឺកូវីដ-១៩ គឺ**មាន ៩០នាក់ ស្រី៤៣នាក់ ដែលស្លាប់ក្នុងមូលដ្ឋានខណ្ឌដូនពេញ។

- **លទ្ធផលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩៖**

**ការចាក់វ៉ាក់សាំងលើកទី១**

- សម្រាប់កុមារមានអាយុ០៣ឆ្នាំ ដល់ក្រោម០៥ឆ្នាំ មានចំនួនសរុប៖ ០៥នាក់ ស្រី ០៤នាក់។ សរុបបូកយោងមានចំនួន៖ ២,៧២២នាក់ ស្រី ១,៥៨៥នាក់ ។
- សម្រាប់កុមារមានអាយុ០៥ឆ្នាំ (គ្មាន)។ សរុបបូកយោងមានចំនួន៖ ២.៨៣៧នាក់ ស្រី ១.៥៥៤នាក់ ។
- សម្រាប់កុមារមានអាយុ០៦-១២ឆ្នាំ (គ្មាន)។ សរុបបូកយោងមានចំនួន៖ ៨.២៩៥នាក់ ស្រី ៤.២៧៧នាក់។
- ចាប់ពី១២ឆ្នាំឡើងទៅ មានចំនួនសរុប៖ ០១នាក់។ សរុបបូកយោងមានចំនួន៖ ៧៩.១០០នាក់ ស្រី ៣៦.៨៩៥នាក់។

**ការចាក់វ៉ាក់សាំងលើកទី២**

- សម្រាប់កុមារមានអាយុ០៣ឆ្នាំ ដល់ក្រោម០៥ឆ្នាំមានចំនួនសរុប៖ ០៣នាក់ ស្រី ០២នាក់។ សរុប

[50] មាត្រា៣ នៃព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១

បូកយោងមានចំនួន៖ ១.៥៤១នាក់ ស្រី ១៣៦នាក់ ។

- សម្រាប់កុមារមានអាយុ០៥ឆ្នាំ (គ្មាន)។ សរុបបូកយោងមានចំនួន៖ ២.០៧៤នាក់ ស្រី ១.០៦០ នាក់ ។
- សម្រាប់កុមារមានអាយុ០៦-១២ឆ្នាំមានចំនួនសរុប៖ ១២នាក់ ស្រី ០៨នាក់។ សរុបបូកយោងមានចំនួន៖ ៩.៥៧៤នាក់ ស្រី ៥.០៥៩នាក់។
- ចាប់ពី១២ឆ្នាំឡើងទៅ មានចំនួនសរុប៖ ០៥នាក់ ស្រី ០២នាក់។ សរុបបូកយោងមានចំនួន៖ ៦៩.៩៣៣នាក់ ស្រី ៣១.៩០៩នាក់ ។

**ការចាក់វ៉ាក់សាំងដូសទី៣**

- សម្រាប់កុមារមានអាយុ០៣ឆ្នាំ ដល់ក្រោម០៥ឆ្នាំ (គ្មាន)។ សរុបបូកយោងមានចំនួន៖ ០៥នាក់ ស្រី ០០នាក់ ។
- សម្រាប់កុមារមានអាយុ០៦-១២ឆ្នាំ មានចំនួនសរុប៖ ១២នាក់ ស្រី ០៥នាក់។ សរុបបូកយោងមានចំនួន៖ ៤.៧៩៨នាក់ ស្រី ២.៥១៨នាក់។
- ចាប់ពី១២ឆ្នាំ រហូតដល់ក្រោម១៨ឆ្នាំ មានចំនួនសរុប៖ ២០នាក់ ស្រី ០៨នាក់។ សរុបបូកយោងមានចំនួន៖ ៦.២៦៧នាក់ ស្រី ៣.៤០២នាក់។
- ចាប់ពីអាយុ១៨ឆ្នាំឡើងទៅ មានចំនួនសរុប៖ ០៩នាក់ ស្រី ០៥នាក់។ សរុបបូកយោងមានចំនួន៖ ៤០.៤៣៧នាក់ ស្រី ២១.០១៤នាក់ ។

**ការចាក់វ៉ាក់សាំងដូសទី៤**

- ចាប់ពី១២ឆ្នាំ រហូតដល់ក្រោម១៨ឆ្នាំ មានចំនួនសរុប៖ ១២នាក់ ស្រី ០៧នាក់។ សរុបបូកយោងមានចំនួន៖ ២៩៩នាក់ ស្រី ១៥៣នាក់។
- ចាប់ពីអាយុ១៨ឆ្នាំឡើងទៅ មានចំនួនសរុប៖ ៣០នាក់ ស្រី ១៣នាក់។ សរុបបូកយោងមានចំនួន៖ ២៤.១២៩នាក់ ស្រី ១២.៤៤៨នាក់ ។

**ការចាក់វ៉ាក់សាំងដូសទី៥**

- ចាប់ពី១២ឆ្នាំ រហូតដល់ក្រោម១៨ឆ្នាំ (គ្មាន)។ សរុបបូកយោងមានចំនួន៖ ៣៩នាក់ ស្រី ១៧នាក់។
- ចាប់ពីអាយុ១៨ឆ្នាំឡើងទៅ មានចំនួនសរុប៖ ៨១នាក់ ស្រី ៣៦នាក់។ សរុបបូកយោងមានចំនួន៖ ៣២៤នាក់ ស្រី ១៥៦នាក់។[51]

[51] របាយការណ៍លេខ ៨៦០/២២ របក.ដព ស្តីពីសកម្មភាពការងារទប់ស្កាត់ជំងឺកូវីដ-១៩ និងការព្យាបាលជំងឺនៅតាមផ្ទះ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើ សង្កេតឃើញថាខណ្ឌដូនពេញ គឺជាទីពេញចិត្តរបស់ប្រជាជននៅតំបន់នោះ ហើយក៏ជាទីកន្លែងដែលមហាជនទាំងអស់ចង់មករស់នៅដែរ ដោយសារតែខណ្ឌដូនពេញមានទីតាំងសម្រាប់ស្វែងរកការងារគ្រប់ប្រភេទ សាលារៀន មន្ទីរពេទ្យ និងកន្លែងសម្រាប់កម្សាន្តជាច្រើន។ លើសពីនេះទៅទៀត តំបន់មួយនេះមិនដែលធ្វើឱ្យអ្នកដំណើរមានការលំបាកនោះទេ ពេលថ្ងៃអ្នកដំណើរអាចប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈតាមរយៈរថយន្តក្រុង ស៊ីក្លូ ម៉ូតូកង់បី ឬប្រើប្រាស់យានយន្តផ្ទាល់ខ្លួនក៏បាន ចំណែកពេលយប់វិញ នៅតាមដងផ្លូវគឺសុវត្ថិភាព ដងផ្លូវមានភ្លើងពណ៌ស្រស់ស្អាត អាចឱ្យអ្នកដំណើរឆ្លងកាត់បានយ៉ាងងាយស្រួលបំផុតទៀតផង។ ទាំងនេះ គឺជាការរៀបចំការអភិវឌ្ឍមូលដ្ឋានខណ្ឌដូនពេញ ដោយមានការរៀបចំទីក្រុងស្អាត គ្រប់គ្រងបរិស្ថាន ភាពស្អាត គ្រប់គ្រងសំណល់បញ្ជ្រាបការយល់ដឹង តំបន់បៃតង និងខ្សែក្រវ៉ាត់បៃតង សុវត្ថិភាព សុខភាពសាធារណៈ សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង និងហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ ដែលជាមូលដ្ឋានគ្រឹះនៃការរៀបចំខណ្ឌយ៉ាងរឹងមាំ ដើម្បីទទួលបានជ័យលាភី និងពានរង្វាន់នៃទីក្រុងស្អាតប្រចាំទីក្រុងភ្នំពេញ។ ទាំងនេះជាមោទកភាពសម្រាប់ខណ្ឌដូនពេញផ្ទាល់ ក៏ដូចជាការបង្ហាញឱ្យឃើញពីការខិតខំប្រឹងប្រែងរបស់រដ្ឋបាលខណ្ឌ មន្ត្រីពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ និងប្រជាពលរដ្ឋនៅតំបន់នោះផងដែរ។

សរុបសេចក្តីមក ការរៀបចំផែនការត្រឹមត្រូវ និងមានយន្តការសហការគ្នាល្អ ក្នុងការអនុវត្ត និងការទទួលខុសត្រូវច្បាស់លាស់របស់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងយុទ្ធនាការផ្សព្វផ្សាយ។ កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ និងចលនាប្រឡងប្រណាំង « ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ » ពិតជាមានសារៈសំខាន់ខ្លាំងក្នុងការលើកកម្ពស់គុណភាព បរិស្ថាន អនាម័យ និងសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងមូលដ្ឋានខណ្ឌដូនពេញឱ្យបានល្អប្រសើរ។ ទន្ទឹមនឹងនោះការអនុវត្តបានល្អរបស់ខណ្ឌដូនពេញ និងជួយផ្តល់នូវភាពងាយស្រួលដល់រាជធានីភ្នំពេញដើម្បីចូលរួមអនុវត្តឱ្យបានល្អនៅក្នុងការទទួលយកឱ្យបាននូវស្តង់ដារទីក្រុងស្អាតអាស៊ាន ព្រមទាំងរួមចំណែកយ៉ាងសំខាន់ ក្នុងការជំរុញប្រែក្លាយរាជធានីភ្នំពេញឱ្យក្លាយទៅជាទីក្រុងឆ្លាតវៃ និងទីក្រុងទេសចរណ៍ដ៏ល្បីល្បាញស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រទេសចណ៍ជាតិ ក្នុងការអភិវឌ្ឍ ទាក់ទាញភ្ញៀវទេសចរ និងជំរុញកំណើនសេដ្ឋកិច្ចសង្គម ឱ្យកាន់តែរីកចម្រើនប្រកបដោយនិរន្តរភាព។

# អនុសាសន៍

# អនុសាសន៍

តាមការសង្កេតមើលពីស្ថានភាពជាក់ស្តែង ការប្រឡងប្រណាំងទីក្រុងស្អាតនៃខណ្ឌដូនពេញ មានលក្ខណៈល្អប្រសើរណាស់ ដែលគ្រប់បណ្តាក្រុង-ខណ្ឌ ទាំងអស់បានចូលរួម និងប្រកួតប្រជែងយ៉ាងសម្រិតសម្រាំង ក៏ប៉ុន្តែនាងខ្ញុំទាំងពីរយល់ឃើញថា ការប្រឡងប្រណាំងទីក្រុងស្អាតនឹងតែកាន់ល្អប្រសើរលើសឆ្នាំមុនៗទៀត បើសិនខណ្ឌដូនពេញមានការផ្សព្វផ្សាយឱ្យកាន់តែខ្លាំងថែមទៀតទៅលើបញ្ហានេះ នាងខ្ញុំសូមការអនុញ្ញាតធ្វើការបញ្ចេញមតិយោបល់ និងសំណូមពរមួយចំនួនដូចតទៅៈ

- ចូលរួមពង្រឹង និងអនុវត្តបទប្បញ្ញត្តិទាំងឡាយ ដែលមានអានុភាពក្នុងការរៀបចំក្រុង រួមមានដូចជាស្តង់ដារទីក្រុងស្អាត ការគ្រប់គ្រងសម្អាត ប្រមូលសំរាម កាកសំណល់រឹងរាវ ការដោះស្រាយបញ្ហាចរាចរណ៍ជាដើម ដែលប្រកាន់ភ្ជាប់ឱ្យបាននូវការអនុវត្តតាមសេចក្តីប្រកាស ឬសេចក្តីណែនាំផ្សេងៗដែលស្តីពីការថែរក្សាបរិស្ថាន ហើយធានាបាននូវអនាម័យល្អ ដោយគ្មានការបំពុលបរិស្ថានក្រោមរូបភាពណាមួយឡើយ។
- ចូលរួមអនុវត្តគម្រោងរៀបចំតំបន់ថ្មើរជើង និងវិថីលក់ម្ហូបអាហារបន្តទៀត ក្នុងគោលដៅបង្កើតសោភ័ណភាពថ្មី និងបម្រើផលប្រយោជន៍សាធារណៈ មិនមែនយកផ្លូវថ្មើរជើងសម្រាប់បម្រើផលប្រយោជន៍បុគ្គលនោះទេ។
- ប្រតិបត្តិករទេសចរណ៍ខ្លះមិនទាន់យល់ដឹងអំពីចលនាប្រឡងប្រណាំទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងការគ្រប់គ្រងសំណាល់រឹងរាវ ហើយអាជីវករខ្លះក៏មិនទាន់យល់ច្បាស់អំពីទេសចរណ៍ អនាម័យ (វិធានសុវត្ថិភាពសុខាភិបាល) និងគុណភាពសេវាកម្មនៅមានកម្រិតផងដែរ។
- សូមឱ្យធ្វើការផ្សព្វផ្សាយយ៉ាងស៊ីជម្រៅដល់ប្រជាពលរដ្ឋគ្រប់រូបទទួលបានដំណឹង មានចំណេះដឹងនឹងការវេចខ្ចប់ និងការបោះសំរាមក្នុងកន្លែងដាក់សំរាមឱ្យបានត្រឹមត្រូវ មិនគួរឱ្យមានការចោលសំរាមតាមដងផ្លូវ និងទីសាធារណៈនោះទេ។
- អគ្គិភ័យ ក៏ជាបញ្ហាដែលមិនគួរមើលរំលង ពីព្រោះនាងខ្ញុំឃើញថាមានករណីអគ្គិភ័យ ២ទៅ៣ដងក្នុងមួយឆ្នាំ ហើយបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិរដ្ឋ ទ្រព្យឯកជន និងខូចខាតច្រើនទៀតផង ដូចនេះសូមធ្វើការណែនាំ ផ្សព្វផ្សាយប្រជាពលរដ្ឋឱ្យមានការប្រុងប្រយ័ត្នខ្ពស់ ទៅលើបញ្ហាមួយនេះ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១
- ព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១
- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦
- អនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិកាដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២
- អនុក្រឹត្យលេខ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណងរឹង ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥
- អនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០
- សេចក្តីសម្រេចលេខ១០៣/២១ សសរ.អ ស្តីពីការបង្កើតក្រុមវាយតម្លៃទីក្រុងស្អាត រាជធានីភ្នំពេញ ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២១
- សេចក្តីសម្រេចលេខ៦៨៦/២១ សសរ.អ ស្តីពីការបង្កើតក្រុមវាយតម្លៃទីក្រុងស្អាត ខណ្ឌដូនពេញ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១
- សេចក្តីសម្រេចលេខ០០៧/២១ សសរ.អណា៣ ស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធី៣ឆ្នាំរំកិលខណ្ឌដូនពេញ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២១
- ដីកាអមលេខ២៤៧/២១ ដកអ.ដ៣ ស្តីពីការប្រឡងប្រណាំងទីក្រុងស្អាតដែលអនុវត្តវិធានសុវត្ថិភាព និងទេសចរណ៍បានល្អនៃខណ្ឌដូនពេញ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១
- សេចក្តីណែនាំលេខ០០៧/១៧ សណន.ច ស្តីពីការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៧

- គោលនយោបាយជាតិ អំពីការជំរុញចលនាភូមិមួយ ផលិតផលមួយ ឆ្នាំ២០១៦-២០២៦ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧

## ២. សៀវភៅនៃឯកសារ

- សៀវភៅ នីតិរូបនីយវិទ្យា បណ្ឌិត អ៊ុន សកក្កដា ឆ្នាំ២០២០
- វចនានុក្រមខ្មែរ, សម្តេចព្រះសង្ឃរាជជួនណាត
- គោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ឆ្នាំ២០១៦-២០២៦
- ផែនការអភិវឌ្ឍទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញឆ្នាំ២០១៨-២០២២
- កម្រងបទដ្ឋានគតិយុត្តសម្រាប់ទ្រទង់ដំណើរការគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ឆ្នាំ២០១៧
- សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ឆ្នាំ២០១៣
- បរិស្ថានសៀវភៅជំនួយស្មារតី ២០០៥
- កម្មវិធីស្តីពីសេវាកម្មប្រមូល សម្អាត និងដឹកជញ្ជូនសំរាមក្នុងខណ្ឌដូនពេញរវាងខណ្ឌដូនពេញ និងក្រុមហ៊ុនMIZUDA

## ៣. គេហទំព័រ

- គេហទំព័រ www.cambodiacleancity.gov.kh
- គេហទំព័រ http://phnompenh.gov.kh/
- គេហទំព័រ https://www.facebook.com/DaunPenhDistricHall
- គេហទំព័រhttps://www.phnompenhpost.com/national/one-dead-heavy-rains-wreak-havoc-kandal-and-phnom-penh
- គេហទំព័រhttps://www.phnompenhpost.com/post-property/city-hall-reassures-phnom-penh-citizens-flooding
- គេហទំព័រ https://www.propertyarea.asia/archives/83762
- គេហទំព័រ https://www.kampucheathmey.com/local-news/207945

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធរូបភាព

ឧបសម្ព័ន្ធទី១៖ ផែនទីរដ្ឋបាលរាជធានីភ្នំពេញ និងផែនទីរដ្ឋបាលខណ្ឌដូនពេញ

ឧបសម្ព័ន្ធទី២៖ ទីតាំងសំខាន់ៗនៅក្នុងខណ្ឌដូនពេញ និងសោភ័ណភាពខណ្ឌដូនពេញ

ឧបសម្ព័ន្ធទី៣៖ សកម្មភាពរបស់រដ្ឋបាលខណ្ឌដូនពេញ

## ២. ឧបសម្ព័ន្ធគតិយុត្តិ

ឧបសម្ព័ន្ធទី១៖ ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១

ឧបសម្ព័ន្ធទី២៖ ព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១

ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៩

ឧបសម្ព័ន្ធទី៤៖ អនុក្រឹត្យលេខ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩

ឧបសម្ព័ន្ធទី៥៖ អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

ឧបសម្ព័ន្ធទី៦៖ អនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

ឧបសម្ព័ន្ធទី៧៖ អនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិកាដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២

ឧបសម្ព័ន្ធទី៨៖ ដីកាអមលេខ២៤៧/២១ ដកអ.ដព ស្តីពីការប្រឡងប្រណាំងទីក្រុងស្អាតដែលអនុវត្តវិធានសុវត្ថិភាព និងទេសចរណ៍បានល្អនៃខណ្ឌដូនពេញ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១

ឧបសម្ព័ន្ធទី៩៖ សេចក្តីសម្រេចលេខ១០៣/២១ សសរ.អ ស្តីពីការបង្កើតក្រុមវាយតម្លៃទីក្រុងស្អាតរាជធានីភ្នំពេញ ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២១

ឧបសម្ព័ន្ធទី១០៖ សេចក្តីសម្រេចលេខ៦៨៦/២១ សសរ.អ ស្តីពីការបង្កើតក្រុមវាយតម្លៃទីក្រុងស្អាត ខណ្ឌដូនពេញ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១

ឧបសម្ព័ន្ធទី១១៖ សេចក្តីសម្រេចលេខ០០៧/២១ សសរ.អណា៣ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធី៣ឆ្នាំរំកិលខណ្ឌដូនពេញ

ឧបសម្ព័ន្ធទី១២៖ សេចក្តីណែនាំលេខ០០៧/១៧ សណន.ច ស្តីពីការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៧

ឧបសម្ព័ន្ធទី១៣៖ របាយការណ៍លេខ៤៧៩ សជណ ស្តីពីការផ្សព្វផ្សាយគោលនយោបាយជាតិ អំពីការជំរុញចលនាភូមិមួយ ផលិតផលមួយ ឆ្នាំ២០១៦-២០២៦ ចុះថ្ងៃទី១៥ មិថុនា ឆ្នាំ២០១៧

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធទី១៖ ផែនទីរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌដូនពេញ




ផែនទីរដ្ឋបាលរាជធានីភ្នំពេញ



ផែនទីរដ្ឋបាលខណ្ឌដូនពេញ

## ឧបសម្ព័ន្ធទី២៖ ទីតាំងសំខាន់ៗនៅក្នុងខណ្ឌ និងសោភ័ណភាពខណ្ឌ



ទីតាំង៖ សាលារាជធានីភ្នំពេញ



ទីតាំង៖ សាលាខណ្ឌដូនពេញ



ទីតាំង៖ ព្រះបរមរាជវាំង



ទីតាំង៖ វិមានឯករាជ្យ



ទីតាំង៖ រមណីយដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ




ទីតាំង៖ សារមន្ទីរជាតិ



ទីតាំង៖ វត្តឧណ្ណាលោម



ទីតាំង៖ វត្តបទុមវតី



**ទីតាំង៖ ក្រសួងអប់រំ យុវជន និងកីឡា**




**ទីតាំង៖ សាកលវិទ្យាល័យជាតិគ្រប់គ្រង និងវិទ្យាល័យព្រះស៊ីសុវត្ថិ**



**ទីតាំង៖ ធនាគារជាតិនៃកម្ពុជា**



ទីតាំង៖ តុលាការកំពូល



ទីតាំង៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា



ទីតាំង៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

# សោភ័ណភាពស្រស់ស្អាតនៃខណ្ឌដូនពេញ



# ឧបសម្ព័ន្ធទី៣៖ សកម្មភាពរបស់រដ្ឋបាលខណ្ឌដូនពេញ



សកម្មភាព៖ ខណ្ឌដូនពេញជាម្ចាស់ជ័យលាភីទីក្រុងស្អាតផ្ការំដួល៣ទង និងទីក្រុងទេសចរណ៍ស្អាតអាស៊ាន (២០២០-២០២២)



**ឡាបិលទីក្រុងស្អាត**

ផ្ទាំងប៉ាណូអប់រំផ្សព្វផ្សាយអំពីការគ្រប់គ្រង
បរិស្ថាន អនាម័យ និងការទុកដាក់សំរាម
នៅតាមតំបន់ទាក់ទាញទេសចរណ៍ និងផ្សារ











សកម្មភាព៖ រដ្ឋបាលខណ្ឌចុះមូលដ្ឋានផ្ទាល់ ដើម្បីណែនាំដល់ក្រុមការងារសម្អាតសំរាម និងប្រមូលសំរាម



សកម្មភាពៈ កិច្ចប្រជុំផ្សព្វផ្សាយការអនុវត្តសុវត្ថិភាពទេសចរណ៍ដល់មូលដ្ឋានអាជីវកម្ម-សេវាកម្ម និងដឹកនាំក្រុមការងារចុះត្រួតពិនិត្យ និងណែនាំដល់ម្ចាស់អាជីវកម្ម



សកម្មភាពៈ ការពារសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង



សកម្មភាព៖ រដ្ឋបាលខណ្ឌដូនពេញចុះត្រួតពិនិត្យទៅលើប្រភេទរ៉ឺម៉ក់កែច្នៃ និងរថយន្តចតលើផ្លូវសាធារណៈ



សកម្មភាព៖ ក្រុមការងារជួយសម្រួលចរាចរណ៍តាមដងផ្លូវ



សកម្មភាព៖ ផ្តល់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងចុះធ្វើសំណាកជូនប្រជាពលរដ្ឋ



សកម្មភាព៖ គម្រោងការពារទឹកជំនន់អង្គការJICA និងក្រុមការងារចុះពិនិត្យ ស្តារអណ្តូង បណ្តាញលូដែលកកស្ទះដោយសារកាកសំណល់

# ឧបសម្ព័ន្ធគតិយុត្ត

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៦១៤

## ស្តីពី
## ការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ដែលសរសេរអក្សរកាត់ថា **គ.ជ.វ.ទ.** ដើម្បីវាយតម្លៃទីក្រុងស្អាត តាមរយៈការប្រឡងប្រណាំង ក្នុងគោលបំណងលើកកម្ពស់សោភ័ណភាព អនាម័យ បរិស្ថានល្អនៅតាមបណ្តាទីក្រុង ពិសេសចូលរួមធ្វើឲ្យទីក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្លាយជាគោលដៅទេសចរណ៍ ដែលទាក់ទាញ និងប្រកបដោយភាពកក់ក្តៅ។

## ជំពូកទី២

## សមាសភាព

**មាត្រា ២.-**

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន | ០១ រូប | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |
| - ប្រធានគណៈកម្មការគ្រប់គ្រង អភិវឌ្ឍន៍ទេសចរណ៍រាជធានី ខេត្តទាំង២៤ | | សមាជិក |
| - អគ្គលេខាធិការគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត | | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងរបស់ **គ.ជ.វ.ទ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

# ជំពូកទី៣

## តួនាទីនិងភារកិច្ចរបស់ គ.ជ.ទ.ឆ.

មាត្រា ៣.-

**គ.ជ.ទ.ឆ.** មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- អនុវត្តយុទ្ធនាការអប់រំ និងផ្សព្វផ្សាយជាសាធារណៈ អំពីការប្រឡងប្រណាំងទីក្រុងស្អាត
- កំណត់ទម្រង់ និងបែបបទនៃការចុះឈ្មោះ ក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- រៀបចំនិងដាក់ឱ្យដំណើរការ ការប្រឡងប្រណាំងទីក្រុងស្អាត
- វាយតម្លៃទីក្រុងស្អាត ដោយផ្អែកលើស្តង់ដារទីក្រុងស្អាត ដែលជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ
- ចេញស្លាកសញ្ញាផ្លូវការឱ្យទីក្រុងដែលជាជ័យលាភី
- ពិនិត្យនិងតាមដាន ការអនុវត្តរបស់ទីក្រុងជ័យលាភី ក្រោយទទួលបានស្លាកសញ្ញាពី **គ.ជ.ទ.ឆ.**
- ផ្តល់អនុសាសន៍និងណែនាំដល់ទីក្រុងបេក្ខភាព ដែលពុំទាន់បានឆ្លើយតបនឹងលក្ខណវិនិច្ឆ័យ ក្នុងស្តង់ដារទីក្រុងស្អាត
- ដកហូតស្លាកសញ្ញា ពីទីក្រុងជ័យលាភីទាំងឡាយណា ដែលបាត់បង់ ឬមិនគោរពតាមលក្ខណវិនិច្ឆ័យ នៃស្តង់ដារទីក្រុងស្អាត
- រៀបចំនិងធ្វើបច្ចុប្បន្នភាព លើសូចនាករនិងនីតិវិធី ក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- ធ្វើសហការជាមួយនឹងក្រសួង ស្ថាប័ន ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួលការងារខាងលើ ឱ្យកាន់តែមានប្រសិទ្ធភាព
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

# ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់ គ.ជ.ទ.ឆ.

មាត្រា ៤.-

**គ.ជ.ទ.ឆ.** បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។

មាត្រា ៥.-

**គ.ជ.ទ.ឆ.** អាចអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំដើម្បីពិគ្រោះយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយ ដែលទាក់ទងនឹងក្របខណ្ឌការងាររបស់ខ្លួន។

មាត្រា ៦.-

បែបបទនិងនីតិវិធីការងាររបស់ **គ.ជ.ទ.ឆ.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ទ.ឆ.**។

មាត្រា ៧.-

**គ.ជ.ទ.ឆ.** អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ ឬអន្តរជាតិនានាមួយចំនួន តាមការចាំបាច់។

មាត្រា ៨.-

**គ.ជ.ទ.ឆ.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលត្រូវមានទីតាំងស្ថិតនៅក្នុងក្រសួងទេសចរណ៍។

មាត្រា ៩.-

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ឆ.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ឆ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ១០.-

គ.ជ.ទ.ឆ. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥

## ប្រភពធនធាន

មាត្រា ១១.-

គ.ជ.ទ.ឆ. មានប្រភពធនធានផ្គត់ផ្គង់ដោយកញ្ចប់ថវិកាមួយដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងទេសចរណ៍ និងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ព្រមទាំងប្រភពស្របច្បាប់ផ្សេងទៀតសម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

មាត្រា ១២.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៣.-

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១១

នស/រកត.១១០៦.៦៤៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ ៥៩១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន



5/5


ច្បាប់

ស្ដីពី

វិធានការទប់ស្កាត់ការឆ្លងរាលដាល
នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ
និងប្រកបដោយគ្រោះថ្នាក់
ធ្ងន់ធ្ងរផ្សេងទៀត

# ច្បាប់ស្ដីពី

## វិធានការទប់ស្កាត់ការឆ្លងរាលដាល
## នៃជំងឺកូវីដ-១៩
## និងជំងឺឆ្លងកាចសាហាវ
## ត្រូវបានប្រកាស
## ឱ្យប្រើប្រាស់ជាបន្ទាន់

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ**

**នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

ជូន សម្តេចវិបុលសេនាភក្តី **សាយ ឈុំ**
ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចវិបុលសេនាភក្តី ជាទីរាប់អានដ៏ខ្ពង់ខ្ពស់បំផុត និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត

ខ្ញុំបានទទួលរួចហើយ នូវសារលិខិតរបស់ សម្តេចវិបុលសេនាភក្តី ប្រមុខរដ្ឋស្តីទី ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ស្តីអំពីសំណើរបស់ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានសូម សម្តេចវិបុលសេនាភក្តី ប្រមុខរដ្ឋស្តីទី ចេញព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ។

ខ្ញុំយល់ព្រមអនុញ្ញាតជូន សម្តេចវិបុលសេនាភក្តី ប្រមុខរដ្ឋស្តីទី ចុះហត្ថលេខាលើព្រះរាជក្រមតាមសំណើខាងលើនេះ ។

សូម សម្តេចវិបុលសេនាភក្តី ប្រមុខរដ្ឋស្តីទី ទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់បំផុត និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត អំពីខ្ញុំ ។

ន សីហមុនី

**នរោត្តម សីហមុនី**

ធ្វើនៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២១

# ច្បាប់

## ស្ដីពី

## វិធានការទប់ស្កាត់ការឆ្លងរាលដាល
## នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ
## និងប្រកបដោយគ្រោះថ្នាក់
## ធ្ងន់ធ្ងរផ្សេងទៀត

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ព្រះរាជក្រម

## យើង

នស/រកម/០៣២១/០០៤

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .- គោលបំណង**

ច្បាប់នេះកំណត់អំពីវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលត្រូវអនុវត្ត ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្ដាប់ធ្នាប់សាធារណៈ ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងជំងឺនេះ ចំពោះវិស័យសង្គមនិងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .- វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមការកំណត់របស់ក្រសួងសុខាភិបាល។

## ជំពូកទី២
## វិធានការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

**មាត្រា៣ .- វិធានការសុខាភិបាល**

ក្នុងគោលដៅប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលមានសិទ្ធិដាក់ចេញនូវវិធានការសុខាភិបាលចាំបាច់នានា មានជាអាទិ៍៖

- ការធ្វើអនាម័យ
- ការពាក់ម៉ាស
- ការរក្សាគម្លាតសុវត្ថិភាពសង្គម
- ការយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩
- ការធ្វើចត្តាឡីស័ក
- ការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល
- ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
- ការធ្វើសេចក្ដីប្រកាសសុខភាព និង
- វិធានការសុខាភិបាលផ្សេងទៀតដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ខ្លឹមសារលម្អិតនៃវិធានការសុខាភិបាលខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ។

ក្នុងករណីបន្ទាន់និងចាំបាច់ រាជរដ្ឋាភិបាលអាចប្រគល់សិទ្ធិដល់ក្រសួងសុខាភិបាល ដើម្បីដាក់ចេញនូវវិធានការសុខាភិបាលផ្សេងថែមទៀត សំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

**មាត្រា៤ .- វិធានការរដ្ឋបាលនិងវិធានការផ្សេងទៀត**

រាជរដ្ឋាភិបាលអាចដាក់ចេញជាបណ្តោះអាសន្ននូវវិធានការរដ្ឋបាលនិងវិធានការផ្សេងទៀត ដែលមានភាពចាំបាច់និងមានប្រយោជន៍ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា ក្នុងការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មានជាអាទិ៍៖

- ការរឹតត្បិតឬការហាមឃាត់ការធ្វើដំណើរ
- ការរឹតត្បិតឬការហាមឃាត់ការជួបជុំនិងការប្រមូលផ្តុំមនុស្សដែលសកម្មភាពនេះអាចបណ្តាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការហាមឃាត់ឬការកម្រិតការធ្វើសកម្មភាពការងារឬមុខរបរដែលជាហានិភ័យឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការបិទខ្ទប់តំបន់ឬទីកន្លែងមួយចំនួនដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការរឹតត្បិត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង
- វិធានការរដ្ឋបាលនិងវិធានការផ្សេងទៀតដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ក្នុងករណីបន្ទាន់និងចាំបាច់ រាជរដ្ឋាភិបាលអាចប្រគល់សិទ្ធិអំណាចដល់ក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីដាក់ចេញនូវវិធានការខាងលើ និងធានាដល់ការអនុវត្តវិធានការខាងលើ សំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

## ជំពូកទី៣
## ទោសប្បញ្ញត្តិ

**មាត្រា៥ .- ទណ្ឌកម្ម**

បុគ្គលដែលមិនអនុវត្តតាមវិធានការសុខាភិបាល វិធានការរដ្ឋបាល ឬវិធានការផ្សេងទៀត ដែលត្រូវបានដាក់ចេញស្របតាមច្បាប់នេះ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងច្បាប់នេះ។

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន ទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

ទណ្ឌកម្មរដ្ឋបាលរួមមាន៖

- ការព្យួរឬដកហូតអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ការបិទអាជីវកម្ម។

ទណ្ឌកម្មព្រហ្មទណ្ឌរួមមាន៖

- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

បទល្មើសផ្សេងទៀតដែលត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ចំពោះការបំពានវិធានការសុខាភិបាលជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។ ការសម្រេចដាក់ពិន័យអន្តរការណ៍ចំពោះការបំពានវិធានការរដ្ឋបាលនិងវិធានការផ្សេងទៀតជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចដែលចេញវិធានការនោះ។

ការបង់ប្រាក់ពិន័យអន្តរការណ៍រំលត់បណ្តឹងអាជ្ញាចំពោះបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

ការបង់ប្រាក់ពិន័យអន្តរការណ៍មិននាំឱ្យរួចផុតពីកាតព្វកិច្ចអនុវត្តវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលបានដាក់ចេញស្របតាមច្បាប់នេះឡើយ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចស្តីពីការដាក់ពិន័យអន្តរការណ៍ មន្ត្រីដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌នៃក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមនីតិវិធីជាធរមាន។

**មាត្រា៦ .- ក្រសួង ស្ថាប័នមានសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្មរដ្ឋបាល**

ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥នៃច្បាប់នេះ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នដែលចេញអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត។

បុគ្គលដែលមិនសុខចិត្តចំពោះការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលខាងលើ អាចដាក់ពាក្យប្តឹងតវ៉ាទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្តីសម្រេចស្តីពីការដាក់ទណ្ឌកម្មនោះ។

ក្នុងករណីបុគ្គលនោះនៅតែមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ បុគ្គលនោះអាចដាក់ពាក្យប្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្តីសម្រេចលើបណ្តឹងតវ៉ា។

ការដាក់ពាក្យប្តឹងតវ៉ារបស់បុគ្គលខាងលើ មិនមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេចស្តីពីការដាក់ទណ្ឌកម្មនោះទេ។

**មាត្រា៧ .- បទគេចវេះពីការធ្វើចត្តាឡីស័កឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័ក**

អំពើគេចវេះពីការធ្វើចត្តាឡីស័កឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័កក្នុងអំឡុងពេលធ្វើចត្តាឡីស័កដែលកំណត់ដោយក្រសួងសុខាភិបាលឬអាជ្ញាធរមានសមត្ថកិច្ច ត្រូវទទួលពិន័យអន្តរការណ៍តាមការកំណត់នៅក្នុងអនុក្រឹត្យ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល កាលបើអំពើខាងលើនេះបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

**មាត្រា៨ .- បទគេចវេះពីការព្យាបាលឬគេចចេញពីទីកន្លែងព្យាបាល**

អំពើគេចវេះពីការតម្រូវឱ្យទទួលការព្យាបាលឬគេចចេញពីទីកន្លែងព្យាបាល ដែលកំណត់ដោយក្រសួងសុខាភិបាល ឬការប៉ុនប៉ងប្រព្រឹត្តអំពើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ កាលបើអំពើខាងលើនេះបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

**មាត្រា៩ .- បទចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ**

អំពើចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ តាមគ្រប់មធ្យោបាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០(ដប់)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ កាលបើអំពើខាងលើនេះ ត្រូវបានធ្វើឡើងដោយមានការរៀបចំជាក្រុមឬអង្គការចាត់តាំង។

**មាត្រា១០ .- បទមិនគោរពវិធានការរដ្ឋបាល**

ដោយមិនគិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត អំពើដោយចេតនាមិនគោរពវិធានការរដ្ឋបាល ដែលបានដាក់ចេញស្របតាមច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ពី១.០០០.០០០(មួយលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល កាលបើអំពើខាងលើនេះបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល កាលបើអំពើខាងលើនេះបណ្តាលឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ។

**មាត្រា១១ .- បទរារាំងដល់ការអនុវត្តវិធានការ**

អំពើរាំងឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការដែលបានដាក់ចេញស្របតាមច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល កាលបើអំពើខាងលើនេះបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃឬប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ។

**មាត្រា១២ .- ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច**

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់នេះ បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពរូបកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៣ .- ករណីលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវឬទទួលការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ**

ចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៧ មាត្រា៨ មាត្រា១០ និងមាត្រា១១នៃ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច្បាប់នេះ អាចត្រូវលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនបើបុគ្គលនោះបានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាលឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

ការលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌខាងលើ ក៏ត្រូវយកទៅអនុវត្តផងដែរ ក្នុងករណីដែលក្រុមគ្រួសារនៃបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលមានចែងក្នុងមាត្រា៧ មាត្រា៨ មាត្រា១០ និងមាត្រា១១នៃច្បាប់នេះ បានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាលឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

**មាត្រា១៤ .- ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត**

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី៣នៃច្បាប់នេះ មិនរាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី៤
## ការអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

**មាត្រា១៥ .- ការអនុវត្តដូចគ្នានូវបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត**

វិធានការទាំងឡាយ ព្រមទាំងទោសប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ ដើម្បីអនុវត្តចំពោះជំងឺកូវីដ-១៩ ត្រូវមានអានុភាពអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលត្រូវបានកំណត់ដោយក្រសួងសុខាភិបាល ក្រោមវិសាលភាពអនុវត្តនៃច្បាប់នេះ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១៦ .- ការបន្តសុពលភាពនៃលិខិតបទដ្ឋានគតិយុត្តមុនច្បាប់នេះ**

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលច្បាប់នេះចូលជាធរមាន ហើយដែលមិនផ្ទុយនឹងច្បាប់នេះ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៧ .- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨ .- ការប្រកាសជាការប្រញាប់**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ព្រហស្បតិ៍ ១៣រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២១

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាសបទ្ទាប់**
**ប្រមុខរដ្ឋស្តីទី**

[illegible]

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល** **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ម៉ម ប៊ុនហេង** **កើត រិទ្ធ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ** : ៣៦ អ.ន.ក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងសំណល់រឹង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំនត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ :

ក-"**សំណល់រឹង**" គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទីដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតំរូវឱ្យបោះបង់ចោល ។

ខ-"**សំរាម**" គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅស្ថាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ល។

គ-"**សំណល់ប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កអោយមានជំងឺមហារីក ចំលងជំងឺ ធ្វើអោយរលាក ធ្វើអោយច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្មអាជីវកម្មរ៉ែ ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## ការគ្រប់គ្រងសំរាម

**មាត្រា ៤.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី គោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត-ក្រុង របស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេល

មធ្យម និងរយៈពេលវែង ។

**មាត្រា ៥.-**

ការអនុវត្តន៍ក្នុងការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី ១ នៃមាត្រា៥ នេះត្រូវអនុលោមទៅតាមគោលការណ៍ណែនាំលើការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ដែលមានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦.-**

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ក្នុងការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ។

**មាត្រា ៧.-**

ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៨.-**

ការវិនិយោគក្នុងស្រុកលើការសាងសង់កន្លែងចាក់ចោល ដុត ស្តុក ឬកែច្នៃសំរាម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ៩.-**

ការនាំចេញសំរាមពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបានលុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្មព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

**មាត្រា ១០.-**

ហាមឃាត់ជាដាច់ខាត ការនាំសំរាមពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣

## ការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

**មាត្រា ១១.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពីគោលការណ៍ណែនាំ លើការគ្រប់គ្រងសំណល់ ប្រកបដោយគ្រោះថ្នាក់ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាព ។

**មាត្រា ១២.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី កំរិតស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ នៅក្នុងសំណល់ប្រ

កបដោយគ្រោះថ្នាក់ ដែលអាចអនុញ្ញាតអោយបោះបង់ចោល ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស ការការពារគុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ១៣.-**

ម្ចាស់សំណល់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្របនឹងមានសុវត្ថិភាព ។

**មាត្រា ១៤.-**

ម្ចាស់សំណល់ ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទង និងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន :

ក-ប្រភេទ និងបរិមាណសំណល់

ខ-វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ-វិធីសាស្ត្រក្នុងការសំអាតសំណល់ ឬបំបាត់សំណល់ ។

**មាត្រា ១៥.-**

ការទុកដាក់ ស្តុក ដឹកជញ្ជូន និងការបោះចោល ឬចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុវត្តដាច់ដោយឡែកពីសំរាមធម្មតា ដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

ហាមឃាត់ជាដាច់ខាត ការបោះចោល ឬការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភព ឬបណ្តាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ ។

**មាត្រា ១៦.-**

ការប្រមូល ដឹកជញ្ជូន ស្តុក និងការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ តាមលំនៅស្ថាន ទីផ្សារ គ្លីនិកសម្ភព មន្ទីរពេទ្យ សណ្ឋាគារ ភោជនីយដ្ឋាន និងអាគារសាធារណៈ គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តនីវាក្យខ័ណ្ឌទី១ នៃមាត្រា១៦ នេះ ត្រូវអនុលោមទៅតាមប្រកាសរបស់ក្រសួងបរិស្ថាន ស្តីពី គោលការណ៍ណែនាំលើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ១៧.-**

ការដឹកជញ្ជូន ឬសាងសង់ទីកន្លែងចាក់ ឬទីកន្លែងស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ដែលមានប្រភពពីរោងចក្រសហគ្រាស និងមូលដ្ឋានផលិតកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ១៨.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងចាក់ ឬស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងទៅនឹងសំណល់ ដែលបានដឹកយកមកចាក់ចោល ឬស្តុកនៅកន្លែងរបស់ខ្លួន រួមមាន :

ក-ប្រភេទ និងបរិមាណសំណល់

ខ-ប្រភពដើមរបស់សំណល់

គ-ការដឹកជញ្ជូនរបស់សំណល់ និងមធ្យោបាយវេចខ្ចប់

ឃ-ដំណើរការ និងការគ្រប់គ្រងសំណល់នៅក្នុងទីកន្លែងរបស់ខ្លួន ។

**មាត្រា ១៩.-**

ការវិនិយោគលើការធ្វើប្រព្រឹត្តកម្មសំអាត ឬដុតសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវមានការឯកភាពពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ២០.-**

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបាន លុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍នៃអនុសញ្ញាអន្តរជាតិបាសែល ស្តីពីការត្រួតពិនិត្យការដឹកជញ្ជូនអន្តរជាតិ និងការបោះបង់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ឆ្នាំ ១៩៨៩ ដែលចូលជាធរមាននៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩២ ។

**មាត្រា ២១.-**

ហាមឃាត់ជាដាច់ខាត ការនាំចូលសំណល់ប្រកបដោយគ្រោះថ្នាក់ពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៤
## ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច
## លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

**មាត្រា ២២.-**

ការត្រួតពិនិត្យលើការវេចខ្ចប់ ទុកដាក់ ស្តុក ដឹកជញ្ជូន កែច្នៃ ដុត ធ្វើប្រព្រឹត្តកម្មសំអាតជាតិពុល និងការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ២៣.-**

ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ នៅគ្រប់គោលដៅដែលមានចែងក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រា២៣ នេះត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២៤.-**

ការវិភាគគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ ក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចត្រូវយកទៅធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា២៣ នៃអនុក្រឹត្យនេះ អាចសុំធ្វើការវិភាគគំរូតាងសំណល់របស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តនូវវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា២៣ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃវិភាគសំណល់របស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំណូលនេះ ត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៥.-**

ក្នុងករណីដែលរកឃើញថា មានការលួចចាក់ចោល ឬបោះចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតិពីស្ថាប័នមានសមត្ថកិច្ច ក្រសួងបរិស្ថាន សហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រូវចុះធ្វើអធិការកិច្ចដល់ទីកន្លែងនោះ ដោយអនុវត្តន៍តាមនីតិវិធី ដែលមានចែងខាងក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬទីកន្លែងនោះ ដើម្បីធ្វើអធិការកិច្ច និងយកគំរូតាង ។

ខ-ត្រូវធ្វើនៅនឹងកន្លែង នូវកំណត់ហេតុ និងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ-ត្រូវសាកសួរ និងតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ផ្តល់នូវពតិមាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ ឬកំណត់ហេតុ និងសំរាប់ជាវត្ថុតាង ។

ឃ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ។

**មាត្រា ២៦.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា មានស្តុកទុក ឬការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់បណ្តាលអោយប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលបរិស្ថាន ក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ ហើយត្រូវជូនពតិមានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ២៧.-**

ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោសដោយយោងទៅតាម មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ២៨.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមសមគំនិត នឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនោះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

**មាត្រា ២៩.-**

កំណត់ហេតុ និងការធ្វើបណ្តឹង ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។

## ជំពូកទី ៦
## អវសានបញ្ញត្តិ

**មាត្រា ៣០.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា ៣២.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣១

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

## តារាងឧបសម្ព័ន្ធ

## ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

១-សំណល់សរសៃអំបោះ និងកំទេចក្រណាត់ដែលមានពណ៌ ( ក្នុងករណីយកទៅដុត) ។

២-សំណល់កំទេចក្រដាស ដែលសល់ពីការផលិតម្សៅក្រដាស ។

៣-សំណល់ភក់ ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តកម្មសំអាចសំណល់រាវ និងទឹកល្វ ។

៤-សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡឧស្សាហកម្ម ។

៥-សំណល់ប្លាស្ទិច "ប៉ូលីវីនីក្លរ" ។

៦-សំណល់សារធាតុជ័រប៉ូលីក្លរីណេតទីតប៊ីផេនីល (PCB) នៃម៉ាស៊ីនត្រជាក់ ទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ។ល ។

៧-សំណល់ជ័រ និងកៅស៊ូដែលមានសារធាតុប៉ូលីម៉ែប៉ុយទីលីន

៨-សំណល់ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន

៩-សំណល់ដែលមានផ្ទុកជាតិអាស៊ីត

១០-សំណល់ដែលមានផ្ទុកជាតិបាស

១១-សំណល់លោហៈ និងសមាសធាតុរបស់វារួមមាន :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម(Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរិយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |
| បារត (Hg) | កាត់ម្យូម (Cd) | ដែក (Fe) | |

១២-លំអងផ្សែង និងធូលីដែលកើតមានក្នុងករណីសំអាតផ្សែងបញ្ចេញពីមូលដ្ឋានផលិតកម្ម

១៣-សំណល់អំពូលអគ្គីសនី និងបន្ទះប្រព័ន្ធគ្រឿងអេឡិចត្រូនិចអគ្គីសនី

១៤-សំណល់អាគុយ និងថ្មពិល

១៥-សំណល់ថ្នាំលាប និងថ្នាំជ្រលក់ពណ៌ និងសំភារៈវេចខ្ចប់ថ្នាំពណ៌

១៦-សំណល់បានមកពីការផលិត និងការប្រើប្រាស់ទឹកខ្មៅបោះពុម្ព

១៧-សំណល់គ្រឿងផ្ទុះ

១៨-សំណល់ដែលនាំអោយមានការចំលងមេរោគ ឬជំងឺ

១៩-សំណល់ដែលសល់ពីការផលិតថ្នាំពុលកសិកម្ម និងសំភារៈវេចខ្ចប់

២០-សំណល់ផេះនៃឡដុតសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់

២១-ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់

២២-សំណល់ហ្វីល ដូចជាហ្វីលភាពយន្ត វីដេអូ ហ្វីលកាសែតចំរៀង ហ្វីលថតរូប និងហ្វីលថតសរីរាង្គមនុស្សតាមមន្ទីរពេទ្យ

២៣-សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសំអាតដីកខ្វក់ ឬដីខូចគុណភាព

២៤-សំណល់ដែលបានមកពីការផលិតឱសថ និងឱសថដែលខូចគុណភាព

២៥-សំណល់ដែលជាសមាសធាតុសរីរាង្គក្លរអរីន

២៦-សំណល់ដែលជាសមាសធាតុស៊ីអានីត

២៧-សំណល់ដែលជាសមាសធាតុអាសបេតូស

២៨-សំណល់ដែលជាសមាសធាតុផេណុល ($C_6H_5OH$)

២៩-សំណល់ដែលជាសមាសធាតុអេទែ ($R\text{-}COO\text{-}R_1$)

៣០-សំណល់ដែលជាសារធាតុសរីរាង្គរំលាយដែលមានអាឡូសែន និងគ្មានអាឡូសែន

៣១-សំណល់ដែលជាសមាសធាតុឌីអុកស៊ីន និងហ្វូរ៉ាន

៣២-សំណល់ធាតុវិទ្យុសកម្ម

៣៣-សារធាតុដែលជាផលិតផលបានមកពីការធ្វើប្រព្រឹត្តកម្មសំអាតសំណល់ ដែលមានចែងពីចំនុចទី១ ដល់ទី៣២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ** : ២៧ អ.ន.ក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការត្រួតពិនិត្យការបំពុលទឹក

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ និងការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៩ ។

## **សំរេច**

## **ជំពូកទី ១**

## **បទបញ្ញត្តិទូទៅ**

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់សាធារណៈ ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក-"**តំបន់ទឹកសាធារណៈ**" គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា : ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំងប្រព័ន្ធប្រឡាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី ។

ខ-"**ប្រភពបំពុល**" គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ

គ-"**សំណល់រាវ**" គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី ។

ឃ-"**ទឹកលូ**" គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ ។

ង-"**សំណល់រឹង**" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល ។

ច-"**សំរាម**" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ ។

ឆ-"**សារធាតុបំពុល**" គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទដែលធ្វើឱ្យមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា ធ្វើឱ្យប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចោលចូលទៅក្នុងទឹកដោយចេតនាក្តី ឬអចេតនាក្តី ។

ជ-"**បរិមាណសារធាតុបំពុល**" គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ-"**សារធាតុប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមានគ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលអោយប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសំណល់ និងសារធាតុប្រកបដោយគ្រោះថ្នាក់

### មាត្រា ៤.-

ក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

### មាត្រា ៥.-

ក្នុងករណីចាំបាច់ និងតំរូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្សជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក សំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

ក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

### មាត្រា ៦.-

ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ ។

### មាត្រា ៧.-

ក្រសួងបរិស្ថាន ត្រូវរៀបចំក៏រិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតឱ្យបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និង ការអភិរក្សជីវៈចំរុះ ។

ក៏រិតស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

### មាត្រា ៨.-

ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹក

សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ហាមឃាត់ជាដាច់ខាតនូវការទុកដាក់ ឬការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលនាំឱ្យមានការបំពុលទឹកតំបន់ទឹកសាធារណៈ ។

**មាត្រា ៩.-**

ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសំអាតនានា ។

## ជំពូកទី ៣

## ការសុំអនុញ្ញាតបញ្ចេញសំណល់រាវ

**មាត្រា ១០.-**

ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១១.-**

ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ហើយដែលចែកចេញជាពីរប្រភេទ ដូចតទៅ :

ក-ប្រភពបំពុលប្រភេទថ្នាក់ទី១ តំរូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង ១០ ម៉ែត្រគូបក្នុងមួយថ្ងៃដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សំរាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ ។

ខ-ប្រភពបំពុលប្រភេទថ្នាក់ទី២ ចាំបាច់តំរូវអោយមានការសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ។

**មាត្រា ១២.-**

ការសុំអនុញ្ញាតលើការបញ្ចេញចោល ឬការដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុល ទាំងគំរោងថ្មី និងទាំងគំរោងកំពុងដំណើរការ លើកលែងតែគំរោងប្រភពបំពុលថ្មី ដែលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោងនោះត្រូវបានអនុម័ត នឹងត្រូវបានរួចផុតពីការតំរូវឱ្យសុំការអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ។

**មាត្រា ១៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកាន់កន្លែងដទៃ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

-អោយបានមុន ៤០ថ្ងៃសំរាប់គំរោងនៅភ្នំពេញ និង ៦០ថ្ងៃ សំរាប់គំរោងនៅតាមខេត្ត ក្រុងនៃការចាប់ផ្តើម

ដំណើរការ សំរាប់ប្រភពបំពុលដែលជាគំរោងថ្មី ។

-អោយបានក្នុងរយៈពេល ៣០ថ្ងៃ សំរាប់ប្រភពបំពុលនៅភ្នំពេញ និង ៥០ថ្ងៃសំរាប់ប្រភពបំពុលនៅតាមខេត្ត ក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សំរាប់ប្រភពបំពុលដែលកំពុងដំណើរការ ។

**មាត្រា ១៤.-**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកាន់កន្លែងដទៃ នឹងត្រូវបានផ្តល់ជូន ប្រសិនបើបែបបទនៃការសុំអនុញ្ញាតនោះត្រូវបានបំពេញទៅតាមគោលការណ៍ណែនាំបច្ចេកទេស ដែលកំនត់ដោយក្រសួង បរិស្ថាន ។

**មាត្រា ១៥.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដែលទទួលបានការអនុញ្ញាតពីក្រសួងបរិស្ថានអោយបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃ ហើយមានបំណងចង់ធ្វើការផ្លាស់ប្តូរប្រព័ន្ធបញ្ចេញសំណល់រាវរបស់ខ្លួន ត្រូវដាក់ពាក្យ សុំការអនុញ្ញាតជាថ្មី ទៅក្រសួងបរិស្ថានអោយបានមុន ៣០ថ្ងៃ នៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូរ ។

**មាត្រា ១៦.-**

បុគ្គលដែលជួល ឬអ្នកកាន់កាប់បន្តប្រភពបំពុលពីម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើមដែលបានទទួលការ អនុញ្ញាតពីក្រសួងបរិស្ថានឱ្យបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃត្រូវអនុវត្តបន្តអោយបានត្រឹមត្រូវនូវចំនុច ដែលបានកំណត់នៅក្នុងពាក្យសុំការអនុញ្ញាត ដែលម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើម បានដាក់ជូនទៅក្រសួង បរិស្ថាន ។

ម្ចាស់កម្មសិទ្ធិថ្មី ឬអ្នកទទួលខុសត្រូវថ្មីនៃប្រភពបំពុល ត្រូវផ្តល់សេចក្តីជូនដំណឹងពីការជួល ឬការកាន់កាប់បន្ត របស់ខ្លួនទៅក្រសួងបរិស្ថាន ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ ក្រោយពីមានការជួល ឬកាន់កាប់បន្តនោះ ។

**មាត្រា ១៧.-**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃ ដែលបានផ្តល់ជូនទៅឱ្យ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នឹងត្រូវបានដកហូតជាបណ្តោះអាសន្ន ឬជាស្ថាពរ បន្ទាប់ពីមានការពិគ្រោះ យោបល់ជាមុនជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ប្រសិនបើម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះប្រព្រឹត្ត ល្មើសធ្ងន់ធ្ងរ និងមាត្រាណាមួយនៃមាត្រា ១៤ មាត្រា ១៥ ឬមាត្រា ១៦ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤

## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន

**មាត្រា ១៩.-**

ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់រាវ នៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២០.-**

ការវិភាគគំរូតាងសំណល់រាវ ដែលយកបានមកពីប្រភពបំពុលក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ត្រូវធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២១.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវបង់ថ្លៃវិភាគសំណល់រាវរបស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំនូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជូនទានបរិស្ថាន ។

**មាត្រា ២២.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសំណល់រាវរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២៣.-**

ចំពោះប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវ :

- ក-ទទួលខុសត្រូវក្នុងការកំណត់យកនូវវិធីសាស្ត្រធ្វើប្រព្រឹត្តកម្មសំអាតនិងបញ្ចេញសំណល់រាវរបស់ខ្លួន ដើម្បីឱ្យឆ្លើយតបទៅ និងក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ និងក៏រិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។
- ខ-មានសំភារៈ និងមធ្យោបាយគ្រប់គ្រាន់សំរាប់រារាំង ឬទប់ស្កាត់ការបំពុលតំបន់ទឹកសាធារណៈនៅពេលដែលមានគ្រោះថ្នាក់ដោយចៃដន្យបង្កឡើងពីប្រភពបំពុលរបស់ខ្លួន ។
- គ-ទទួលខុសត្រូវក្នុងការដំឡើងឧបករណ៍ សំរាប់ធ្វើការវាស់នូវចរន្តហូរ កំហាប់ និងបរិមាណសារធាតុបំពុលដែលមាននៅក្នុងសំណល់រាវរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ។ លទ្ធផលនៃការវាស់ស្ទង់ ត្រូវធ្វើជារបាយការណ៍មកកាន់ក្រសួងបរិស្ថានរៀងរាល់ ៣ខែម្តង ។

**មាត្រា ២៤.-**

ក្នុងករណីដែលរកឃើញថា ការបញ្ចេញសំណល់រាវពីប្រភពបំពុលណាមួយ ពុំបានឆ្លើយតបទៅ និងក៏រិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ ឬពុំឆ្លើយតបទៅ និងក៏រិតស្តង់ដារបរិមាណសារធាតុ

បំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ក្រសួងបរិស្ថានត្រូវ :

ក-ចេញបញ្ជាជាលាយលក្ខណ៍អក្សរ តម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់ណាមួយ ប្រសិនបើសកម្មភាពល្មើសនោះមិនទាន់បង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

ខ-ចេញបញ្ជាជាលាយលក្ខណ៍អក្សរ តម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្ន រហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

## ជំពូកទី ៥
## ការត្រួតពិនិត្យការបំពុលទឹក
## នៅតាមតំបន់ទឹកសាធារណៈ

### មាត្រា ២៥.-

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹកមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៤ នៃអនុក្រឹត្យនេះ ។

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹសាធារណៈ សំរាប់ការពារសុខភាពសាធារណៈមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៥ នៃអនុក្រឹត្យនេះ ។

### មាត្រា ២៦.-

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យ តាមដានជាប្រចាំពីស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

### មាត្រា ២៧.-

ក្រសួងបរិស្ថាន ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតំលៃពីស្ថានភាពគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២៨.-

ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាពទឹក និងស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២៩.-

ក្នុងករណីរកឃើញថា តំបន់ទឹកសាធារណៈត្រូវទទួលរងការបំពុល ដែលបង្កអោយមានការគំរាមកំហែងដល់ជីវិតមនុស្ស ឬជីវៈចំរុះ ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់នេះ និងត្រូវចាត់

វិធានការទប់ស្កាត់ការបំពុលទឹក និងស្តារនូវគុណភាពទឹកតំបន់ទឹកសាធារណៈនោះ ។

## ជំពូកទី ៦

## នីតិវិធីនៃការធ្វើអធិការកិច្ច

**មាត្រា ៣០.-**

នៅពេលចុះធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន ត្រូវអនុវត្តន៍តាមនីតិវិធីដូចចែងខាងក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកម្មរបស់ខ្លួន នៅពេលចូលក្នុងបរិវេណ ឬទីកន្លែងប្រភពបំពុលដើម្បីអធិការកិច្ច យកគំរូតាង ឬពិនិត្យកត់ត្រា

ខ-កំណត់ហេតុ និងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុ សំរាប់ប្រើប្រាស់ជាវត្ថុតាង

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣១.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបង្ហូរបញ្ចេញនូវសំណល់រាវ ដែលមានផ្ទុកសារធាតុពុល បង្កឱ្យមានគ្រោះថ្នាក់សុខភាពមនុស្សសត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិចូលធ្វើអធិការកិច្ច នៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣២.-**

ក្នុងករណីមានឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយ នៃការបំពុលទឹកនៅតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣៣.-**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កឱ្យមានការបំពុលទឹក មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូល ឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនទាន់បង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

ខ-ប្រមូល និងឃាត់ទុកភស្តុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្សសត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

## ជំពូកទី ៧

## ទោសបញ្ញត្តិ

**មាត្រា ៣៤.-**

ការរំលោភល្មើសទៅ និងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣៥.-**

កំណត់ហេតុចោទប្រកាន់បទល្មើស ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តន៍តាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៦.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិត និងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨
## អវសានបញ្ញត្តិ

**មាត្រា ៣៧.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៩.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣៨

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

## តារាងឧបសម្ព័ន្ធ ១

## ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់

១-សមាសធាតុសរីរាង្គអាឡូសែន និងសារធាតុដែលអាចបង្កើតបានជាសមាសធាតុសរីរាង្គអាឡូសែនទាំងនោះ នៅក្នុងបរិស្ថានទឹក

២-សមាសធាតុសរីរាង្គផូស្វរ

៣-សមាសធាតុសរីរាង្គទីន

៤-សារធាតុដែលបង្កអោយមានជំងឺមហារីក

៥-បារត និងសមាសធាតុរបស់វា

៦-កាត់ម្ញូម និងសមាសធាតុរបស់វា

៧-សមាសធាតុប្រេងអសរីរាង្គដែលមិនបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

៨-សមាសធាតុសំយោគដែលមិនបំបែកធាតុ ដែលអាចអណ្តែតនៅលើផ្ទៃទឹក រឺលិចក្នុងទឹកហើយដែលអាចជ្រាបចូលទៅក្នុងការប្រើប្រាស់ទឹក

៩-សារធាតុវិទ្យុសកម្ម

១០-លោហៈ និងសមាធាតុ របស់វាដូចជា :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម(Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរិយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |

១១-សមាសធាតុសរីរាង្គពុលមិនបំបែកធាតុស៊ីលីស្យូម

១២-សមាសធាតុអសរីរាង្គផូស្វរ

១៣-សមាសធាតុប្រេងជាអសរីរាង្គបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

១៤-សមាសធាតុស៊ីអានីត និងភ្លុយអរ

១៥-សារធាតុដែលមានឥទ្ធិពលលើអុកស៊ីសែន ដូចជា អាម៉ូញ៉ាក់ នីទ្រីត ។ល។

## តារាងឧបសម្ព័ន្ធ ២

កំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ពីប្រភពបំពុលចូលទៅ

ក្នុងតំបន់ទឹកសាធារណៈ ឬទៅក្នុងប្រព័ន្ធបណ្តាញលូ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | បរិមាណសារធាតុបំពុលដែលអាចអនុញ្ញាតឱ្យបញ្ចេញ | |
|---|---|---|---|---|
| | | | តំបន់ទឹកសាធារណៈដែលត្រូវបានការពារ | តំបន់ទឹកសាធារណៈនិងលូ |
| 1 | សីតុណ្ហភាព | $^{0}C$ | <45 | <45 |
| 2 | pH | | 6-9 | 5-9 |
| 3 | $BOD_5$ | mg/l | <30 | <80 |
| 4 | COD | mg/l | <50 | <100 |
| 5 | សារធាតុរឹងអណ្តែតក្នុងទឹក | mg/l | <60 | <120 |
| 6 | សារធាតុរឹងដែលរលាយក្នុងទឹក | mg/l | <1000 | <2000 |
| 7 | ប្រេង ឬខ្លាញ់ | mg/l | <5.0 | <15 |
| 8 | សាប៊ូ | mg/l | <5.0 | <15 |
| 9 | ផេណុល | mg/l | <0.1 | <1.2 |
| 10 | នីត្រាត | mg/l | <10 | <20 |
| 11 | ក្លរក្នុងទំរង់សេរី | mg/l | <1.0 | <2.0 |
| 12 | ក្លរជាអ៊ីយ៉ុង | mg/l | <500 | <700 |
| 13 | ស៊ុលផាត | mg/l | <300 | <500 |
| 14 | ស៊ុលហ្វីត | mg/l | <0.2 | <1.0 |
| 15 | ផូស្វាត | mg/l | <0.3 | <6.0 |
| 16 | ស៊ីអានីត ($CN^{-1}$) | mg/l | <0.2 | <1.5 |
| 17 | បារ្យ៉ូម (Ba) | mg/l | <4.0 | <7.0 |
| 18 | អាសេនិច (As) | mg/l | <0.10 | <1.0 |
| 19 | សំណប៉ាហាំង(Sn) | mg/l | <2.0 | <8.0 |
| 20 | ដែក (Fe) | mg/l | <1.0 | <20 |
| 21 | បរ(B) | mg/l | <1.0 | <5.0 |
| 22 | ម៉ង់កាណែស(Mn) | mg/l | <1.0 | <5.0 |
| 23 | កាត់ម្ញ៉ូម(Cd) | mg/l | <0.1 | <0.5 |

| | | | | |
|---|---|---|---|---|
| 24 | ក្រូម(Cr)$^{+3}$ | mg/l | <0.2 | <1.0 |
| 25 | ក្រូម(Cr)$^{+6}$ | mg/l | <0.05 | <0.5 |
| 26 | ទង់ដែង(Cu) | mg/l | <0.2 | <1.0 |
| 27 | សំណ(Pb) | mg/l | <0.1 | <1.0 |
| 28 | បារត(Hg) | mg/l | <0.002 | <0.05 |
| 29 | នីកែល(Ni) | mg/l | <0.2 | <1.0 |
| 30 | សេលេញ៉ូម(Se) | mg/l | <0.05 | <0.5 |
| 31 | ប្រាក់(Ag) | mg/l | <0.1 | <0.5 |
| 32 | ស័ង្កសី(Zn) | mg/l | <1.0 | <3.0 |
| 33 | ប៉ូលីបដែន(Mo) | mg/l | <0.1 | <1.0 |
| 34 | អាម៉ូញាក់($NH_3$) | mg/l | <5.0 | <7.0 |
| 35 | អុកស៊ីសែនដែលរលាយក្នុងទឹក | mg/l | >2.0 | >.1.0 |
| 36 | ប៉ូលីក្លរ៉ូ បីផេនីល(PCB) | mg/l | <0.003 | <0.003 |
| 37 | កាល់ស្យូម(Ca) | mg/l | <150 | <200 |
| 38 | ម៉ាញ៉េស្យូម(Mg) | mg/l | <150 | <200 |
| 39 | កាបូនតេត្រាក្លរួ | mg/l | <3 | <3 |
| 40 | អ៊ិចសាក្លរបង់សែន | mg/l | <2 | <2 |
| 41 | ដេដេតេ | mg/l | <1,3 | <1,3 |
| 42 | អង់ទ្រីន | mg/l | <0,01 | <0,01 |
| 43 | ឌីអលទ្រីន | mg/l | <0,01 | <0,01 |
| 44 | អេនទ្រីន | mg/l | <0,01 | <0,01 |
| 45 | អ៊ីសូទ្រីន | mg/l | <0,01 | <0,01 |
| 46 | ពែក្លរអេទីឡែន | mg/l | <2,5 | <2,5 |
| 47 | អ៊ិចសាក្លរប៊ុយតាឌីអែន | mg/l | <3 | <3 |
| 48 | ក្លរហ្វម | mg/l | <1 | <1 |
| 49 | 1,2 ឌីក្លរអេទីឡែន | mg/l | <2,5 | <2,5 |
| 50 | ទ្រីក្លរអេទីឡែន | mg/l | <1 | <1 |
| 51 | ទ្រីក្លរបង់សែន | mg/l | <2 | <2 |
| 52 | អ៊ិចសាក្លរស៊ីក្លូអ៊ិចសែន | mg/l | <2 | <2 |

***កំណត់សំគាល់*** : ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការរៀបចំក៏រិតកំណត់ស្តង់ដារថ្នាំពុលកសិកម្ម ដែលបញ្ចេញពីប្រភពបំពុល ។

## តារាងឧបសម្ព័ន្ធ ៣

ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយមានការសុំអនុញ្ញាតិពីក្រសួងបរិស្ថាន

មុននឹងបញ្ចេញចោលនូវសំណល់រាវរបស់ខ្លួន ឬដឹកទៅទីដទៃ

| ល.រ | ប្រភេទប្រភពបំពុល | កំរិតថ្នាក់ប្រភេទ |
|---|---|---|
| 1 | -ទីតាំងផលិតអាហារ និងសាច់កំប៉ុង | ទី១ |
| 2 | -ទីតាំងផលិតបន្លែ និងផ្លែឈើកំប៉ុង | ទី១ |
| 3 | -ទីតាំងកែច្នៃផលនេសាទ | ទី១ |
| 4 | -ទីតាំងក្លាសេ និងបង្កក | ទី១ |
| 5 | -ទីតាំងផលិតម្សៅមី | ទី១ |
| 6 | -ទីតាំងផលិតស្ករស | ទី១ |
| 7 | -ទីតាំងផលិតទឹកស្អាត | ទី១ |
| 8 | -ទីតាំងផលិតស្នូនរបស់ប្រើប្រាស់ពីដី | ទី១ |
| 9 | -ទីតាំងផលិតភេសជ្ជៈ និងស្រាបៀរ | ទី១ |
| 10 | -ទីតាំងផលិតអាល់កុល និងស្រា | ទី១ |
| 11 | -ទីតាំងផលិតចំណីសត្វ | ទី១ |
| 12 | -ទីតាំងផលិតប្រេង និងខ្លាញ់ | ទី១ |
| 13 | -ទីតាំងផលិតដំបែ និងមេស្រា | ទី១ |
| 14 | -ទីតាំងផលិតនំ និងស្ករគ្រាប់ | ទី១ |
| 15 | -ទីតាំងផលិតបារី | ទី១ |
| 16 | -ទីតាំងកាត់ដេរគ្មានក្រឡុកបោក | ទី១ |
| 17 | -សណ្ឋាគារ | ទី១ |
| 18 | -ភោជនីយដ្ឋាន | ទី១ |
| 19 | -ទីតាំងកសិដ្ឋានចិញ្ចឹមសត្វ | ទី១ |
| 20 | -ទីតាំងសត្តឃាត | ទី១ |
| 21 | -ទីតាំងយានដ្ឋាន និងកន្លែងលាងរថយន្ត | ទី១ |
| 22 | -ទីតាំងមជ្ឈមណ្ឌលលក់ដុំ និងទីផ្សារ | ទី១ |
| 23 | -ទីតាំងមន្ទីរពេទ្យ និងសម្ភព | ទី១ |
| 24 | -ទីតាំងផលិតរបស់ផ្លាស្ទិក-កៅស៊ូកង់ | ទី១ |
| 25 | -ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវលំនៅស្ថាន | ទី១ |
| 26 | -ទីតាំងផលិតជ័រការ | ទី១ |
| 27 | -ទីតាំងបង្អក និងកែច្នៃជ័រកៅស៊ូ | ទី១ |

| | | |
|---|---|---|
| 28 | -ទីតាំងផលិតកែវ-ដប | ទី១ |
| 29 | -ទីតាំងផលិតស៊ីម៉ងត៍ | ទី១ |
| 30 | -ការដ្ឋានយកថ្ម | ទី១ |
| 31 | -ការដ្ឋានយកគ្រួស | ទី១ |
| 32 | -ទីតាំងផលិតក្តារបន្ទះ | ទី១ |
| 33 | -ទីតាំងផលិត ឬកែច្នៃជីគីមីកសិកម្ម | ទី១ |
| 34 | -ទីតាំងលាយបេតុង និងផលិតសំភារៈសំណង់ជាបេតុង | ទី១ |
| 35 | -នាំវាំដឹកសារធាតុភាវ | ទី២ |
| 36 | -ទីតាំងផលិតអាសេទីឡែន | ទី២ |
| 37 | -ទីតាំងសំលាប់ស្បែក | ទី២ |
| 38 | -ទីតាំងផលិតសាប៊ូ និងផលិតមេសាប៊ូ | ទី២ |
| 39 | -ទីតាំងស្ថានីយ៍ និងឃ្លាំងស្តុកប្រេងឥន្ធនៈ | ទី២ |
| 40 | -ទីតាំងកប់ ឬចាក់ចោលសំណល់រឹង | ទី២ |
| 41 | -ទីតាំងតំបាញ ឬជ្រលក់ពណ៌ | ទី២ |
| 42 | -ទីតាំងកាត់ដេរមានក្រឡុកបោក | ទី២ |
| 43 | -ទីតាំងផលិតក្រដាស និងម្សៅក្រដាស | ទី២ |
| 44 | -ទីតាំងបោះពុម្ពទស្សនាវដ្តី និងឯកសារផ្សេងៗ | ទី២ |
| 45 | -ទីតាំងលាងសំអាតត្បូងថ្ម និងរ៉ែ | ទី២ |
| 46 | -ទីតាំងផលិតថ្មពិល —អាគុយ | ទី២ |
| 47 | -ទីតាំងផលិតថ្នាំពណ៌អសរីរាង្គ | ទី២ |
| 48 | -ទីតាំងផលិត និងតំឡើងគ្រឿងអេឡិចត្រូនិច | ទី២ |
| 49 | -ទីតាំងផលិតដីក្រាលថ្ម | ទី២ |
| 50 | -ទីតាំងផលិតហ្វីលថត និងថ្នាំលាងហ្វីល | ទី២ |
| 51 | -ទីតាំងផលិតសារធាតុគីមីសរីរាង្គ | ទី២ |
| 52 | -ទីតាំងផលិតឱសថ | ទី២ |
| 53 | -ទីតាំងផលិតសារធាតុសរីរាង្គប្រើសំរាប់លាង | ទី២ |
| 54 | -ទីតាំងផលិត និងលាយថ្នាំពុលកសិកម្ម | ទី២ |
| 55 | -ទីតាំងផលិត ចំរាញ់ប្រេងកាត | ទី២ |
| 56 | -ទីតាំងផលិតដែក និងដែកថែប | ទី២ |
| 57 | -ទីតាំងផលិតលោហៈធាតុដែលមិនមែនដែក | ទី២ |
| 58 | -ទីតាំងផលិតរបស់របរលោហៈ | ទី២ |

| | | |
|---|---|---|
| 59 | -ទីតាំងក្រូម៉េរបស់លោហៈធាតុដែលមិនមែនដែក | ទី២ |
| 60 | -ទីតាំងដុត រឺកែច្នៃសំណល់រឹង | ទី២ |
| 61 | -ទីតាំងប្រព្រឹត្តកម្មសំអាតដី | ទី២ |
| 62 | -ទីតាំងកែច្នៃសំណល់ប្រេង | ទី២ |
| 63 | -ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវឧស្សាហកម្ម | ទី២ |
| 64 | -មន្ទីរពិសោធន៍ និងមជ្ឈមណ្ឌលស្រាវជ្រាវ | ទី២ |
| 65 | -រោងចក្រអគ្គិសនី | ទី២ |
| 66 | -ទីតាំងកែច្នៃឈើ | ទី២ |
| 67 | -ការដ្ឋានស្រែបង្គា | ទី២ |

# តារាងឧបសម្ព័ន្ធ ៤

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ

សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹក

## ១.សំរាប់ទន្លេ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | $BOD_5$ | mg/l | 1-10 |
| 3 | សារធាតុរឹងអណ្តែតលើទឹក(SS) | mg/l | 25-100 |
| 4 | កំរិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម(Coliform) | MPN/100ml | <5000 |

## ២-សំរាប់បឹង និងអាងស្តុកទឹក

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | COD | mg/l | 1-8 |
| 3 | សារធាតុរឹងអណ្តែតលើទឹក(SS) | mg/l | 1-15 |
| 4 | កំរិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម(Coliform) | MPN/100ml | <1000 |
| 6 | អាសូតសរុប(Total Nitrogen) | mg/l | 0,1-0,6 |
| 7 | ផូស្វរសរុប(Total Phosphorus) | mg/l | 0,005-0,05 |

## ៣-សំរាប់ទឹកសមុទ្រ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 7,0-8,3 |
| 2 | COD | mg/l | 2-8 |
| 3 | កំរិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 4 | កូលីហ្វម(Coliform) | MPN/100ml | <1000 |
| 5 | សមាសធាតុប្រេង(Oil content) | mg/l | 0 |
| 6 | អាសូតសរុប (Total Nitrogen) | mg/l | 0,2-1,0 |
| 7 | ផូស្វរសរុប (Total Phosphorus) | mg/l | 0,02-0,09 |

## តារាងឧបសម្ព័ន្ធ ៥

### កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ

### សំរាប់ការពារសុខភាពសាធារណៈ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | កាបូនតេត្រាក្លរួ | µg/l | <12 |
| 2 | អ៊ិចសាក្លរបង់សែន | µg/l | <0,03 |
| 3 | ដេដេតេ | µg/l | <10 |
| 4 | អង់ឌ្រីន | µg/l | <0,01 |
| 5 | ឌីអលឌ្រីន | µg/l | <0,01 |
| 6 | អេនឌ្រីន | µg/l | <0,005 |
| 7 | អ៊ីសូឌ្រីន | µg/l | <0,005 |
| 8 | ពៃក្លរូអេទីឡែន | µg/l | <10 |
| 9 | អ៊ិចសាក្លរប៊ុយតាឌីអែន | µg/l | <0,1 |
| 10 | ក្លរហ្វម | µg/l | <12 |
| 11 | 1,2ឌីក្លរអេទីឡែន | µg/l | <10 |
| 12 | ទ្រីក្លរអេទីឡែន | µg/l | <10 |
| 13 | ទ្រីក្លរបង់សែន | µg/l | <0,4 |
| 14 | អ៊ិចសាក្លរស៊ីក្លូអ៊ិចសែន | µg/l | <0,05 |
| 15 | បង់សែន | µg/l | <10 |
| 16 | តេត្រាក្លរអេទីឡែន | µg/l | <10 |
| 17 | កាត់ម្ញូម | µg/l | <1 |
| 18 | បារតសរុប | µg/l | <0,5 |
| 19 | បារតសរីរាង្គ | µg/l | 0 |
| 20 | សំណ | µg/l | <10 |
| 21 | ក្រូមវ៉ាឡង់ ៦ | µg/l | <50 |
| 22 | អាសេទិច | µg/l | <10 |
| 23 | សេលេញ៉ូម | µg/l | <10 |
| 24 | ប៉ូលីក្លរ៉ូ ប៊ីផេនីល(PCB) | µg/l | 0 |
| 25 | ស៊ីអានីត ($CN^{+}$) | µg/l | <0,005 |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ៤២ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់

# និងការរំខានដោយសំលេង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០០។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័តនិងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក -"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ភេទ ។

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណង់ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសាធារបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងឧបសម្ព័ន្ធ ២ ។

**មាត្រា ៥.-**

កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៦.-**

ក្នុងករណីចាំបាច់ កំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ នឹងត្រូវពិនិត្យកែសំរួលរៀងរាល់ប្រាំឆ្នាំម្តងតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧.-**

កំរិតកំណត់ស្តង់ដារបញ្ចេញសំលេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំរិតកំណត់ស្តង់ដារសំលេងអតិបរមាសំរាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ៨.-**

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុពុលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៩.-**

ហាមឃាត់ដាច់ខាតនូវការបង្កអោយមានសំលេង ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ១០.-**

ការនាំចូល និងផលិតនូវសារធាតុឆេះ ដែលមានជាតិស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាប៊ួប្រហើរ ត្រូវឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងឧសម្ព័ន្ធ ៨ ។

**មាត្រា ១១.-**

ហាមឃាត់ដាច់ខាតការនាំចូល ប្រើប្រាស់ ផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ដែលយានយន្ត និងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុល និងសំលេងមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ និងឧបសម្ព័ន្ធ ៥ ។

**មាត្រា ១២.-**

ហាមដាច់ខាតការបង្ហូរ ឬការធ្វើអោយលេចធ្លាយសារធាតុឆេះ ប្រេងឥន្ធនៈ ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី ។

## ជំពូកទី ៣
## ការសុំអនុញ្ញាត

**មាត្រា ១៣.-**

ការបញ្ចេញសារធាតុបំពុល និងសំលេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១៤.-**

ការសុំអនុញ្ញាតនាំចូលសារធាតុឆេះ ត្រូវមានភ្ជាប់នូវលទ្ធផលវិភាគ ដែលបញ្ជាក់ពីបរិមាណជាតិពុលស្ពាន់ធ័រ សំណបង់សែន ឬអ៊ីដ្រូកាបួប្រហើរពីប្រភពដើមនៃការនាំចូល ឬការផលិត ។

**មាត្រា ១៥.-**

ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំលេងដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងគំរោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ លើកលែងតែគំរោងដែលមានរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរួចហើយ ។

**មាត្រា ១៦.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

- អោយបានមុន ៤០ថ្ងៃ នៃការចាប់ផ្តើមដំនើរការ សំរាប់គំរោងនៅភ្នំពេញ
- អោយបានមុន ៦០ថ្ងៃ នៃការចាប់ផ្តើមដំនើរការ សំរាប់គំរោងនៅតាមខេត្ត ក្រុង ។

## ជំពូកទី ៤
## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៧.-**

ការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុឆេះ ការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពអចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័ន និងសំលេងពីប្រភពចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការពីក្រសួងស្ថាប័នពាក់ព័ន្ធ ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យនេះត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង ។

**មាត្រា ១៩.-**

ក្រសួងបរិស្ថានត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្តីពីវិធីសាស្ត្រត្រួតពិនិត្យប្រភពបំពុល វិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់ និងសំលេង ។

**មាត្រា ២០.-**

ក្រសួងបរិស្ថានត្រូវចុះយកគំរូតាងនៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាងដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២១.-**

នៅពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីបរិស្ថានអាចធ្វើការវិភាគគំរូតាងនៅនឹងកន្លែង ឬយកមកធ្វើនៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២២.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវបង់ថ្លៃសំរាប់វិភាគតាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំនត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសារធាតុបំពុលរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

**មាត្រា ២៤.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងអស់ត្រូវ :

- ទទួលខុសត្រូវក្នុងការដំឡើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល និងឧបករណ៍សំរាប់កាត់បន្ថយសំលេង ដើម្បីឱ្យឆ្លើយតបទៅនឹងកំណត់កំរិតស្តង់ដារ
- ទទួលខុសត្រូវក្នុងការដំឡើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុលដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ហើយត្រូវផ្ញើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់ ៣ខែ ម្តង ។
-ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូប ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសំរបសំរួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាលតាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ ។

**មាត្រា ២៥.-**

ក្នុងករណីដែលរកឃើញថាការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពណាមួយពុំបានឆ្លើយតបទៅ និងកំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា ៥ មាត្រា ៧ នៃអនុក្រឹត្យនេះក្រសួងបរិស្ថានត្រូវ :

ក-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ

ខ-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្នរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬប៉ះពាល់ដល់គុណភាពបរិស្ថាន ។

## ជំពូកទី ៥

## ការត្រួតពិនិត្យគុណភាពខ្យល់

### មាត្រា ២៦.-

ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជាដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា ។

### មាត្រា ២៧.-

ក្រសួងបរិស្ថានត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពខ្យល់ និងវាយតំលៃពីស្ថានភាពគុណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈពីស្ថានភាពគុណភាព និងការបំពុលខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២៨.-

ក្នុងករណីរកឃើញថា តំបន់ណាមួយត្រូវទទួលរងការបំពុលខ្យល់ ដែលបង្កអោយមានការគំរាមកំហែងដល់អាយុជីវិតសាធារណៈ ឬគុណភាពបរិស្ថាន ក្រសួងបរិស្ថានត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់ និងត្រូវស៊ើបអង្កេតរកប្រភពដែលបង្កអោយមានការបំពុល ព្រមទាំងចាត់វិធានការទប់ស្កាត់ប្រភពបំពុលទាំងនោះ ដើម្បីស្តារនូវគុណភាពខ្យល់អោយបានប្រសើរឡើងវិញ ។

## ជំពូកទី ៦

## នីតិវិធីនៃការធ្វើអធិការកិច្ច

### មាត្រា ២៩.-

នៅពេលចុះធ្វើអធិការកិច្ចតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថានត្រូវអនុវត្តតាមនីតិវិធីដូចមានចែងខាង ក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬកន្លែងប្រភពបំពុលដើម្បីធ្វើអធិការកិច្ចយកគំរូតាង ឬពិនិត្យកំណត់ត្រា ។

ខ-កំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ចដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់ពត៌មាន ឬឯកសារនានាដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុសំរាប់ប្រើជាវត្ថុតាង ។

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្ដល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣០.-**

ក្នុងករណីមានពាក្យបណ្ដឹង ឬសេចក្ដីរាយការណ៍ថា ប្រភពបំពុលណាមួយបានបញ្ចេញសារធាតុបំពុលខ្យល់ ឬសំលេង ឬរំញ័របង្កអោយមានគ្រោះថ្នាក់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣១.-**

ក្នុងករិណីមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនៃការបំពុលខ្យល់ ឬការរំខានដោយសំលេង ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពតិមានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣២.-**

ក្នុងករណីបទល្មើសជាក់ស្ដែងដែលបង្កអោយមានការបំពុលខ្យល់ ឬការរំខានដោយសំលេង មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូលឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

ខ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៣.-**

ការរំលោភល្មើសទៅ និងអនុក្រឹត្យនេះនឹងត្រូវទទួលពិន័យ និងផ្ដន្ទាទោសដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូក ទី ៩ នៃច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣៤.-**

កំណត់ហេតុចោទប្រកាន់បទល្មើសចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំង

ឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៨.-**

អនុក្រឹត្យនេះចូលជាធរមានគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ១

## កម្រិតកំណត់ស្តង់ដារគុណភាពខ្យល់

| ល.រ | ប៉ារ៉ាម៉ែត្រ | រយៈពេល១ម៉ោង ជាមធ្យម mg/m3 | រយៈពេល៨ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល២៤ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល ១ឆ្នាំ ជាមធ្យម$mg/m^3$ |
|---|---|---|---|---|---|
| 1 | កាបូនឌីអុកស៊ីត CO | 40 | 20 | | |
| 2 | អាសូតឌីអុកស៊ីត$NO_2$ | 0,3 | | 0,10 | |
| 3 | ស្ពាន់ធ័រឌីអុកស៊ីត$SO_2$ | 0,5 | | 0,30 | 0,10 |
| 4 | អូសូន $0_3$ | 0,2 | | | |
| 5 | សំណ Pb | | | 0,005 | |
| 6 | សារធាតុរឹងអណ្តែត ក្នុងខ្យល់ TSP | | | 0,33 | 0,10 |

**កំណត់សំគាល់**

-កម្រិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ធ្វើការវាយតំលៃគុណភាពខ្យល់ទូទៅ និងអង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់ ។

-វិធីសាស្ត្រនៃការវិភាគគុណភាពខ្យល់នឹងត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន

-TSP Total Suspended Particulate

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ២

## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់

| ល.រ | ឈ្មោះសារធាតុគីមី | រូបមន្តគីមី | កំរិតអតិបរមា ($mg/m^3$) |
|---|---|---|---|
| 1 | អានីលីន | $C_6H_5NH_2$ | 0,03 |
| 2 | អាម៉ូញាក់ | $NH_3$ | 0,2 |
| 3 | អាស៊ីត អាសេទិច | $CH_3COOH$ | 0,2 |
| 4 | អាស៊ីតស៊ុលផួរិច | $H_2SO_4$ | 0,3 |
| 5 | អាស៊ីតនីទ្រិច | $HNO_3$ | 0,4 |
| 6 | បង់សែន | $C_6H_6$ | 1 |
| 7 | បង់ស៊ីឌីន | $NH_2C_6H_4C_6H_4NH_2$ | គ្មាន |
| 8 | កាបូនឌីស៊ុលហ្វីត | $CS_2$ | 0,02 |
| 9 | ក្លរ៉ូហ្វម | $CHCL_3$ | 0,01 |
| 10 | កាបូនតេត្រាក្លរិត | $CCL_4$ | 3 |
| 11 | ភាគល្អិតដែលមាន asbestor | | គ្មាន |
| 12 | ដេ ដេ តេ | $C_8H_{11}CL$ | 0,5 |
| 13 | ហ្វម៉ល់ដេអ៊ីត | HCOH | 0,012 |
| 14 | អ៊ីដ្រូសែន អាសេនិច | $AsH_3$ | 0,002 |
| 15 | អ៊ីដ្រូសែន ស៊ីអានីត | HCN | 0,01 |
| 16 | អ៊ីដ្រូសែន ភ្លុយអរិច | HF | 0,002 |
| 17 | អ៊ីដ្រូសែនស៊ុលហ្វីត | $H_2S$ | 0,001 |
| 18 | ផេណុល | $C_6H_5OH$ | 0,01 |
| 19 | ស៊ីរេន | $C_6H_5CHCH_2$ | 0,003 |
| 20 | តេត្រាក្លរូអេទីឡែន | $C_2Cl_4$ | 0,1 |
| 21 | សំណតេត្រាអេទិល | $Pb(C_2H_5)_4$ | 0,005 |
| 22 | ទ្រីក្លរូអេទីឡែន | $CLCHCCL_2$ | 0,2 |
| 23 | តូលុយអេន | $C_9H_5CH_3$ | 0,4 |
| 24 | វិនិក្លរូ | $CLCHCH_2$ | 0,05 |

| | | | |
|---|---|---|---|
| 25 | អាសេទិច (សមាសធាតុអសរីរាង្គ) | As | 0,00001 |
| 26 | កាត់ម្ញូម(សមាសធាតុលោហៈ និងអុកស៊ីត) | Cd | 0,003 |
| 27 | ក្រូម(លោហៈ និងសមាសធាតុ) | Cr | 0,0015 |
| 28 | នីកែល (លោហៈ និងសមាសធាតុ) | Ni | 0,0001 |
| 29 | បារត(លោហៈ និងសមាសធាតុ) | Hg | 0,0001 |
| 30 | ប្រេងសាំង | | 5 |

**កំណត់សំគាល់**

ក៏រិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់ ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៣

## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញ

## ពីប្រភពអចល័ត ចូលទៅក្នុងបរិយាកាស

| ល.រ | ប៉ារ៉ាម៉ែត | កំរិតអតិបរមានៃការបញ្ចេញ |
|---|---|---|
| 1 | ភាគល្អិតនៅក្នុងផ្សែង បញ្ចេញពីប្រភព : | |
| | -ឡដុត | 400 mg/m$^3$ |
| | -រោងចក្រផលិតលោហធាតុ | 400 mg/m$^3$ |
| | -រោងចក្រស៊ីម៉ង់ត៍ កំបោរ និងថ្មស្អុយ | 400 mg/m$^3$ |
| | -រោងចក្របេតុងអាស្ពាល់ | 500 mg/m$^3$ |
| 2 | ធូលី ដែលមានភ្ជាប់ : | |
| | -សារធាតុ ស៊ីលីកាត $Si0_2$ | 100 mg/m$^3$ |
| | -សារធាតុ Asbetos | 27 µg/$m_3$ |
| | -សារធាតុគីមីអសរីរាង្គ : | |
| 3 | អាលុយមីញ៉ូម AL | (ធូលី) ៣00 mg/m$^3$ ៈ(Al) 50 mg/m$^3$ |
| 4 | អាម៉ូញាក់ $NH_3$ | 100 mg/m$^3$ |
| 5 | អាង់ទីម៉ូន Sb | 25 mg/m$^3$ |
| 6 | អាសេទិច As | 20 mg/$m_3$ |
| 7 | បេរីល្យ៉ូម Be | 10 µg/$m_3$ |
| 8 | ក្លរ CL | 20 mg/$m_3$ |
| 9 | អ៊ីដ្រូសែនក្លរីត HCL | 200 mg/$m_3$ |
| 10 | អ៊ីដ្រូសែនភ្លុយអរីត HF | 10 mg/$m_3$ |
| 11 | អ៊ីដ្រូសែនស៊ុលភីត $H_2F$ | 2 mg/$m_3$ |
| 12 | កាត់ម្យ៉ូម Cd | 1 mg/$m_3$ |
| 13 | ទង់ដែង Cu | (ធូលី) ៣00mg/$m_3$ (Cu) 20 mg/$m_3$ |
| 14 | សំណ Pb | (ធូលី) ១00 mg/$m_3$ (Pb) 30 mg/$m_3$ |
| 15 | ស័ង្កសី Zn | 30 mg/$m_3$ |
| 16 | បារត Hg | 0,1 mg/$m_3$ |
| 17 | កាបូនម៉ូណូអុកស៊ីត Co | 1000 mg/$m_3$ |

| | | |
|---|---|---|
| 18 | ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | 500 $mg/m^3$ |
| 19 | អាសូតអុកស៊ីត( គ្រប់ប្រភេទ) NOx | 1000 $mg/m^3$ |
| 20 | អាសូតអុកស៊ីត( ចេញពីការផលិតអាស៊ីត)NOx | 2000 $mg/m^3$ |
| 21 | អាស៊ីតស៊ុលផួរិច $H_2SO_4$ | 35 $mg/m^3$ |
| 22 | អាស៊ីតនីទ្រិច $HNO_3$ | 70 $mg/m^3$ |
| 23 | ស្ពាន់ធ័រទ្រីអុកស៊ីត ($SO_3$) | 35 $mg/m^3$ |
| 24 | អាស៊ីតផូស្វរិច ($H_3PO_4$) | 3 $mg/m^3$ |
| | សារធាតុគីមីសរីរាង្គ : | |
| 25 | អាសេទីឡែនតេត្រាប្រូមីត $CHBr_2CHBr_2$ | 14 $mg/m^3$ |
| 26 | អាក្រូឡេអ៊ិន $CH_2CHCHO$ | 1,2 $mg/m^3$ |
| 27 | អានីលីន $C_6H_5NH_2$ | 19 $mg/m^3$ |
| 28 | បង់ស៊ីឌីន $NH_2C_6H_4C_6H_4NH_2$ | None |
| 29 | បង់សែន $C_6H_6$ | 80 $mg/m^3$ |
| 30 | ក្លរបង់ស៊ីល $C_6H_5CH_2Cl$ | 5 $mg/m^3$ |
| 31 | ប៊ុយទីលឡាមីន $CH_3(CH_2)_2CH_2NH_2$ | 15 $mg/m^3$ |
| 32 | ក្រេសូល (O-,m-,P-) $CH_3C_6H_4OH$ | 22 $mg/m^3$ |
| 33 | ក្លរបង់សែន $C_6H_5Cl$ | 350 $mg/m^3$ |
| 34 | ក្លរហ្វម $CHCl_3$ | 240 $mg/m^3$ |
| 35 | ក្លរពិគ្រីន $CCl_3NO_2$ | 0,7 $mg/m^3$ |
| 36 | O-ឌីក្លរបង់សែន $C_6H_4Cl_2$ | 300 $mg/m^3$ |
| 37 | 1.1-ឌីក្លរអេតាន $CHCl_2CH_3$ | 400 $mg/m^3$ |
| 38 | ឌីមេទីលស៊ុលហ្វាត $(CH_3)_2SO_4$ | 0,5 $mg/m^3$ |
| 39 | ឌីមេទីលអ៊ីដ្រាហ្ស៊ីន $(NH_3)_2NNH_2$ | 1 $mg/m^3$ |
| 40 | ឌីនីត្រូបង់សែន (O-,m-,P-) $C_6H_4(NO_2)_2$ | 1 $mg/m^3$ |
| 41 | អេទីឡែនឌីអាមីន $NH_2CH_2$-$CH_2NH_2$ | 30 $mg/m^3$ |
| 42 | អេទីឡែន ក្លរអ៊ីឌ្រីន $CH_2ClCH_2OH$ | 16 $mg/m^3$ |
| 43 | អេទីឡែន អុកស៊ីត $CH_2OCH_2$ | 20 $mg/m^3$ |
| 44 | ហ្វ័រម៉ាល់ដេអ៊ីដ HCHO | 6 $mg/m^3$ |
| 45 | មេទីលអាគ្រីឡាត $CH_2CHCOOCH_3$ | 35 $mg/m^3$ |
| 46 | មេតាណុល $CH_3OH$ | 260 $mg/m^3$ |
| 47 | មេទីលប្រូមីត $CH_3Br$ | 80 $mg/m^3$ |

| | | |
|---|---|---|
| 48 | ម៉ូណូមេទីលអានីលីន $C_6H_5NHCH_3$ | 9 mg/m$^3$ |
| 49 | នីត្រូបង់សែន $C_6H_5NO_2$ | 5 mg/m$^3$ |
| 50 | នីត្រូគ្លីសេរីន $C_3H_5(NO_2)_3$ | 5 mg/m$^3$ |
| 51 | នីត្រូតូលូអែន $NO_2C_6H_4CH_3$ | 30 mg/m$^3$ |
| 52 | ផេណុល $C_6H_5OH$ | 19 mg/m$^3$ |
| 53 | ផេនីលអ៊ីដ្រាហ្ស៊ីន $C_6H_5NHNH_2$ | 22 mg/m$^3$ |
| 54 | ពីរីនឌីន $C_5H_5N$ | 30 mg/m$^3$ |
| 55 | ពីរ៉ែន $C_{16}H_{10}$ | 15 mg/m$^3$ |
| 56 | គ្វីណូន $C_6H_4O_2$ | 0,4 mg/m$^3$ |
| 57 | ស្ទីរ៉ែន $C_6H_5CHCH_2$ | 420 mg/m$^3$ |
| 58 | 1,1,2,2-តេត្រាក្លូរអេតាន $Cl_2HCCHCl_2$ | 35 mg/m$^3$ |
| 59 | តេត្រាក្លូរមេតាន $CCl_4$ | 65 mg/m$^3$ |
| 60 | តូលូអែន $C_6H_5CH_3$ | 750 mg/m$^3$ |
| 61 | តេត្រានីត្រូមេតាន $C(NO_2)_4$ | 8 mg/m$^3$ |
| 62 | តូលូអ៊ីឌីន $CH_3C_6H_4NH_2$ | 22 mg/m$^3$ |
| 63 | តូលូអែន 2.4- ឌីអ៊ីសូស៊ីអាណាត $CH_3C_6H_3(NCO)_2$ | 0,7 mg/m$^3$ |
| 64 | ទ្រីក្លូរអេទីឡែន $ClCHCCl_2$ | 110 mg/m$^3$ |
| 65 | ស៊ីលីឌីន $(CH_3)_2C_6H_3NH_2$ | 50 mg/m$^3$ |
| 66 | វីនីលក្លរីត $CH_2CHCl$ | 150 mg/m$^3$ |

## កំណត់សំគាល់

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៤

## កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត

| ល.រ | ប្រភេទយានយន្ត | ប្រភេទប្រេងឥន្ធនៈ | កំរិតនៃការបញ្ចេញ | | | | |
|---|---|---|---|---|---|---|---|
| | | | CO (%) | | HC(ppm) | | ផ្សែងខ្មៅ % |
| | | | ក | ខ | ក | ខ | |
| 1 | ទោចក្រយានយន្តដែលមានចំហេះ២វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 3000 | |
| 2 | ទោចក្រយានយន្តដែលមានចំហេះ៤វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 2400 | |
| 3 | យានយន្តគ្រប់ប្រភេទ | ប្រេងសាំង | 4,5 | 4 | 1200 | 800 | |
| 4 | យានយន្តគ្រប់ប្រភេទ | ប្រេងម៉ាស៊ូត | | | | | ៥០ |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញឧស្ម័នពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

ក-គឺសំដៅលើយានយន្តគ្រប់ប្រភេទដែលប្រើប្រាស់ហួសរយៈពេល ៥ឆ្នាំ គិតពីឆ្នាំដែលផលិត ។

ខ-គឺសំដៅទៅលើយានយន្តគ្រប់ប្រភេទដែលបាននាំចូលថ្មីក្នុងរយៈពេល ប្រាំឆ្នាំដំបូងគិតចាប់ពីឆ្នាំដែលផលិត ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៥

# កំរិតកំណត់ស្តង់ដារអតិបរមា ដែលអនុញ្ញាតបញ្ចេញសំលេងនៅលើផ្លូវសាធារណៈ ពីប្រភពយានយន្ត

| ល.រ | **ប្រភេទយានយន្ត** | កំរិតអតិបរមា (dB (A)) |
|---|---|---|
| 1 | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)< 125 $Cm^3$ | 85 |
| 2 | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)≥ 125 $Cm^3$ | 90 |
| 3 | **ត្រីចក្រយានយន្ត** | 90 |
| 4 | រថយន្តធុនតូច រថយន្តដឹកអ្នកដំណើរ ១២ នាក់ | 80 |
| 5 | រថយន្តដឹកអ្នកដំណើរ ≥ ១២ នាក់ | 85 |
| 6 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ < 3,5 តោន | 85 |
| 7 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ > 3,5 តោន | 88 |
| 8 | រថយន្តដឹកទំនិញដែលមានកំលាំង ≥ 150 kw | 89 |
| 9 | គ្រឿងយន្តផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ | 91 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតបញ្ចេញសំលេងពីប្រភពយានយន្តគ្រប់ប្រភេទ ដែលកំពុងធ្វើចរាចរលើផ្លូវសាធារណៈ ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៦

## កំរិតកំណត់ស្តង់ដារសំលេងអតិបរមា ដែលអនុញ្ញាតនៅតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន (dB(A))

| ល.រ | ទីតាំង | អំឡុងពេល | | |
|---|---|---|---|---|
| | | ពីម៉ោង ៦ព្រឹកដល់ម៉ោង ១៨ល្ងាច | ពីម៉ោង ១៨ល្ងាចដល់ម៉ោង ២២យប់ | ពីម៉ោង២២យប់ដល់ម៉ោង ៦ព្រឹក |
| 1 | តំបន់ស្ងប់ស្ងៀម<br>-មន្ទីរពេទ្យ<br>-បណ្ណាល័យ<br>សាលារៀន<br>មតេយ្យសាលា | 45 | 40 | 35 |
| 2 | តំបន់លំនៅដ្ឋាន<br>-សណ្ឋាគារ ទីកន្លែង រដ្ឋបាល<br>-ភូមិគ្រឹះ ផ្ទះល្វែង | 60 | 50 | 45 |
| 3 | តំបន់ពាណិជ្ជកម្ម សេវាកម្ម និងចំរុះ | 70 | 65 | 50 |
| 4 | ឧស្សាហកម្មធន់ស្រាល លាយចំរុះនៅក្នុងតំបន់លំនៅដ្ឋាន | 75 | 70 | 50 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងពីប្រភព ឬសកម្មភាពណាមួយ ដែលបញ្ចេញសំលេងចូលក្នុងតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៧

# កំរិតកំណត់ស្តង់ដារសំរាប់ត្រួតពិនិត្យសំលេង

# ក្នុងទីតាំង រោងជាង រោងចក្រឧស្សាហកម្ម

| កំរិតសំលេង (dB(A)) | រយៈពេលអតិបរមា (ម៉ោង) | កំណត់បង្ហាញ |
|---|---|---|
| 75 | 32 | ត្រូវផ្តល់ឧបករណ៍ការពារត្រចៀកដល់អ្នកបំរើការដែលធ្វើការនៅកន្លែងមានសំលេងលើសពី 80dB (A) |
| 80 | 16 | |
| 85 | 8 | |
| 90 | 4 | |
| 95 | 2 | |
| 100 | 1 | |
| 105 | 0,5 | |
| 110 | 0,25 | |
| 115 | 0,125 | |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងនៅក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៧

## កំរិតកំណត់ស្តង់ដារ ជាតិស្ពាន់ធ័រ សំណ បង់សែន

## និងអ៊ីដ្រូកាប៊ួប្រហើរ ដែលអនុញ្ញាតឱ្យមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម

| ល.រ | សារធាតុចំហេះ | ស្ពាន់ធ័រ(S) | សណ(Pb) | បង់សែន | អ៊ីដ្រូកាប៊ួប្រហើរ |
|---|---|---|---|---|---|
| 1 | ប្រេងខ្មៅ | 1,0% | | | |
| 2 | ប្រេងម៉ាស៊ូត | 0,2% | | | |
| 3 | ប្រេងសាំង | | 0,15 ក្រាម/លីត្រ | 3,5% | 50% |
| 4 | ធ្យូងថ្ម | 1,5% | | | |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ត្រួតពិនិត្យជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាប៊ួប្រហើរ ដែលអនុញ្ញាត អោយមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៧. អនក្រ. បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញអនុក្រឹត្យលេខ ៣៨.អនក្រ/បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍និងជាប្រធានគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតដែលសរសេរកាត់ថាអគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ស.**។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ស.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ធ្វើជាសេនាធិការឲ្យ **គ.ជ.ទ.ស.** ក្នុងការប្រមូលនិងវិភាគទិន្នន័យដែលពាក់ព័ន្ធនឹងចលនាប្រឡងប្រណាំងទីក្រុងស្អាត ដើម្បីជាមូលដ្ឋានក្នុងការផ្ដល់អនុសាសន៍ដល់ទីក្រុងបេក្ខភាព
- ធ្វើការផ្សព្វផ្សាយនិងរៀបចំដំណើរការប្រឡងប្រណាំងទីក្រុងស្អាត
- ទទួលពាក្យស្នើសុំចូលរួមការប្រឡងប្រណាំង ធ្វើអង្កេត ត្រួតពិនិត្យឯកសារ និងវាយតម្លៃទីក្រុងបេក្ខភាព ដើម្បីដាក់ជូនប្រធាន **គ.ជ.ទ.ស.** សម្រេច
- ជួយ**គ.ជ.ទ.ស.** ក្នុងការជំរុញនិងលើកទឹកចិត្តដល់ការកែលម្អទីក្រុងស្របតាមស្តង់ដាទីក្រុងស្អាត
- ជានាការអនុវត្តរបស់ **គ.ជ.ទ.ស.** ដោយអនុលោមតាមបទដ្ឋានគតិយុត្តនិងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- រៀបចំសេចក្ដីព្រាងផែនការសកម្មភាពការងារដើម្បីដាក់ជូន **គ.ជ.ទ.ស.** សម្រេច
- សិក្សា ស្រាវជ្រាវ និងធ្វើបច្ចុប្បន្នកម្មលើឯកសារនានាសម្រាប់ដំណើរការប្រឡងប្រណាំងទីក្រុងស្អាត ដែលអាចឆ្លើយតបនឹងតម្រូវការសង្គម
- ទទួលព័ត៌មានស្ដីពីកម្មវិធី គម្រោង និងសកម្មភាពនានាដែលបាន កំពុង នឹងគ្រោងអនុវត្តក្នុងទិសដៅគ្រប់គ្រងនិងអភិវឌ្ឍទីក្រុង
- ប្រមូលផ្តុំនិងចងក្រងឯកសារពាក់ព័ន្ធ
- ពិនិត្យនិងតាមដានសកម្មភាពការងារនៃក្រុមការងារថ្នាក់រាជធានី ខេត្ត ដើម្បីធានាសុក្រឹតភាពនិងប្រសិទ្ធភាពការងារ
- ធ្វើជាសេនាធិការឲ្យ **គ.ជ.ទ.ស.** ក្នុងការធ្វើសហការជាមួយនឹងប្រទេសសមាជិកអាស៊ានទាំងអស់ដើម្បីជំរុញឲ្យមានការប្រឡងប្រណាំងទីក្រុងស្អាត
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ.ជ.ទ.ស.**
- រៀបចំកិច្ចប្រជុំនានារបស់ **គ.ជ.ទ.ស.**
- សម្របសម្រួលការងារនានារបស់ **គ.ជ.ទ.ស.** ជាមួយនឹងស្ថាប័នជាតិ អន្តរជាតិ និងបុគ្គលពាក់ព័ន្ធដើម្បីធានាឱ្យដំណើរការការងាររបស់ **គ.ជ.ទ.ស.** កាន់តែមានប្រសិទ្ធភាព។

- រៀបចំរបាយការណ៍ជាប្រចាំពីវឌ្ឍនភាពនៃកិច្ចដំណើរការការងាររបស់ **គ.ជ.ទ.ស.** និងធ្វើរបាយការណ៍ផ្សេងទៀតជូន **គ.ជ.ទ.ស.**
- ជួយការងារគ្រប់គ្រងរដ្ឋបាលទូទៅរបស់ **គ.ជ.ទ.ស.**
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធាន **គ.ជ.ទ.ស.**។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ស.** ដឹកនាំដោយអគ្គលេខាធិការ១រូប អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ស.** មានរចនាសម្ព័ន្ធដូចតទៅៈ

- ផ្នែកបច្ចេកទេសវាយតម្លៃទីក្រុងស្អាត
- ផ្នែកផែនការ បណ្តុះបណ្តាល និងនីតិកម្ម
- ផ្នែកសហប្រតិបត្តិការនិងការផ្សព្វផ្សាយ
- ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ស.** ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

ផ្នែកនីមួយៗត្រូវដឹកនាំដោយប្រធានផ្នែក១រូបដែលមានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអនុប្រធានផ្នែកមួយចំនួនជាជំនួយការតាមការចាំបាច់។

ផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ស.** អាចមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធាន **គ.ជ.ទ.ស.**។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ស.** មានមន្ត្រីបម្រើការមកពីក្រសួងទេសចរណ៍និងមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈផ្សេងទៀត។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ស.** អាចមានអ្នកជំនាញការនិងបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងាររបស់ខ្លួន។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ស.** មានក្រុមការងារវាយតម្លៃទីក្រុងស្អាតថ្នាក់[illegible]ត្ត ដើម្បីសម្រួលដំណើរការការងាររបស់ខ្លួន។

ក្រុមការងារវាយតម្លៃទីក្រុងស្អាតថ្នាក់រាជធានី ខេត្ត ដឹកនាំដោយប្រធាន១រូបដែលជាអភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត មានប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ជាអនុប្រធានអចិន្ត្រៃយ៍ និងមានប្រធានមន្ទីរពាក់ព័ន្ធមួយចំនួនជាសមាជិកតាមការចាំបាច់។

សមាសភាពនិងភារកិច្ចរបស់ក្រុមការងាររាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ទ.ឆ.**។

## ជំពូកទី៤
## តួនាទីនិងភារកិច្ចរបស់ផ្នែកនីមួយៗ

**មាត្រា ៨.-**

ផ្នែកបច្ចេកទេសវាយតម្លៃទីក្រុងស្អាត មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងនិងអនុវត្តនីតិវិធីចុះឈ្មោះចូលរួមការប្រឡងប្រណាំងទីក្រុងស្អាត
- ចុះពិនិត្យដល់ទីតាំងជាក់ស្តែងនិងផ្ទៀងផ្ទាត់ឯកសារដែលទីក្រុងបេក្ខភាពនីមួយៗបានផ្តល់ជូន
- ធ្វើការវាយតម្លៃបឋមទីក្រុងបេក្ខភាពយោងតាមឯកសារនានាដែលអនុម័តដោយ **គ.ជ.ទ.ឆ.**
- ពិនិត្យនិងលើកសំណើដោះស្រាយទៅថ្នាក់ដឹកនាំតាមឋានានុក្រមនូវរាល់ករណីមិនប្រក្រតីនៃការអនុវត្តរបស់ទីក្រុងជ័យលាភី
- ផ្តល់យោបល់និងធ្វើការណែនាំអំពីការអនុវត្តល្អៗដល់ទីក្រុងបេក្ខភាពទាំងឡាយ
- ប្រមូលនិងវិភាគទិន្នន័យពាក់ព័ន្ធនឹងការវាយតម្លៃទីក្រុងស្អាត
- សិក្សា ស្រាវជ្រាវ និងចងក្រងឯកសារដែលពាក់ព័ន្ធនឹងការងារវាយតម្លៃទីក្រុងស្អាត
- រៀបចំប្រព័ន្ធគ្រប់គ្រងនិងបញ្ចូលទិន្នន័យ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូនអគ្គលេខាធិការ **គ.ជ.ទ.ឆ.**
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ជ.ទ.ឆ.**។

**មាត្រា ៩.-**

ផ្នែកផែនការ បណ្តុះបណ្តាល និងនីតិកម្ម មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ប្រមូល រៀបចំ គ្រប់គ្រង និងវិភាគទិន្នន័យលទ្ធផលការងារដែលទទួលបានពីគ្រប់អង្គភាពពាក់ព័ន្ធ ដើម្បីកំណត់និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីអភិវឌ្ឍន៍ការងារប្រឡងប្រណាំងទីក្រុងស្អាត
- ធ្វើសហការរៀបចំនិងវាយតម្លៃតម្រូវការសម្រាប់ការបណ្តុះបណ្តាលនិងការអភិវឌ្ឍធនធានមនុស្សក្នុងអគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ឆ.** និងគ្រប់ភាគីពាក់ព័ន្ធក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- ធ្វើសហការរៀបចំកម្មវិធីបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពដល់មន្ត្រីអគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ឆ.** និងគ្រប់ភាគីពាក់ព័ន្ធក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- រៀបចំ អង្កេត និងវាយតម្លៃការអនុវត្តផែនការនិងគម្រោងអភិវឌ្ឍន៍ការងារប្រឡងប្រណាំងទីក្រុងស្អាតដើម្បីជូនយោបល់ប្រធាន **គ.ជ.ទ.ឆ.** តាមរយៈអគ្គលេខាធិការនៃ **គ.ជ.ទ.ឆ.**

- សិក្សាស្រាវជ្រាវឯកសារច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងចលនាប្រឡងប្រណាំងទីក្រុងស្អាត
- រៀបចំកសាងច្បាប់និងលិខិតបទដ្ឋាននានា ដើម្បីគ្រប់គ្រងការងារពាក់ព័ន្ធនឹងចលនាប្រឡងប្រណាំងទីក្រុងស្អាត ដោយធ្វើសហការជាមួយអង្គភាពជំនាញនិងក្រសួងស្ថាប័នពាក់ព័ន្ធ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូនអគ្គលេខាធិការនៃ **គ.ជ.ទ.ឧ.**
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការ **គ.ជ.ទ.ឧ.**។

**មាត្រា ១០.-**

ផ្នែកសហប្រតិបត្តិការនិងផ្សព្វផ្សាយ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគម្រោងសហប្រតិបត្តិការជាមួយអង្គការ សមាគមជាតិនិងអន្តរជាតិ ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ
- សម្របសម្រួលនិងធ្វើទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយប្រទេសសមាជិកអាស៊ានលើរាល់សកម្មភាពដែលទាក់ទងនឹងចលនាទីក្រុងស្អាត
- តាមដាននិងវាយតម្លៃលើរាល់សកម្មភាពដែលមានចែងក្នុងកំណត់ហេតុ អនុស្សរណៈនៃការយោគយល់គ្នា ពិធីសារ និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ជូនថ្នាក់ដឹកនាំពិនិត្យ ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌចលនាប្រឡងប្រណាំងទីក្រុងស្អាត
- ជំរុញការចូលរួមពីសាធារណជននិងគ្រប់ភាគីពាក់ព័ន្ធក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត
- ធ្វើសហការរៀបចំកម្មវិធីអប់រំនិងនាទីផ្សព្វផ្សាយចលនាប្រឡងប្រណាំងទីក្រុងស្អាត
- បង្កើត គ្រប់គ្រង រចនា និងធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់ **គ.ជ.ទ.ឧ.**
- ពិនិត្យ រៀបចំ និងចងក្រងគ្រប់ឯកសារផ្សព្វផ្សាយអំពីចលនាប្រឡងប្រណាំងទីក្រុងស្អាត និងអំពីសកម្មភាពរបស់ **គ.ជ.ទ.ឧ.**
- ធ្វើសហការជាមួយផ្នែកជំនាញពាក់ព័ន្ធ ដើម្បីសិក្សា ស្រាវជ្រាវ និងចងក្រងជាឯកសារស្ដីពីការអនុវត្តផ្សេងៗ ដែលមានចរិតផ្សារភ្ជាប់នឹងចលនាប្រឡងប្រណាំងទីក្រុងស្អាត
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូនអគ្គលេខាធិការនៃ **គ.ជ.ទ.ឧ.**
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ជ.ទ.ឧ.**។

**មាត្រា ១១.-**

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែកនិងក្រុមការងាររបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ឧ.**
- គ្រប់គ្រង ចាត់ចែង និងចរាចរឯកសាររដ្ឋបាលរបស់ **គ.ជ.ទ.ឧ.**
- ធានាប្រសិទ្ធភាព សុវត្ថិភាព និងគ្រប់គ្រងការងាររដ្ឋបាល
- ទទួលបន្ទុករៀបចំសន្និបាត កិច្ចប្រជុំ សិក្ខាសាលា និងពិធីការនានា ព្រមទាំងធ្វើរបាយការណ៍ឬកំណត់ហេតុ
- គ្រប់គ្រងចំណូល ចំណាយ និងលើកគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ.ជ.ទ.ឧ.**

- គ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិកក្នុងអគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ឧ.**
- បូកសរុបនិងធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ឧ.**
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូនអគ្គលេខាធិការនៃ **គ.ជ.ទ.ឧ.**
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ជ.ទ.ឧ.**។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធាន **គ.ជ.ទ.ឧ.** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីសូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១២**
**ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**
**អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.វ.ក.**




៧/៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ
រដ្ឋបាលខណ្ឌដូនពេញ
លេខ៖...[illegible]/២១....ដកអ.ដព

ថ្ងៃពុធ ១៣រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ដូនពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០២១

# លិខិតបញ្ជូន

## សូមគោរពជូន

- ឯកឧត្តម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- ឯកឧត្តម អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ និងជាប្រធានក្រុមការងារតាមដាន និងជម្រុញការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ រាជធានីភ្នំពេញ
- លោក ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ និងជាប្រធានលេខាធិការដ្ឋានក្រុមការងារតាមដាន និងជម្រុញការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ រាជធានីភ្នំពេញ

| ល.រ | រាយលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | -សេចក្តីសម្រេចលេខ ១៩៨/២០សសរ.ដព ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ របស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពីការបង្កើតគណៈកម្មការប្រយុទ្ធនឹងវីរុសកូវីដ ១៩(COVID-19) រាជធានីភ្នំពេញ | (០៤ច្បាប់) | "ដើម្បីគោរពជូនពិនិត្យ និងសម្រេច ក្នុងការចូលរួមប្រឡងប្រណាំង ទីក្រុងស្អាត ទីក្រុងដែលអនុវត្តវិធានសុវត្ថិភាពទេសចរណ៍បានល្អ" |
| ២ | -សេចក្តីសម្រេចលេខ ៤៧៣/២០សសរ.ដព ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ របស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពីការបង្កើតគណៈកម្មការប្រយុទ្ធនឹងវីរុសកូវីដ ១៩(COVID-19) ខណ្ឌដូនពេញ រាជធានីភ្នំពេញ | (០៤ច្បាប់) | |
| ៣ | -សេចក្តីសម្រេចលេខ ៨៩០/២០សសរ/ដព ចុះថ្ងៃទី២៥ខែឧសភា ឆ្នាំ២០២០ របស់រដ្ឋបាលខណ្ឌដូនពេញ ស្តីពីការបំពេញបន្ថែមការបង្កើតអនុគណៈកម្មការ ដើម្បីធ្វើជាជំនួយការឱ្យគណៈកម្មការត្រួតពិនិត្យប្រយុទ្ធនឹងវីរុសកូវីដ ១៩(COVID-19) តាមសង្កាត់ទាំង១១ ក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ | (០៤ច្បាប់) | |
| ៤ | -សេចក្តីសម្រេចលេខ ២៣០២/២០ សសរ.ដព ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់រដ្ឋបាលខណ្ឌដូនពេញ ស្តីពីការបង្កើតក្រុមការងារជម្រុញនិងតាមដានការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ ក្នុងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ" ខណ្ឌដូនពេញ រាជធានីភ្នំពេញ | (០៤ច្បាប់) | |
| ៥ | -លិខិតលេខ២៣៩/២១ របក.ដព របាយការណ៍បច្ចុប្បន្នភាពការងារចូលរួមការប្រឡងប្រណាំង "ទីក្រុងស្អាត ទីក្រុងដែលអនុវត្តវិធានសុវត្ថិភាពទេសចរណ៍បានល្អ" របស់រដ្ឋបាលខណ្ឌដូនពេញ គិតត្រឹមបំណាច់ឆ្នាំ២០២០ | (០៤ ច្បាប់) | |
| ៦ | -សម្រង់ព័ត៌មានទម្រង់ "ក" សម្រង់ព័ត៌មានអំពីអាជីវកម្មទេសចរណ៍ប្រភេទសណ្ឋាគារក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ | (០៤ច្បាប់) | |

| | | | |
|---|---|---|---|
| ៧ | -សម្រង់ព័ត៌មានទម្រង់ "ក" សម្រង់ព័ត៌មានអំពីអាជីវកម្មទេសចរណ៍ ប្រភេទផ្ទះភ្ញៀវក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ | (០៤ច្បាប់) | |
| ៨ | -សម្រង់ព័ត៌មានទម្រង់ "ក" សម្រង់ព័ត៌មានអំពីអាជីវកម្មទេសចរណ៍ ប្រភេទភោជនីយដ្ឋានក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ | (០៤ច្បាប់) | |
| ៩ | -សម្រង់ព័ត៌មានទម្រង់ "ក" សម្រង់ព័ត៌មានអំពីអាជីវកម្មទេសចរណ៍ ប្រភេទដឹកជញ្ជូនទេសចរណ៍ផ្លូវទឹកក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ | (០៤ច្បាប់) | |
| ១០ | -សម្រង់ព័ត៌មានទម្រង់ "ក" សម្រង់ព័ត៌មានអំពីអាជីវកម្មទេសចរណ៍ ប្រភេទរមណីយដ្ឋានទេសចរណ៍ក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ | (០៤ច្បាប់) | |
| ១១ | -សម្រង់ព័ត៌មានទម្រង់ "ខ" សម្រង់ព័ត៌មានអំពីសកម្មភាពបណ្តុះបណ្តាលមន្ត្រីជំនាញពាក់ព័ន្ធ ស្តីពីការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ | (០៤ច្បាប់) | |
| ១២ | -សម្រង់ព័ត៌មានទម្រង់ "គ" សម្រង់ព័ត៌មានអំពីសកម្មភាពបណ្តុះបណ្តាលជនបង្គោលរបស់មូលដ្ឋានអាជីវកម្ម ស្តីពីការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ | (០៤ច្បាប់) | |
| ១៣ | -កំណត់ហេតុចុះត្រួតពិនិត្យ និងណែនាំវិធានសុវត្ថិភាពសុខាភិបាលដល់មូលដ្ឋានអាជីវកម្ម សេវាកម្ម របស់រដ្ឋបាលខណ្ឌដូនពេញ ចំនួន ១៤ច្បាប់ | (០៤ច្បាប់) | |
| ១៤ | -បញ្ជីវត្តមានកិច្ចប្រជុំផ្សព្វផ្សាយស្តីពី "លិខិតបទដ្ឋានគតយុត្តិដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍(ជំហានទី១) សម្រាប់ដំណាក់កាលវិបត្តិនៃកូវីដ១៩" ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ | (០៤ច្បាប់) | |
| ១៥ | -បញ្ជីវត្តមានកិច្ចប្រជុំផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពី "ការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ ដល់មន្ត្រីពាក់ព័ន្ធក្នុងខណ្ឌដូនពេញ ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០២០<br>-បញ្ជីវត្តមានកិច្ចប្រជុំផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពី "ការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ ដល់ជនបង្គោលតំណាងអាជីវកម្ម ក្នុងខណ្ឌដូនពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ | (០៤ច្បាប់) | |
| ១៦ | -រូបថតសកម្មភាពកិច្ចប្រជុំផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងសកម្មភាពចុះត្រួតពិនិត្យ និងណែនាំដល់មូលដ្ឋានអាជីវកម្ម ដែលក្រុមការងារពិនិត្យឃើញថា អាជីវកម្មមួយចំនួន ពុំទាន់អនុវត្តវិធានសុវត្ថិភាពសុខាភិបាលបានពេញលេញ | (០៤ច្បាប់) | |
| សរុប | | ៦៤ ច្បាប់ | |

បានទទួលគ្រប់ចំនួន.............ច្បាប់

ថ្ងៃទី...........ខែ............ឆ្នាំ ២០២១

**ហត្ថលេខាអ្នកទទួល**

**អភិបាល នៃគណៈអភិបាលខណ្ឌដូនពេញ**

**សុខ ពេញវុធ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
លេខ: ១០៣/២១ សរ.ព

សាលាខណ្ឌដូនពេញ
ចូល
លេខ.....៤៦១.....
ថ្ងៃទី..១៧.០៣.២១..
បញ្ជូន.........

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមការងារវាយតម្លៃទីក្រុងស្អាត រាជធានីភ្នំពេញ

## អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញសេចក្ដីសម្រេចលេខ១២ សសរ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- យោងលិខិតលេខ ០០៤ សជណ.គជវទ ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ស្ដីពីការរៀបចំសម្រួលសមាសភាពក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានី-ខេត្ត
- យោងតាមការចាំបាច់ចំពោះមុខ

## សម្រេច

**ប្រការ ១ ._**

ត្រូវបានបង្កើតក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឃួង ស្រេង | អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ | ប្រធាន |
| ២-ឯកឧត្តម | ហួត ហៃ | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៣-លោកជំទាវ | កែវ សុខពិសី | អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៤-លោក | សេង វណ្ណៈ | នាយករដ្ឋបាលសាលារាជធានីភ្នំពេញ | អនុប្រធាន |
| ៥-លោក | ម៉ម ភាសនា | ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ | សមាជិកអចិន្ត្រៃយ៍ |

៦-តំណាងស្នងការនគរបាលរាជធានីភ្នំពេញ សមាជិក
៧-តំណាងមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ សមាជិក
៨-លោកស្រី សក់ ចិន្តាវី នាយិការងរដ្ឋបាលសាលារាជធានីភ្នំពេញ សមាជិកា
៩-លោក-លោកស្រីអភិបាល នៃគណៈអភិបាលខណ្ឌទាំង១៨ សមាជិក-សមាជិកា ✓
១០-លោក ម៉ៅ តឹមថេង ប្រធានមន្ទីរមុខងារសាធារណៈរាជធានីភ្នំពេញ សមាជិក
១១-លោក យុគ សំខាន់ ប្រធានមន្ទីរព័ត៌មានរាជធានីភ្នំពេញ សមាជិក
១២-លោក ហៃម ស៊ីណារ៉េត ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ សមាជិក
១៣-លោក គាត វង្ស៊ី ប្រធានមន្ទីរបរិស្ថានរាជធានីភ្នំពេញ សមាជិក
១៤-លោក ធី មានហេង ប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ សមាជិក
១៥-លោក សារិន វណ្ណា ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដីរាជធានីភ្នំពេញ សមាជិក
១៦-លោក សាំ ពិសិដ្ឋ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ សមាជិក
១៧-លោក ជុំ វុន្ន៊ី ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ សមាជិក
១៨-លោក នេត មុនីប៊ុណ្ណាកា ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ សមាជិក
១៩-លោក ធី ប៊ុនលី ប្រធានមន្ទីររ៉ែ និងថាមពលរាជធានីភ្នំពេញ សមាជិក
២០-លោក ចាន់ រិទ្ធី ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ សមាជិក
២១-លោក ម៉ៅ ប៊ុនធឿន ប្រធានមន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ សមាជិក
២២-លោក គឹម ច័ន្ទឌីណា ប្រធានមន្ទីរផែនការរាជធានីភ្នំពេញ សមាជិក
២៣-លោក ពៅ គាងឡេង ប្រធានមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ សមាជិក
២៤-លោក ទេព គង្គា ប្រធានមន្ទីរធម្មការ និងសាសនារាជធានីភ្នំពេញ សមាជិក
២៥-លោកស្រី ច័ន្ទ សុគន្ធា នាយិកាទីចាត់ការអន្តរវិស័យ សមាជិកា
២៦-លោក អ៊ុក សុផល នាយកទីចាត់ការហិរញ្ញវត្ថុ សមាជិក
២៧-លោក នួន សំណាវុធ នាយកទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន សមាជិក
២៨-លោក កាំង លាងគ្រី នាយកទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស សមាជិក
២៩-លោក ស៊ិន បូណិមី នាយកទីចាត់ការរៀបចំក្រុង សមាជិក
៣០-លោក ម៉េត មាសភក្តី នាយកទីចាត់ការផែនការ និងវិនិយោគ សមាជិក
៣១-លោក យុន វណ្ណា នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស សមាជិក
៣២-លោកស្រី ផាន សុភ័ក្រនីត្តា នាយិកាទីចាត់ការទំនាក់ទំនងសាធារណៈ
និងសហប្រតិបត្តិការអន្តរជាតិ សមាជិកា
៣៣-លោកស្រី ដោ សម្ផស្ស នាយិកាទីចាត់ការរដ្ឋបាល សមាជិកា
៣៤-លោកស្រី មូក យុវល័ក្ខ ប្រធានអង្គភាពច្រកចេញ-ចូលតែមួយ សមាជិកា
៣៥-លោក ជុំ បូរ៉ែន នាយករងទីចាត់ការអន្តរវិស័យ សមាជិក
៣៦-លោក ប៊ុន ដារ៉ា ប្រធានការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច សមាជិក
៣៧-លោកស្រី អៀង សុវ័ណ្ណា ប្រធានការិយាល័យសរុប និងព័ត៌មាន សមាជិកា
៣៨-លោកស្រី សយ សារិន អនុប្រធានការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច សមាជិកា
៣៩-លោក ហេង គឹមហ៊័រ អនុប្រធានការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច សមាជិក
៤០-លោក វ័ត្ត សុភា មន្ត្រីការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច សមាជិក
៤១-លោកស្រី ម៉ម សុធា មន្ត្រីការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច សមាជិកា

ខ-តួនាទី និងភារកិច្ច

-សម្របសម្រួល ជំរុញខណ្ឌាបេក្ខភាពទាំងអស់ឱ្យបំពេញ ចុះឈ្មោះក្នុងចលនាប្រឡងប្រណាំង ទីក្រុងស្អាត និងចលនាប្រឡងប្រណាំងនានាតាមគោលការណ៍ និងសេចក្ដីណែនាំផ្សេងៗ របស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ( គ.ជ.វ.ទ )

-សម្របសម្រួលជាមួយមន្ទីរជំនាញពាក់ព័ន្ធ ដើម្បីបំពេញបែបបទលើគម្រោងអភិវឌ្ឍន៍ផ្សេងៗ និងឯកសាររបស់ខណ្ឌាបេក្ខភាពឱ្យបានត្រឹមត្រូវតាមស្តង់ដារទីក្រុងស្អាត

-ដកស្រង់ទិន្នន័យ ផែនការអភិវឌ្ឍន៍ទេសចរណ៍របស់រដ្ឋបាលរាជធានីភ្នំពេញ និងផ្សព្វផ្សាយជូនខណ្ឌាបេក្ខភាពឱ្យបានជ្រាប ដើម្បីបំពេញឯកសារតាមសូចនាករលម្អិតរបស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ( គ.ជ.វ.ទ )

-ប្រមូល និងចងក្រងឯកសារពាក់ព័ន្ធ ដើម្បីធ្វើរបាយការណ៍សរុបជូនប្រធានក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានីភ្នំពេញ ឱ្យបានទៀងទាត់ ។

**ប្រការ ៤ ._**

-ក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានីភ្នំពេញ មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលរាជធានីភ្នំពេញ ដើម្បីសម្រួលការងារតាមការចាំបាច់

-សមាជិក សមាជិកាទាំងអស់ដែលមានឈ្មោះនៅក្នុងប្រការ ១ និងប្រការ ៣ ខាងលើ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ និងប្រធានលេខាធិការដ្ឋាន

-ក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានីភ្នំពេញ និងលេខាធិការដ្ឋាន មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱ្យវាទ ដើម្បីអនុវត្តការងារតាមការចាំបាច់ ។

**ប្រការ ៥ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦ ._**

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខណ្ឌទាំង១៤ ប្រធានមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធជុំវិញរដ្ឋបាលរាជធានីភ្នំពេញ និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ និងប្រការ៣ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ សុក្រ ១១ កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០២១

អភិបាលរាជធានីភ្នំពេញ

**ឃួង ស្រេង**

<u>**កន្លែងទទួល៖**</u>

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងទេសចរណ៍

-គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

« *<u>ដើម្បីគោរពជូនជ្រាប</u>* »

-ដូចក្នុងប្រការ ៦

« *<u>ដើម្បីអនុវត្ត</u>* »

-ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ
រដ្ឋបាលខណ្ឌដូនពេញ
លេខ:..៦៥៦/......សសរ/ដព
/២១

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារវាយតម្លៃទីក្រុងស្អាត ខណ្ឌដូនពេញ

### អភិបាល នៃគណៈអភិបាលខណ្ឌដូនពេញ

**យោង៖**

- អនុក្រឹត្យលេខ១១៧៥អនក្រ.តត ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០១៦ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ រាជធានីភ្នំពេញ របស់រាជរដ្ឋាភិបាលកម្ពុជា
- លិខិតលេខ០០៨ សជណ.គជវទ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ស្តីពីការរៀបចំសម្រួលសមាសភាពក្រុមការងារវាយតម្លៃទីក្រុងស្អាត រាជធានី-ខេត្ត
- សេចក្តីសម្រេចលេខ០០៧សសរ.គជវទ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ស្តីពី លក្ខណវិនិច្ឆ័យនិងនីតិវិធី នៃការផ្តល់វិញ្ញាបនបត្របញ្ជាក់ ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិដែលអនុវត្តបានសុវត្ថិភាពទេសចរណ៍បានល្អក្នុងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត មណ្ឌលយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ"
- សេចក្តីសម្រេចលេខ១០៣/២១សសរ.អ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃទីក្រុងស្អាត រាជធានីភ្នំពេញ
- តាមការចាំបាច់ចំពោះមុខ

### សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតក្រុមការងារវាយតម្លៃទីក្រុងស្អាតខណ្ឌដូនពេញ រួមមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-លោក សុខ ពេញវុធ | អភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ | ប្រធាន |
| ២-លោក ចាន់ គន្ធក | អភិបាលរងខណ្ឌ | អនុប្រធាន |
| ៣-លោក ទៀង ច័ន្ទសារ | អធិការនគរបាលខណ្ឌ | អនុប្រធាន |
| ៤-លោក ថោង ពិសិដ្ឋ | មេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ | អនុប្រធាន |
| ៥-លោក ចាប ឌីណា | នាយករដ្ឋបាលខណ្ឌ | អនុប្រធាន |
| ៦-លោក ហឿន ប្រសើរ | ប្រធានការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ខណ្ឌ | សមាជិក អចិន្ត្រៃយ៍ |
| ៧-លោក រេកម វុត្ថា | ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌ | សមាជិក |

ក្រុមបានបង្កើតលេខាធិការដ្ឋានមួយដើម្បីជាជំនួយការក្រុមការងារវាយតម្លៃទីក្រុងស្អាតខណ្ឌដូនពេញ ដែលមានសមាសភាព និងតួនាទីភារកិច្ចដូចខាងក្រោម៖

ក-សមាសភាព

| | | |
|---|---|---|
| ១-លោក **ចាន់ គន្ធេត** | អភិបាលរងខណ្ឌ | ប្រធាន |
| ២-លោក ចាប ឌីណា | នាយករដ្ឋបាលខណ្ឌ | អនុប្រធាន |
| ៣-លោក ហៀន ប្រសើរ | ប្រធានការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ខណ្ឌ | សមាជិកអចិន្ត្រៃយ៍ |
| ៤-លោក នី សាមិត្ត | ប្រធានការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈខណ្ឌ | សមាជិក |
| ៥-លោក អោម វុត្ថា | ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌ | សមាជិក |
| ៦-លោក ជុង ពេជសំរិទ្ធ | ប្រធានអង្គភាពលទ្ធកម្មខណ្ឌ | សមាជិក |
| ៧-លោក រិន សំណាង | ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិកខណ្ឌ | សមាជិក |
| ៨-លោក គួយ ស៊ុយប៊ុន | ប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុខណ្ឌ | សមាជិក |
| ៩-លោក សេង សូរិយា | ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខណ្ឌ | សមាជិក |
| ១០-លោក ស៊ាម ម៉េងអ៊ី | ប្រធានការិយាល័យច្រកចេញចូលតែមួយខណ្ឌ | សមាជិក |
| ១១-លោក ហេង វេលង់ | ប្រធានការិយាល័យអប់រំយុវជននិងកីឡាខណ្ឌ | សមាជិក |
| ១២-លោក គង់ ធី | ប្រធានការិយាល័យធម្មការនិងសាសនាខណ្ឌ | សមាជិក |
| ១៣-លោក ជិត ណារិទ្ធ | អនុប្រធានការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ខណ្ឌ | សមាជិក |
| ១៤-លោក ជិន បូរី | មន្ត្រីការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន | សមាជិក |
| ១៥-លោក លោកស្រី | ចៅសង្កាត់ទាំង១១ | សមាជិក សមាជិកា |
| ១៦-លោក | នាយនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ទាំង១១ | សមាជិក |
| ១៧-លោក លោកស្រី | ប្រធានទីរួមផ្សារទាំង០៣ | សមាជិក សមាជិកា |

ខ-តួនាទី និងភារកិច្ច

- សម្របសម្រួល ជំរុញគ្រប់ស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងអស់ ដើម្បីផ្តល់ឯកសារក្នុងការបំពេញចុះឈ្មោះប្រឡងប្រណាំងទីក្រុងស្អាត និងការប្រឡងប្រណាំងនានាតាមគោលការណ៍ និងសេចក្តីណែនាំផ្សេងៗរបស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត (គ.ជ.វ.ទ)
- សម្របសម្រួលជាមួយមន្ទីរជំនាញពាក់ព័ន្ធ ដើម្បីបំពេញបែបបទលើគម្រោងអភិវឌ្ឍន៍ផ្សេងៗ និងឯកសាររបស់ខណ្ឌបេក្ខភាព ខណ្ឌដូនពេញឲ្យបានត្រឹមត្រូវ ពេញលេញ តាមស្តង់ដារទីក្រុងស្អាត
- ដកស្រង់ទិន្នន័យ គម្រោងអភិវឌ្ឍន៍រាជធានី-ខណ្ឌ-សង្កាត់ និង ផែនការអភិវឌ្ឍន៍ទេសចរណ៍របស់រដ្ឋបាលរាជធានីភ្នំពេញដើម្បីបំពេញឯកសារតាមសូចនាករលម្អិតរបស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត (គ.ជ.វ.ទ)
- ប្រមូល និង ចងក្រងឯកសារពាក់ព័ន្ធដើម្បីធ្វើរបាយការណ៍សរុបជូនប្រធានក្រុមការងារវាយតម្លៃទីក្រុងស្អាតខណ្ឌដូនពេញឲ្យបានទៀងទាត់។

ប្រការ៤._

- ក្រុមការងារវាយតម្លៃទីក្រុងស្អាតខណ្ឌដូនពេញ មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលខណ្ឌដូនពេញ ដើម្បីសម្រួលការងារតាមការចាំបាច់

- សមាជិក សមាជិកាទាំងអស់ដែលមានឈ្មោះនៅក្នុងប្រការ១និងប្រការ៣ខាងលើ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារនិងប្រធានលេខាធិការដ្ឋាន

- ក្រុមការងារវាយតម្លៃទីក្រុងស្អាតខណ្ឌដូនពេញ និងលេខាធិការដ្ឋាន មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទដើម្បីអនុវត្តការងារតាមការងារចាំបាច់។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

នាយករដ្ឋបាលសាលាខណ្ឌ អធិការដ្ឋាននគរបាលខណ្ឌ មេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១និងប្រការ៣ខាងលើត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១១រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅដូនពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០២១
អភិបាលរងនៃគណៈអភិបាលខណ្ឌដូនពេញ

សុខ ពេញវុធ

<u>ចម្លងជូន</u>
-រដ្ឋបាលរាជធានីភ្នំពេញ
-មន្ទីរទេសចរណ៍រាជធានីភ្នំពេញ
-ក្រុមប្រឹក្សាខណ្ឌដូនពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ៦
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ
រដ្ឋបាលខណ្ឌដូនពេញ
លេខៈ ......០០៣៥|......សសរ/អណា៣
|២១

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឲ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌដូនពេញ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងអនុក្រឹត្យលេខ២១៥ អនក្របកចុះថ្ងៃទី ១៤ ខែធ្នូឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សាគណៈអភិបាល ខណ្ឌ នៃរាជធានីភ្នំពេញ
- យោងអនុក្រឹត្យលេខ ៦៦អនក្រ តត ចុះថ្ងៃទី១០ ខែ មិថុនា ឆ្នាំ២០១៩ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខណ្ឌដូនពេញអណត្តិទី៣
- យោងអនុក្រឹត្យ ២១៩ អនក្រ-បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគ បីឆ្នាំ រំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ ១៥២ អនក្រ-បក ចុះថ្ងៃទី៦ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកែសំរួលមាត្រាទី១២នៃអនុក្រឹត្យស្តីពីការកសាងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងប្រកាសអន្តរក្រសួងលេខ ០៧៥ ផក. ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ
- យោងផែនការអភិវឌ្ឍន៍៥ឆ្នាំ ២០២០-២០២៤ របស់រដ្ឋបាលខណ្ឌដូនពេញ
- យោងកិច្ចប្រជុំសាមញ្ញ លើកទី១៩ របស់ក្រុមប្រឹក្សាខណ្ឌដូនពេញអាណត្តិទី៣ នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

## សម្រេច

**ប្រការ១** ត្រូវបានដាក់ឲ្យប្រើប្រាស់នូវ កម្មវិធីវិនិយោគបីឆ្នាំរំកិល ឆ្នាំ ២០២១-២០២៣ របស់រដ្ឋបាលខណ្ឌដូនពេញ ដែលត្រូវបានអនុម័តដោយ ក្រុមប្រឹក្សាខណ្ឌដូនពេញ នាកិច្ចប្រជុំសាមញ្ញ លើកទី១៩ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ។

**ប្រការ២** - គណៈអភិបាលខណ្ឌដូនពេញ ត្រូវចាត់ចែងផ្សព្វផ្សាយ កម្មវិធីវិនិយោគនេះ ដល់ប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធនានា នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខណ្ឌដូនពេញ ។

- គណៈអភិបាលខណ្ឌដូនពេញ ត្រូវចាត់ចែងសម្របសម្រួល និង កៀរគរធនធាននានា ក្នុងការអនុវត្តកម្មវិធីវិនិយោគនេះ ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និង ការចូលរួម ។

**ប្រការ៣** - គណៈអភិបាលខណ្ឌដូនពេញ ត្រូវរៀបចំយន្តការ និង ប្រព័ន្ធសម្រាប់ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តកម្មវិធីវិនិយោគនេះ ដោយមានការចូលរួមគ្រប់អ្នកពាក់ព័ន្ធនានា ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តគម្រោងវិនិយោគ ។

- គណៈអភិបាលខណ្ឌដូនពេញ ត្រូវរៀបចំរបាយការណ៍ ស្តីពីលទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តន៍កម្មវិធីវិនិយោគនេះ និង រាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាខណ្ឌដូនពេញ អំពីវឌ្ឍនភាពនៃការអនុវត្តនេះ ទៅតាមកាលកំណត់ ។
- គណៈអភិបាលខណ្ឌដូនពេញ ត្រូវរៀបចំ និង ដាក់ជូនក្រុមប្រឹក្សាខណ្ឌ អំពីរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តកម្មវិធីវិនិយោគនេះ ។

**ប្រការ៤** គណៈអភិបាលខណ្ឌដូនពេញ ត្រូវធ្វើការវាយតម្លៃការអនុវត្ត កម្មវិធីវិនិយោគនេះ នៅដំណាច់ឆ្នាំ ដើម្បីវាយតម្លៃអំពីលទ្ធផលសម្រេចបាន ធៀបនឹងគោលដៅ និង គោលបំណងដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍ខណ្ឌ ។

**ប្រការ៥** គណៈអភិបាល គ្រប់ការិយាល័យ និង អង្គភាពពាក់ព័ន្ធទាំងអស់ក្នុងខណ្ឌដូនពេញ ត្រូវអនុវត្តន៍សេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ថ្ងៃចន្ទ ៦រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*
*ដូនពេញ, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១*
*ជ. ក្រុមប្រឹក្សាខណ្ឌដូនពេញ*
**ប្រធាន**

**ហែម_អាន**

**កន្លែងទទួល**
- *ក្រុមប្រឹក្សារាជធានីភ្នំពេញ*
- *សាលារាជធានីភ្នំពេញ*
- *មន្ទីរផែនការរាជធានីភ្នំពេញ*
*"ដើម្បីជូនជ្រាប"*
- *គ្រប់សមាជិកក្រុមប្រឹក្សាខណ្ឌ*
*"ដើម្បីមុខការ"*
- *ដូចប្រការ៥ "ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
៣៧១ · ០០៧/១៧ សណន ៥

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៧

## សេចក្តីណែនាំ
## ស្តីពី
## ការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

ក្នុងរយៈពេលកន្លងមកនេះ រដ្ឋបាលរាជធានីភ្នំពេញពិនិត្យឃើញថា បងប្អូនប្រជាពលរដ្ឋមួយចំនួនដែលជាម្ចាស់លំនៅដ្ឋាន ម្ចាស់សហគ្រាស ម្ចាស់ហាង ម្ចាស់អាជីវកម្ម មន្ទីរពេទ្យ សាលារៀន ស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជនផ្សេងទៀត បាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងដាយផ្លូវមិនទាន់បានសមស្របទាំងស្រុង ឬដោយបំពានលើបទប្បញ្ញត្តិច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ជាពិសេសបំពានលើបទប្បញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ និងបទដ្ឋានគតិយុត្តដែលអនុវត្តក្នុងវិស័យនគរូបនីយកម្ម និងសំណង់។ អំពើរលោភបំពានទាំងនោះមានជាអាទិ៍ ការយកទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងដាយផ្លូវធ្វើជាចំណតយានជំនិះ ការតសំយ៉ាប ការហ៊ុំព័ទ្ធយកចិញ្ចើមផ្លូវ ការយកផ្លូវថ្មើរជើង ឬចិញ្ចើមផ្លូវធ្វើទីតាំងការដ្ឋានទុកដាក់សម្ភារៈ ឬដាក់តាំងបង្ហាញទំនិញ ឬប្រកបអាជីវកម្ម ផ្សេងៗជាលក្ខណៈឯកជន ដែលបង្កឱ្យមានការកកស្ទះចរាចរណ៍ និងជះឥទ្ធិពលអវិជ្ជមានដល់សណ្តាប់ធ្នាប់សាធារណៈ និងសោភណភាពរាជធានីភ្នំពេញ។

អនុវត្តតាមស្មារតីនៃកិច្ចប្រជុំគណៈបញ្ជាការឯកភាពកាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ រដ្ឋបាលរាជធានីភ្នំពេញសម្រេចជ្រើសយកផ្លូវសំខាន់ៗចំនួន ១១ខ្សែ ធ្វើជាអាទិភាពគំរូ សម្រាប់អនុវត្តផែនការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់សាធារណៈ មុននឹងបន្តអនុវត្តចំពោះបណ្តាទីតាំងផ្សេងៗទៀតក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ ផ្លូវអាទិភាពគំរូទាំងនោះរួមមាន៖ ១- មហាវិថីសហព័ន្ធរុស្សី, ២- មហាវិថីព្រះមុនីវង្ស, ៣- មហាវិថីកម្ពុជាក្រោម, ៤- មហាវិថីម៉ៅសេទុង, ៥- មហាវិថីព្រះសីហនុ និងមហាវិថីនេរូហ៍, ៦- មហាវិថីព្រះនរោត្តម, ៧- មហាវិថីសម្តេចមុនីរ៉េត, ៨- ផ្លូវឧកញ៉ាទេពផន, ៩- មហាវិថីហ្សាលនីហ្គោល, ១០- មហាវិថីយោធពលខេមរភូមិន្ទ (ផ្លូវ២៧១) និងផ្លូវឧកញ៉ាឃ្លាំងមឿង (ផ្លូវលេខ៧០) និង ១១- តីរវិថីព្រះស៊ីសុវត្ថិ។

ដូចនេះ ដើម្បីដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវអាទិភាពខាងលើ រដ្ឋបាលរាជធានីភ្នំពេញ ដាក់ចេញនូវសេចក្តីណែនាំដូចខាងក្រោម៖

**ក. ចំពោះបងប្អូនប្រជាពលរដ្ឋ ម្ចាស់លំនៅដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន មន្ទីរពេទ្យ សាលារៀនវិស័យឯកជន អគារសាធារណៈ និងអ្នកប្រើប្រាស់ផ្លូវថ្នល់ ត្រូវអនុវត្តដូចខាងក្រោម៖**

១. ហាមចតយានយន្តគ្រប់ប្រភេទនៅលើទ្រូងផ្លូវ។

៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

២. ហាមដាច់ខាតមិនឱ្យម្ចាស់ការដ្ឋានសំណង់គ្រប់ប្រភេទ ធ្វើការហ៊ុមព័ទ្ធការដ្ឋានលើចិញ្ចើមផ្លូវលើសពី១/៣ (មួយភាគបី) និងឬប្រើប្រាស់ទ្រូងផ្លូវដើម្បីទុកដាក់សម្ភារៈសំណង់របស់ខ្លួន ដូចជា ដែក ខ្សាច់ គ្រួស ថ្ម ជាដើម។

៣. រថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ ត្រូវចេញ-ចូល គោរពតាមការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ និងជៀសវាងការប្រើប្រាស់ទ្រូងផ្លូវក្នុងការលើកដាក់ ផ្ទេរទំនិញ និងបាញ់បេតុង។ ក្នុងករណីជៀសវាងមិនបាន ត្រូវអនុវត្តការលើកដាក់ទំនិញ និងការបាញ់បេតុង ចាប់ពីម៉ោង២១:០០នាទី រហូតដល់ម៉ោង០៦:០០នាទីព្រឹក។

៤. ការរៀបចំសម្ភារៈ ទំនិញ ម៉ូតូ និងរថយន្តដាក់តាំងលក់ អាចប្រើប្រាស់ចំណែកចិញ្ចើមផ្លូវត្រឹម ១/៣ (មួយភាគបី) ជាលក្ខណៈបណ្ដោះអាសន្នតែប៉ុណ្ណោះ ដោយទុក២/៣ (ពីរភាគបី) សម្រាប់ថ្មើរជើង និងបម្រើឱ្យការងារសណ្ដាប់ធ្នាប់ និងចរាចរណ៍។

៥. រាល់ការប្រើប្រាស់ចិញ្ចើមផ្លូវជាទីតាំងផ្ញើកង់ ម៉ូតូ មិនត្រូវឱ្យលើសពី១/៣ (មួយភាគបី) ឡើយ។

**ខ. ចំពោះគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ ត្រូវអនុវត្តដូចខាងក្រោម៖**

១. ត្រូវចុះធ្វើការអប់រំណែនាំដល់ប្រជាពលរដ្ឋ ដែលបាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវដោយរំលោភបំពាន ដោយប្រើប្រាស់វិធីសាស្ត្រទន់ភ្លន់ តែម៉ឺងម៉ាត់ ឱ្យចូលរួមអនុវត្តតាមស្មារតីនៃសេចក្ដីណែនាំនេះ។ ក្នុងករណីនៅតែមិនអនុវត្តតាមការណែនាំនេះ មន្ត្រីអនុវត្តត្រូវធ្វើកំណត់ហេតុ និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

២. ត្រូវណែនាំដល់ម្ចាស់ទីតាំងភោជនីយដ្ឋាន និងម្ចាស់ទីតាំងអាជីវកម្មនានាឱ្យគោរពតាមខ្លឹមសារនៃសេចក្ដីណែនាំនេះ ក្នុងករណីពុំព្រមអនុវត្តតាម អាជ្ញាធរខណ្ឌត្រូវសហការជាមួយកម្លាំងមានសមត្ថកិច្ច និងជំនាញពាក់ព័ន្ធធ្វើការផាកពិន័យតាមច្បាប់ និងអាចឈានទៅបិទទីតាំងអាជីវកម្ម។

៣. ត្រូវធ្វើការណែនាំ និងធ្វើកំណត់ហេតុឱ្យបានត្រឹមត្រូវជាមួយម្ចាស់ការដ្ឋានដែលរំលោភបំពានទ្រូងផ្លូវ និងចិញ្ចើមផ្លូវ ក្នុងករណីមិនរាងចាល ត្រូវផ្អាកការដ្ឋាននោះភ្លាម។

៤. ត្រូវចុះល្បាត និងឃ្លាំមើលជាប្រចាំចំពោះរថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ និងត្រូវមានវិធានការឱ្យបានម៉ឺងម៉ាត់ក្នុងករណីការចេញ-ចូលរាជធានីភ្នំពេញខុសពីសេចក្ដីណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ។

៥. ត្រូវអនុវត្តការងារតាមការណែនាំខាងលើនេះ ឱ្យបានត្រឹមត្រូវ ហ្មត់ចត់ និងទន់ភ្លន់ និងត្រូវរាយការណ៍ប្រចាំសប្ដាហ៍អំពីលទ្ធផលនៃការងារនេះ មកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញឱ្យបានទៀងទាត់ និងទាន់ពេលវេលា។

**គ. ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញត្រូវ៖**

១. បន្ថែមកម្លាំងនគរបាលចរាចរណ៍ ដោះស្រាយបញ្ហាចរាចរណ៍តាមគោលដៅដែលមានការកកស្ទះ នៅចន្លោះម៉ោងមមាញឹក គឺម៉ោង ០៧:៣០នាទី ដល់ម៉ោង ០៨:៣០នាទី, ម៉ោង ១១:៣០នាទី ដល់ម៉ោង ១២:៣០នាទី និងម៉ោង ១៧:០០នាទី ដល់ម៉ោង ១៨:៣០នាទី។

២. រៀបចំរថយន្តស្ទូច ដើម្បីសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ ដើម្បីអនុវត្តវិធានការច្បាប់។


៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ១២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

ទទួលបានសេចក្តីណែនាំនេះ ប្រជាពលរដ្ឋ គ្រឹះស្ថានឯកជន ស្ថាប័នសាធារណៈ និងអ្នកប្រើប្រាស់ផ្លូវ មានរយៈពេល ០២ (ពីរ)សប្តាហ៍ គិតចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះ ដើម្បីធ្វើការកែសម្រួល និងរៀបចំទីតាំងរបស់ខ្លួនឱ្យស្របតាមស្មារតីនៃសេចក្តីណែនាំនេះ។

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាលខណ្ឌទាំង១២ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ បងប្អូនប្រជាពលរដ្ឋ អ្នកប្រើប្រាស់ផ្លូវទាំងអស់ត្រូវរួមអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

ឃួង ស្រេង

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
  "ដើម្បីជូនជ្រាប"
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង ១២
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ
  "ដើម្បីអនុវត្ត"
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
  "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខ: ៤៧៨ សជណ

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៧*

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**សូមគោរពជូន**

- **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
- **លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី**
- **លោកជំទាវរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ** : កំណើរបាយការណ៍ស្តីពីការផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពី ការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦ -២០២៦ កាលពីថ្ងៃទី ៦ ខែមេសា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

**យោង** : - លិខិតលេខ ១៩៣ ក.ក.ជ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

- ចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧។

តបតាមកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា : ដើម្បីជំរុញការងារចលនាភូមិមួយ ផលិតផលមួយ កាន់តែមានសន្ទុះខ្លាំងក្លា និងមានសមិទ្ធិផលធំធេង ស្របតាមគោលនយោបាយជាតិ ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយឆ្នាំ ២០១៦-២០២៦ រាជរដ្ឋាភិបាលបានសម្រេចឯកភាពលើ ០៥ចំណុច ដូចខាងក្រោម៖

១.គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវរៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរជារៀងរាល់ឆ្នាំ ដែលទិវាជាតិនេះត្រូវប្រព្រឹត្តទៅនៅថ្ងៃទី០៩ ខែមេសា មុនការរៀបចំពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិរបស់យើង ដើម្បីឲ្យប្រជាជនយើងបានយល់ដឹងនិងទិញទំនិញប្រើប្រាស់ជាផលិតផលខ្មែរ នៅក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិរបស់យើង។

២.ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយ នៅក្នុងស្ថាប័នរបស់ខ្លួនដើម្បីរួមសហការជាមួយនឹងអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយ ដែលជាសេនាធិការជូនគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ។

៣.ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលជាសមាជិកគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ ត្រូវសហការគ្នារៀបចំផែនការនិងយុទ្ធសាស្ត្ររួមគ្នាឲ្យមានប្រសិទ្ធភាពខ្ពស់ និងការប្រជុំចែករំលែកបទពិសោធដើម្បីដោះស្រាយបញ្ហានិងការប្រឈមនានា ក្នុងការលើកកម្ពស់ផលិតផលខ្មែរ និងការយល់ដឹងនិងប្រើប្រាស់ផលិតផលខ្មែរ។

៤.គណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយរាជធានី-ខេត្ត ទូទាំងប្រទេស ដែលបានរៀបចំបង្កើតកាលពីឆ្នាំ២០១៤ ត្រូវសហការឲ្យបានជិតស្និទ្ធជាមួយនឹងអគ្គលេខាធិការដ្ឋានភូមិមួយ ផលិតផលមួយក្នុងស្មារតីទទួលខុសត្រូវខ្ពស់នៃការខិតខំលើកកម្ពស់ផលិតផលខ្មែរ ក្នុងដែនសមត្ថកិច្ចរាជធានី-ខេត្តរបស់ខ្លួន ដោយប្រើប្រាស់យន្តការនានា និងធនធានថវិការបស់សាលាខេត្ត និងមន្ទីរវិស័យពាក់ព័ន្ធក្នុងការចូលរួមជំរុញនិងលើកកម្ពស់ផលិតផលខ្មែរក្នុងរាជធានីខេត្តរបស់ខ្លួន។

៥.ក្នុងគោលដៅលើកកម្ពស់ផលិតផលក្នុងស្រុក សូមឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជួយបង្កើនកញ្ចប់ថវិកាជាតិដល់គណៈកម្មាធិការជាតិ ក៏ដូចជាគណៈកម្មាធិការរាជធានី-ខេត្តជំរុញចលនាភូមិមួយផលិតផលមួយ ដើម្បីគាំទ្រការអនុវត្តគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ មេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

ប៊ុន-អ៊ុយ

**ចម្លងជូន** :

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី ខេត្តទាំង២៥
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-សភាពាណិជ្ជកម្មកម្ពុជា
-សភាមុខរបរនិងមីក្រូសហគ្រាស
-កាកបាទក្រហមកម្ពុជា
ឯកសារ កាលប្បវត្តិ